ឯកសារស្រាវជ្រាវ

# យន្តការដោះស្រាយពាក្យបណ្តឹងនៅក្នុងប្រទេស កម្ពុជា និងអាស៊ាន

*រាជធានីភ្នំពេញថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣*

**វិទ្យាស្ថានសភាកម្ពុជា**

# តារាងមាតិកា


**សេចក្តីផ្តើម** ................................................ ២

**ផ្នែកទី១៖ យន្តការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយក្នុងប្រទេសកម្ពុជា**… ៤

១. សារៈសំខាន់នៃគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ........ ៤

២. ក្រុមការងារគណនេយ្យភាពខេត្ត និងថ្នាក់ជាតិ........ ៥

៣. ក្រុមការងារគណនេយ្យភាពខេត្ត និងថ្នាក់ជាតិការិយាល័យច្រកចេញចូលតែមួយ និងយន្តការការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក........ ១០

៤. វិធីសាស្ត្រនានាដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងបាន........ ១២

៥. តួនាទីរបស់សភាក្នុងការដោះស្រាយពាក្យបណ្តឹងរបស់ម្ចាស់ឆ្នោត........ ១៦

៦. លទ្ធផលនៃការសិក្សាស្រាវជ្រាវ........ ១៦

**ផ្នែកទី២៖ ការសិក្សាប្រៀបធៀបទៅលើបទពិសោធន៍តំបន់ស្តីពីការដោះស្រាយបណ្តឹង និងដំណោះស្រាយនៃបណ្តាប្រទេសនីមួយៗ**........ ១៨

១. យន្តការដោះស្រាយបណ្តឹងនៅអាស៊ីអាគ្នេយ៍........ ១៨

២. ប្រទេសវៀតណាម........ ១៩

៣. ប្រទេសថៃ........ ២១

៤. ប្រទេសហ្វីលីពីន........ ២៤

៥. ការប្រៀបធៀបយន្តការបណ្តឹងនានា........ ២៧

**សេចក្តីសន្និដ្ឋាន**........ ៣១

**បញ្ជីនៃប្រភពឯកសារ**........ ៣២

**ឧបសម្ព័ន្ធក៖** ពាក្យបណ្តឹងដែលបានដាក់តាមរយៈក្រុមការងារគណនេយ្យភាពខេត្ត(PAWG) ការិយាល័យប្រជាពលរដ្ឋស្រុក(DO) និងអង្គការសង្គមស៊ីវិល........ ៣៨

**ឧបសម្ព័ន្ធ ខ៖** តារាងរចនាសម្ព័ន្ធនៃយន្តការបណ្តឹងរបស់ប្រទេសថៃ........ ៤២

# សេចក្តីផ្តើម

គណនេយ្យភាពមិនមែនពាក់ព័ន្ធត្រឹមតែទំនាក់ទំនងតួអង្គពីរប៉ុណ្ណោះទេ វាក៏ពាក់ព័ន្ធផងដែរទៅនឹងយន្តការ ច្បាប់ និងធនធានដែលអាចឲ្យប្រជាពលរដ្ឋចោទសួរ និងត្រួតពិនិត្យសកម្មភាពអាជ្ញាធរមូលដ្ឋានរបស់ពួកគេ។ នៅក្នុងវដ្តនៃការសិក្សា និងគោលនយោបាយ មានការកើនឡើងលើការយល់ដឹងអំពីសារៈសំខាន់នៃយន្តការគណនេយ្យភាព និងជម្រើសប្រកបដោយប្រសិទ្ធភាព ដើម្បីត្រួតពិនិត្យការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ យន្តការទាំងនេះ គឺចាំបាច់ណាស់ដើម្បីទប់ស្កាត់ការរំលោភបំពានលើការអនុវត្តអំណាច និងដើម្បីផ្តល់នូវជម្រើសដល់ប្រជាពលរដ្ឋដែលយល់ថាពួកគេបានធ្វើខុស។ យន្តការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិ គឺជាកត្តាសំខាន់ដែលជាការផ្ទេរនូវគណនេយ្យសាធារណៈដល់ថ្នាក់មូលដ្ឋាន ដោយធានាបាននូវភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ លើសពីនេះទៀត ដូចដែលបានរៀបរាប់លម្អិតខាងក្រោមនេះ ភាគច្រើននៃពាក្យបណ្តឹងមានទំនោរពាក់ព័ន្ធទៅនឹងបញ្ហានានានៃសារៈសំខាន់នៅមូលដ្ឋាន ដែលទាំងប្រភព និងធនធាននៃបញ្ហាជាការទទួលខុសត្រូវរបស់ថ្នាក់មូលដ្ឋាន។

យន្តការបណ្តឹងតំណាងឱ្យជំហានដ៏សំខាន់ឆ្ពោះទៅរកការបង្កើតប្រព័ន្ធគ្រប់គ្រងមួយ ដែលកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋខ្លួន និងការអនុវត្តអំណាចដែលមិនសូវមានលក្ខណៈរំលោភបំពាន។ ការណ៍នេះគឺស្ថិតក្នុងរបត់នៃការពង្រឹងការផ្សារភ្ជាប់គ្នារវាងពលរដ្ឋ និងរដ្ឋ និងអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការអភិវឌ្ឍតាមរយៈការកាត់បន្ថយអំពើពុករលួយ ប្រសិទ្ធផលត្រូវបានធ្វើឲ្យប្រសើរឡើង និងការកើនឡើងនៅក្នុងការអនុលោមធម្មានុរូប និងស្ថេរភាពនៅក្នុងរដ្ឋ។ យន្តការបណ្តឹងរបស់ប្រជាពលរដ្ឋរួមចំណែកជាវិជ្ជមានដល់ការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពនៃការគ្រប់គ្រង និងការចូលរួមជាមួយនឹងប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក្តី បញ្ហានេះកើតឡើងដោយមានលក្ខណៈផ្សេងៗគ្នា និងមានកម្រិតខុសៗគ្នាទៅតាមភាពចាស់ទុំ និងភាពរឹងមាំនៃបណ្តាប្រទេសនីមួយៗដែលបានលើកយកមកសិក្សា ហើយប្រសិទ្ធិភាពនៃយន្តការបែបនេះគឺអាស្រ័យលើកត្តាផ្សេងៗគ្នាដែលជះឥទ្ធិពលលើប្រពៃណីទំនៀមទម្លាប់របស់ពួកគេ។

នៅក្នុងបណ្តាប្រទេសផ្សេងគ្នា បែបបទនៃការរៀបចំការិយាល័យទទួលពាក្យបណ្តឹង ច្បាប់ដែលគាំទ្រលើវិស័យនេះ វិសាលភាពនៃអាណត្តិ និងវិធីសាស្ត្រនានាដែលសាធារណៈជនអាចទទួលបានអាចមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង។ ឧទាហរណ៍ៈ នៅក្នុងប្រទេសថៃ ការិយាល័យអំប៊ូស្មាន់ (អំប៊ូស្មាន់ គឺជា "មន្ត្រីរដ្ឋាភិបាលដែលត្រូវបានតែងតាំងដើម្បីទទួលនិងស៊ើបអង្កេតពាក្យបណ្តឹង ដែលធ្វើឡើងដោយបុគ្គលប្រឆាំងនឹងការរំលោភបំពាន ឬទង្វើមិនប្រក្រតីណាមួយរបស់មន្ត្រីសាធារណៈ")[1] ដែលត្រូវបានធ្វើមជ្ឈការ និងផ្តល់ឲ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងមានច្បាប់របស់ខ្លួន រីឯនៅក្នុងប្រទេសវៀតណាមវិញ យន្តការបណ្តឹងនេះត្រូវបានដាក់នៅតាម បណ្តាក្រសួងរបស់រដ្ឋាភិបាល និងមិនត្រូវបានដោះស្រាយតាមរដ្ឋធម្មនុញ្ញនោះទេ បើទោះបីជាវាមានច្បាប់ផ្ទាល់ខ្លួនក៏ដោយ។

---

[1] Marriam-Webster Dictionary, online, ដកស្រង់ថ្ងៃទី ៣ កក្កដា ២០១៣ http://www.merriam-webster.com/dictionary/ombudsman

នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការដាក់ពាក្យបណ្តឹង និងស្នើសុំឲ្យមានការបកស្រាយលើការសម្រេច តាមរយៈតំណាងជាប់ឆ្នោតរបស់ពួកគេនៅក្នុងក្រុមប្រឹក្សា។ ទោះជាយ៉ាងណាក្តី គណនេយ្យភាពសាធារណៈរបស់មន្ត្រី គឺជាផ្នត់គំនិតថ្មីមួយ ហើយយន្តការគណនេយ្យភាព និងការអនុវត្តអាចនៅពុំទាន់យល់បានពេញលេញនៅឡើយទេ ទាំងមន្ត្រី និងប្រជាពលរដ្ឋ។ ដើម្បីឲ្យយន្តការបណ្តឹងមានប្រសិទ្ធភាពគឺចាំបាច់ណាស់ដែលថាពួកគេអាចទទួលបានយ៉ាងងាយស្រួល ហើយប្រជាពលរដ្ឋមានការយល់ដឹងអំពីរបៀបក្នុងការដាក់ពាក្យបណ្តឹងតាមរយៈការអប់រំជាសាធារណៈ ដោយការប្រើប្រាស់យន្តការទាំងនេះ។ ប្រជាពលរដ្ឋ ត្រូវតែអាចដឹងថានរណាដែលពួកគេត្រូវប្តឹងទៅ និងវិធីសាស្ត្រផ្សេងៗយោងតាមបញ្ហាដែលពួកគេត្រូវប្តឹង។ ពាក្យបណ្តឹង ត្រូវតែត្រូវបានត្រួតពិនិត្យឡើងវិញ ដោយផ្អែកលើដំណើរការមួយច្បាស់លាស់ និងមានលក្ខណៈទាន់ពេលវេលា ហើយអាជ្ញាធរត្រូវចាត់វិធានការ និងមានការជូនដំណឹងដល់ប្រជាពលរដ្ឋអំពីការសម្រេចលើបណ្តឹងនោះ។ របបនៃការស៊ើបអង្កេត និងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានភាពច្បាស់លាស់ គឺមានសារៈសំខាន់ណាស់លើដំណើរការប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធិភាពនៃយន្តការទាំងនេះ។ ការពិចារណាដ៏សំខាន់មួយទៀត គឺឯករាជ្យភាពនៃយន្តការពីរដ្ឋបាលសាធារណៈ និងត្រូវមានការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការពេញលេញរបស់ខ្លួន។

នៅប្រទេសកម្ពុជាមានយន្តការបណ្តឹងសំខាន់ចំនួនពីរនៅថ្នាក់ក្រោមជាតិៈ ក្រុមការងារគណនេយ្យភាពខេត្ត(PAWG) និងប្រព័ន្ធអំប៊ុដ្ស្មានថ្នាក់ស្រុក ដែលនឹងត្រូវបានបញ្ជាក់លម្អិតនៅក្នុងផ្នែកដំបូងនៃឯកសារខាងក្រោមនេះ។ ផ្នែកទីពីរនៃឯកសារនេះ គឺជាការសិក្សាប្រៀបធៀបនៃបទពិសោធន៍ក្នុងតំបន់ជាមួយនឹងយន្តការដោះស្រាយពាក្យបណ្តឹងនៅប្រទេសវៀតណាម ថៃ និងហ្វីលីពីន។ ឯកសារនេះនឹងសិក្សាអំពីមូលដ្ឋានច្បាប់សម្រាប់យន្តការបណ្តឹង រចនាសម្ព័ន្ធរបស់ពួកគេ នីតិវិធី និងបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ។ ការសិក្សាប្រៀបធៀបនេះបានផ្តល់នូវផ្នត់គំនិត និងពិសោធន៍នៃការរួមបញ្ចូលគ្នា និងអនាគតនៃប្រព័ន្ធបណ្តឹងនៅថ្នាក់ក្រោមជាតិរបស់កម្ពុជា។ ពិសោធន៍ដែលស្តែងចេញពីការសិក្សានេះ គឺមានសារៈសំខាន់ណាស់សម្រាប់ការកំណត់នូវអាណត្តិឲ្យបានត្រឹមត្រូវ ធនធានគ្រប់គ្រាន់ អំណាចលើការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្ម ការយល់ដឹងជាសាធារណៈ និងភាពងាយស្រួលនៃការដាក់ពាក្យបណ្តឹង និងឯករាជ្យភាពនៃយន្តការដោះស្រាយពាក្យបណ្តឹង ដើម្បីឱ្យមានប្រសិទ្ធិភាព។

## ផ្នែកទី១៖ យន្តការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយក្នុងប្រទេសកម្ពុជា

## ១. សារៈសំខាន់នៃគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ

បើតាមឯកសាររបស់ Eng និង Craig(២០០៩)[2] គណនេយ្យភាពគឺជាតម្លៃផ្ទាល់ខ្លួន តម្លៃរដ្ឋបាល និង តម្លៃនយោបាយ ដែលបង្កប់នៅក្នុងបណ្តាស្ថាប័នផ្លូវការទាំងអស់។ ដើម្បីឲ្យប្រព័ន្ធអភិបាលកិច្ចមួយបំពេញមុខងារប្រកបដោយការទទួលខុសត្រូវ និងដើម្បីឲ្យប្រជាពលរដ្ឋមានលទ្ធភាពចោទសួរ និងត្រួតពិនិត្យការអនុវត្តរបស់អាជ្ញាធរមូលដ្ឋានខ្លួន វាមិនមែនជាកិច្ចការដែលពាក់ព័ន្ធត្រឹមតែតួអង្គពីរប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពាក់ព័ន្ធជាមួយយន្តការ ច្បាប់ទម្លាប់ និងធនធានផងដែរ។ ដើម្បីសម្រេចកិច្ចការនេះបាន វាមិនត្រឹមតែទាមទារឲ្យអាជ្ញាធរយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ និងបញ្ហារបស់ពលរដ្ឋ និងទាមទារឲ្យពួកគេដឹងអំពីកាតព្វកិច្ចរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវការយន្តការដែលអនុញ្ញាតឲ្យអាជ្ញាធរឆ្លើយតបដោយផ្ទាល់ ចំពោះពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋអំពីសកម្មភាពរដ្ឋបាល ឬដែលអនុញ្ញាតឲ្យភ្នាក់ងារឯករាជ្យណាមួយជំរុញឲ្យអាជ្ញាធរឆ្លើយតបក៏បាន។ ដំណើរការនេះត្រូវតែអនុវត្តក្នុងវិធីមួយដែលច្បាស់លាស់ និងងាយយល់។ ប៉ុន្តែចំពោះកម្ពុជា បើយើងនិយាយអំពីគណនេយ្យភាពសាធារណៈរបស់មន្ត្រី វានៅជាទស្សនាទានថ្មីមួយនៅឡើយ ហើយទាំងមន្ត្រីទាំងប្រជាពលរដ្ឋអាចនៅមិនទាន់យល់ច្បាស់អំពីយន្តការនិងការអនុវត្តគណនេយ្យភាពនៅឡើយទេ។

មាត្រា៣៩នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ពលរដ្ឋកម្ពុជាមានសិទ្ធិ ប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម ឬរបស់បុគ្គលិកនៃអង្គការទាំងនោះក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន"។ ប្រជាពលរដ្ឋមានសិទ្ធិស្នើសុំឲ្យសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលខ្លួនបោះឆ្នោតជ្រើសរើស ពន្យល់អំពីការសម្រេចចិត្តណាមួយដែលពួកគេធ្វើ។ ប៉ុន្តែទស្សនាទាននេះនៅមិនទាន់មានប្រវត្តិយូរប៉ុន្មានទេក្នុងប្រទេសកម្ពុជា ហើយតាមជាក់ស្តែង ប្រជាពលរដ្ឋមិនទំនងជាបានអនុវត្តសិទ្ធិបែបនេះផង ដរាបណាមិនមានការអនុវត្តយន្តការរឹងមាំដែលផ្តល់អំណាចច្រើនឲ្យពួកគេ និងមិនធ្វើឲ្យពួកគេមានអារម្មណ៍ខ្លាចអារ។ យន្តការប្រកបដោយប្រសិទ្ធភាពមួយដែលអាចជួយប្រជាពលរដ្ឋក្នុងការដាក់បណ្តឹងរបស់ពួកគេមានសារៈសំខាន់ណាស់សម្រាប់លក្ខខណ្ឌវប្បធម៌ដូចនៅកម្ពុជា ដែលច្រើនតែឲ្យតម្លៃទៅលើឋានៈ ហើយដែលអ្នកភូមិច្រើនតែប្រកាន់ឥរិយាបថពិសេសលើសធម្មតាចំពោះអ្នកមានឋានៈខ្ពស់។

យន្តការគណនេយ្យភាពមានគោលការណ៍គន្លឹះចំនួនបីគឺ ៖ ការយល់ដឹង និងការអប់រំ ការបង្ការការប្រព្រឹត្តិមិនត្រឹមត្រូវ និង ការស៊ើបអង្កេត ការដាក់ទណ្ឌកម្ម និងការអនុវត្ត[3]។ វាមានសារៈសំខាន់ណាស់ សម្រាប់ដំណើរការប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាពនៃយន្តការបណ្តឹងទាំងនេះ ដែលប្រជាពលរដ្ឋត្រូវយល់ដឹងអំពីវិធីដាក់ពាក្យបណ្តឹង នរណាខ្លះដែលពួកគាត់ត្រូវប្តឹងទៅ និងយល់ដឹងអំពីនីតិវិធីផ្សេងៗដោយអាស្រ័យលើករណីបណ្តឹងនីមួយៗ ហើយយន្តការទាំងនេះត្រូវមានលក្ខណៈងាយស្រួលប្រើប្រាស់។ យន្តការទាំងនេះត្រូវតែរៀបចំ

[2] Eng, N. & Craig, D. (២០០៩). *គណនេយ្យភាព និងការគ្រប់គ្រងធនធានមនុស្សក្នុងក្របខ័ណ្ឌវិមជ្ឈការកម្ពុជា.* ឯកសារការងាររបស់ CDRI លេខ ៤០. (CDID, រាជធានីភ្នំពេញ, កម្ពុជា)

[3] Graham, P. (២០១០). របាយការណ៍ស្តាពរស្តីអំពីការពន្យាកិច្ចសន្យាសម្រាប់ការកសាងកូនសៀវភៅ និងការបណ្តុះបណ្តាលស្តីអំពីការអង្កេតពាក្យបណ្តឹងសម្រាប់ក្រុមការងារគណនេយ្យភាពដើម្បីបញ្ចូលសេចក្តីវាយតម្លៃរបស់ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិនិងខេត្ត និងយន្តការពាក្យបណ្តឹងរបស់ក្រុមនេះ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, រាជធានីភ្នំពេញ, កម្ពុជា)

ឡើងដើម្បីធានាបានថា ពាក្យបណ្តឹងត្រូវបានត្រួតពិនិត្យតាមកាលកំណត់ និងមានដំណើរការច្បាស់លាស់ បានទាន់ពេលវេលា ហើយអាជ្ញាធរត្រូវមានចំណាត់ការពិតប្រាកដលើបណ្តឹងនោះ និងប្រជាពលរដ្ឋត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចចិត្តណាមួយដែលបានធ្វើ។ នៅថ្នាក់ក្រោមជាតិ មានយន្តការបណ្តឹងសំខាន់ពីរគឺៈ ក្រុមការងារគណនេយ្យភាពខេត្ត និងប្រព័ន្ធអំប៊ុដស្មាន់ថ្នាក់ស្រុក។

## ២. ក្រុមការងារគណនេយ្យភាពខេត្ត និងថ្នាក់ជាតិ

ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD) យន្តការក្រុមការងារគណនេយ្យភាពខេត្ត(ក.គ.ខ) បង្កើតឡើងដើម្បីគាំទ្រដល់ការងារកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនគណនេយ្យភាពនៃការវិនិយោគសាធារណៈ។ យន្តការនេះផ្តល់ឲ្យសហគមន៍ជាតិ និងអន្តរជាតិ មើលឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិមានមធ្យោបាយដ៏គួរឲ្យទុកចិត្ត និងមានតម្លាភាព ដើម្បីធានាបានថាការវិនិយោគនៅថ្នាក់មូលដ្ឋាន គឺជាការគ្រប់គ្រងប្រកបដោយគណនេយ្យភាពស្របតាមគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ ក.គ.ខ បំពេញមុខងារដោយមានការគាំទ្រពីក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ(ក.គ.ជ)។អង្គភាពទាំងពីរនេះ មានសិទ្ធិស្នើដំណោះស្រាយសម្រាប់ករណីបណ្តឹង ប៉ុន្តែពុំមានអំណាចផ្លូវច្បាប់ទេ។ ក្រុមការងារគណនេយ្យភាពមានការទទួលខុសត្រូវ ដូចខាងក្រោម ៖

- ប្រមូល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ មិនចំគោលដៅ
- កំណត់ការប្រព្រឹត្តិខុស/កំហុសរបស់មន្ត្រីមូលដ្ឋាន ព្រមទាំងដាក់ទោសពិន័យ និង
- ពិនិត្យ តាមដាន វាយតម្លៃ និងផ្សព្វផ្សាយដំណោះស្រាយចំពោះករណីបណ្តឹងផ្សេងៗ[4]

ក.គ.ជ មានសមាសភាពមន្ត្រីមកពីបណ្តាក្រសួងក្នុងវិស័យសាធារណៈ រីឯ ក.គ.ខ មានសមាសភាពចម្រុះរវាងអ្នកតំណាងមកពីវិស័យសាធារណៈ និងវិស័យឯកជន។ សមាសភាពរបស់ ក.គ.ខ រួមមានអភិបាលខេត្ត អភិបាលរងខេត្ត តំណាងក្រសួងខ្មែរបណ្តោយ តំណាងឃុំ/សង្កាត់ និងតំណាងវិស័យឯកជន។ ក.គ.ខ មានកញ្ចប់ថវិកាផ្ទាល់ខ្លួនសម្រាប់ដោះស្រាយបណ្តឹងនានា ប៉ុន្តែថវិកានេះមានចំនួនតិច។ ក.គ.ជ មានតួនាទីគាំទ្រ ក.គ.ខ។ ក.គ.ជ មិនមានភារៈកិច្ចដោះស្រាយបណ្តឹងទេ ប៉ុន្តែវាមានភារៈកិច្ចផ្តល់ប្រឹក្សាយោបល់ និងការបណ្តុះបណ្តាល និងតាមដានអំពីវិធីនៃការដោះស្រាយបណ្តឹងនៅថ្នាក់ក្រោមជាតិ។

ប្រជាពលរដ្ឋក៏អាចដាក់បណ្តឹងទៅកាន់ ក.គ.ខ នៅកន្លែងខ្លួនយល់ថាមូលនិធិឃុំ/សង្កាត់(CSF) ត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ឬក៏នៅកន្លែងដែលពួកគាត់យល់ថា មានការរំលោភអំណាច ឬមានបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋាន ដែលធ្វើឲ្យប្រជាពលរដ្ឋពុំមានការពេញចិត្ត។ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯង ឬសរសេរពាក្យបណ្តឹងដាក់ក្នុងប្រអប់គណនេយ្យភាពទាំង២៥៤៥ ដែលមានដាក់នៅគ្រប់ទីតាំង និងគ្រប់កម្រិតតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា[5]។ ប្រអប់ពាក្យបណ្តឹងមានដាក់នៅតាមសាលាខេត្ត សាលាស្រុក និងសាលាឃុំ ព្រមទាំងនៅតាមអង្គការនានាដែលមានមូលដ្ឋានក្នុងសហគមន៍(CBOs)។ នៅតាមប្រអប់គណនេយ្យភាពនីមួយៗ មានដាក់ចែកប័ណ្ណផ្សព្វផ្សាយដែលមានលេខទំនាក់ទំនង

[4] Knowles, J.N. (២០០៧). របាយការណ៍ស្ថាពរស្តីអំពី ការវាយតម្លៃក្រុមការងារគណនេយ្យភាព. (គម្រោងវិនិយោគជនបទសម្រាប់អភិបាល កិច្ចមូលដ្ឋាន, NCDD)

[5] ព័ត៌មានទទួលបានពីការសម្ភាសន៍ជាមួយក្រុមការងារគណនេយ្យភាពជាតិ, NCDD. ៣១ សីហា ២០១២

លម្អិតរបស់សមាជិកម្នាក់ៗនៃក.គ.ខ ហើយប្រជាពលរដ្ឋក៏អាចប្រជាពលរដ្ឋក៏អាចទទួលព័ត៌មានតាមរយៈផ្ទាំងផ្សព្វផ្សាយ និងបណ្ដាញព័ត៌មាននានាផងដែរ។ ក្រៅពីការដាក់បណ្ដឹងតាមរយៈប្រអប់គណនេយ្យភាពនោះ ប្រជាពលរដ្ឋក៏អាចទំនាក់ទំនងទៅសមាជិក ក.គ.ខ តាមរយៈទូរស័ព្ទ ឬជួបផ្ទាល់បានដែរ។ ប្រអប់គណនេយ្យភាពត្រូវបានចាក់សោរសុវត្ថិភាព ដើម្បីជានាការសម្ងាត់នៃបណ្ដឹង[6]។

ការបើកប្រអប់គណនេយ្យភាពត្រូវបានធ្វើជារៀងរាល់ខែ ហើយរាល់ពាក្យបណ្ដឹងទាំងអស់នឹងត្រូវផ្ទេរទៅក្នុងស្រោមសំបុត្រមួយ ដែលនឹងត្រូវបញ្ជូនទៅឲ្យ ក.គ.ខ។ ពាក្យបណ្ដឹងនឹងត្រូវបានយកមកអាននៅក្នុងកិច្ចប្រជុំប្រចាំខែ។ ក្រោយមក ក.គ.ខ នឹងបើកការស៊ើបអង្កេតលើពាក្យបណ្ដឹងណា ដែលត្រូវបានចាត់ទុកថាជាបណ្ដឹងត្រឹមត្រូវ ឬបញ្ជូនបណ្ដឹងនោះទៅក្រសួងពាក់ព័ន្ធ ប្រសិនបើករណីបណ្ដឹងនោះហួសពីសមត្ថកិច្ចរបស់ខ្លួន។ ក.គ.ខ ត្រូវតែសិក្សានិងស៊ើបអង្កេតលើរាល់បណ្ដឹងដែលដាក់មកឲ្យខ្លួន។ ក.គ.ខ មិនដាក់ទោសពិន័យជនដែលជាប់អង្កេតដោយខ្លួនឯងទេ ប៉ុន្តែក្រុមនេះស្នើវិធានការណ៍ដែលគួរអនុវត្តន៍ ឬបញ្ជូនករណីបណ្ដឹងទៅអង្គភាពឬស្ថាប័នដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការណ៍ពិន័យ ឬក៏ដោះស្រាយករណីនោះទៅតាមច្បាប់ជាធរមាន។ ក្រុមគាំទ្រ ក.គ.ខ នឹងត្រូវបានប្រគល់ភារៈកិច្ចឲ្យពាំនាំសេចក្ដីសម្រេចចិត្តដែល ក.គ.ខ បានធ្វើ ជូនទៅអង្គភាពពាក់ព័ន្ធ ដែលមានរយៈពេល១៥ថ្ងៃ ដើម្បីធ្វើការសម្រេចចិត្តថាតើត្រូវដាក់ពិន័យឬទេ រួចត្រូវរាយការណ៍អំពីសេចក្ដីសម្រេចចិត្តរបស់ក្រសួងនោះត្រឡប់ទៅ ក.គ.ខ វិញ។ បន្ទាប់ពីការស៊ើបអង្កេត ការប្រកាសអំពីការដាក់ទណ្ឌកម្មត្រូវធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ[7]។ ក្រុមគាំទ្រ ត្រូវប្រមូលរបាយការណ៍ពីអ្នកដែលត្រូវបានចាត់តាំងឲ្យតាមដានលើសេចក្ដីសម្រេច បន្ទាប់មក ក.គ.ខ នឹងពិនិត្យ និងពិភាក្សាលើរបាយការណ៍នោះ។

នៅពេលដែលការស៊ើបអង្កេត មិនអាចរកឃើញភស្តុតាងនៃកំហុស ករណីបណ្ដឹងនោះអាចបញ្ជូនទៅប្រធានអង្គភាពដើម្បីកែលម្អនីតិវិធី ឬក៏ស្ដីបន្ទោស[8]។ ការផ្ដល់ព័ត៌មានឆ្លើយតបជូនម្ចាស់បណ្ដឹងគឺជាកិច្ចការសំខាន់ រីឯការឆ្លើយតបទៅថ្នាក់ស្រុក និងឃុំ អាចធ្វើទៅបានបន្ទាប់ពីមានការសម្រេចចិត្តឲ្យបើកការស៊ើបអង្កេត និងបន្ទាប់ពីមានការសម្រេចចិត្តដាក់ទោសពិន័យណាមួយ។ សមាជិករបស់ ក.គ.ខ ដែលជាប់ពាក់ព័ន្ធក្នុងករណីបណ្ដឹង ឬជាប់ពាក់ព័ន្ធក្នុងវិវាទនឹងមិនអាចចូលរួមក្នុងដំណើរដោះស្រាយបណ្ដឹងបានទេ។

ជារួម តួលេខបានបង្ហាញថា ចំនួនពាក្យបណ្ដឹងដែលបានដាក់ក្នុងប្រអប់គណនេយ្យភាពមានការកើនឡើង។ បើប្រៀបធៀបទៅក្នុងរយៈពេលពីរត្រីមាសដំបូងក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២ មានពាក្យបណ្ដឹងចំនួន ៤៧៦ ដែលចំនួននេះកើនឡើង៣៨% ដោយឆ្នាំចាស់មានចំនួនត្រឹមតែ ៣៤៦ ពាក្យបណ្ដឹងប៉ុណ្ណោះ។ ៦៥% នៃបណ្ដឹងទាំងនេះត្រូវបានស៊ើបអង្កេត និងធ្វើរបាយការណ៍ត្រឹមត្រូវ។ ៩៩%នៃបណ្ដឹងទាំងនេះ ត្រូវបានដាក់តាមរយៈប្រអប់គណនេយ្យភាព ដែលការណ៍នេះបង្ហាញថា ប្រជាពលរដ្ឋពេញចិត្តគោលការណ៍រក្សាការសម្ងាត់នៃនីតិវិធីបែបនេះ។ កន្លងមក ពាក្យបណ្ដឹងភាគច្រើនបំផុតក្នុងរយៈពេល៦ខែដើមឆ្នាំ២០១២ គឺពាក់ព័ន្ធទៅនឹងតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរនានាដែលធ្វើការងារនៅក្រោមរដ្ឋបាលមូលដ្ឋាន(៧០%) បន្ទាប់មកគឺពាក្យបណ្ដឹងពាក់ព័ន្ធទៅនឹងតួនាទី និងភារកិច្ចរបស់សមាជិក និងបុគ្គលិកក្រុមប្រឹក្សាឃុំ/សង្កាត់ (១៤%)[9]។ ព័ត៌មានលម្អិតអំពីបណ្ដឹងដែលដាក់តាមរយៈ ក.គ.ខ មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ក។

[6] Graham (២០១០)

[7] Graham (២០១០)

[8] Graham (២០១០)

[9] ព័ត៌មានទទួលបានពី *របាយការណ៍ត្រីមាសឆ្នាំ ២០១២ របស់ក្រុមការងារគណនេយ្យភាព*

យោងតាមការវាយតម្លៃលើរចនាសម្ព័ន្ធ ការទទួលខុសត្រូវ និងសមត្ថកិច្ចរបស់ ក.គ.ខ ដែលបានធ្វើក្នុងឆ្នាំ២០១០ ដោយអ្នកប្រឹក្សាយោបល់ឯករាជ្យតំណាងឲ្យ NCDD បានបង្ហាញថា សមិទ្ធិផលសំខាន់ៗនៃយន្តការ ក.គ.ខ រួមមាន[10] ៖

- ក្រុមការងារគណនេយ្យភាពខេត្តត្រូវបានបង្កើតដោយជោគជ័យ ហើយប្រជាពលរដ្ឋបានយល់ដឹង និងប្រើប្រាស់ប្រព័ន្ធនេះកាន់តែច្រើនឡើងៗ។ កិច្ចការនេះបានជួយលើកកម្ពស់ការយល់ដឹងអំពីគណនេយ្យភាពសាធារណៈ ទោះបីជានៅមិនទាន់បានពេញលេញក៏ដោយ។
- ប្រអប់គណនេយ្យភាពគឺជាវិធីដ៏ល្អមួយក្នុងការរក្សាការសម្ងាត់ អំពីអត្តសញ្ញាណប្រជាពលរដ្ឋដែលជាម្ចាស់បណ្តឹង ព្រោះនៅពេលដែលពួកគេប្តឹង ក្នុងនាមជាប្រជាពលរដ្ឋអាចមានការភ័យខ្លាចក្នុងក្នុងចុះហត្ថលេខាក្នុងនាមជាដើមបណ្តឹង។
- បញ្ហាពុករលួយ និងការប្រព្រឹត្តល្មើស និងការផ្តល់សេវារដ្ឋបាលខ្វះគុណភាព កំពុងត្រូវបានដោះស្រាយ ដោយសារវិធានការណ៍ការស៊ើបអង្កេតត្រូវបានអនុវត្ត ឯអ្នកប្រព្រឹត្តខុសត្រូវបានដាក់ទណ្ឌកម្ម និងទទួលពិន័យ។
- មានការផ្សព្វផ្សាយព័ត៌មានអំពីដំណោះស្រាយបណ្តឹងជាសាធារណៈ ទោះបីជានៅមិនទាន់យល់បានពេញលេញទាំងអស់គ្នាក៏ដោយ។

ប៉ុន្តែទន្ទឹមនឹងលទ្ធផលទាំងនេះ ក៏នៅមានបញ្ហាមួយចំនួនផងដែរ ៖

- នៅតែមានការភ័ណ្ឌច្រឡំអំពីអាណត្តិរបស់ក.គ.ខ។ ការណ៍នេះបង្ហាញឲ្យឃើញ ដោយយោងតាមចំនួនពាក្យបណ្តឹងដែលដាក់នៅតាមទីកន្លែងផ្សេងៗ។ ឧទាហរណ៍ កាលពីឆ្នាំ២០១០ នៅខេត្តស្ទឹងត្រែងទទួលបានបណ្តឹង ចំនួន៩៩ ក្នុងនោះ៨៨បណ្តឹងត្រូវបានសម្រេចថា "ជាបណ្តឹងត្រូវដោះស្រាយ" រីឯ១១បណ្តឹងទៀត ត្រូវបានចាត់ទុកថា "ជាបណ្តឹងមិនត្រូវដោះស្រាយ"។[11] ដោយឡែកនៅខេត្តក្រចេះ ក្នុងចំណោមបណ្តឹង១២២ មានតែ១៥ប៉ុណ្ណោះ ដែលត្រូវបានកំណត់ថា "ជាបណ្តឹងត្រូវដោះស្រាយ" និង ១០៧ ត្រូវបានចាត់ទុកថា"ជាបណ្តឹងមិនត្រូវដោះស្រាយ"។ ដោយសារតែចំនួនបណ្តឹងដែលបានដាក់មានចំនួនប្រហាក់ប្រហែលគ្នា ស្ថានភាពនេះបង្ហាញថាប្រហែលជាមានការបកស្រាយខុសៗគ្នា នៅតាមទីកន្លែងផ្សេងៗគ្នា អំពីអាណត្តិរបស់ ក.គ.ខ។[12]
- អនុវត្តការផ្សព្វផ្សាយព័ត៌មាន និងខ្លឹមសារលម្អិតនៃដំណោះស្រាយនៃបណ្តឹង គួរតែត្រូវបានលើកកម្ពស់។ នៅតំបន់មួយចំនួន ពុំមានប័ណ្ណព័ត៌មានដាក់ចែកនៅក្បែរប្រអប់គណនេយ្យភាពនោះទេ។ យោងតាមការស្ទាបស្ទង់មតិក្នុងឆ្នាំ២០០៩ បង្ហាញថាមានអ្នកឆ្លើយតែ១២%ប៉ុណ្ណោះ ដែលបង្ហាញថា ទទួលបានព័ត៌មានគ្រប់គ្រាន់។[13]
- ថវិកាវិភាជន៍សម្រាប់ប្រាក់បៀវត្សន៍ និងសម្ភារៈបរិក្ខារបស់ ក.គ.ខ មានចំនួនតិច។ កាលពីឆ្នាំ២០០៩ ក.គ.ខនីមួយៗ ទទួលបានប្រាក់តែ៦៣២$ប៉ុណ្ណោះ ហើយអ្នកឆ្លើយសំណួររបស់ក.គ.ខ

[10] Graham (២០១០)

[12] Graham (២០១០)

[13] Graham (២០១០)

យល់ថា ថវិកានេះប្រហែលជាមិនគ្រប់គ្រាន់សម្រាប់ឲ្យអ្នកស៊ើបអង្កេតធ្វើដំណើរទៅអង្កេតករណីបណ្តឹងនោះទេ។[14]

- ខ្វះការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងខេត្ត និងខេត្ត និងខ្វះការចែករំលែកបទពិសោធន៍ល្អឲ្យបានទៀងទាត់ និងគ្រប់គ្រាន់។[15]
- នៅតែខ្វះឯកសារស្រាវជ្រាវច្បាប់ សម្រាប់ជួយដល់ ក.គ.ខ និងអ្នកស៊ើបអង្កេតរបស់ ក.គ.ខ។ ម្យ៉ាងទៀតសម្ភារៈបរិក្ខាផ្សេងទៀតដូច ម៉ាស៊ីនកុំព្យូទ័រ និងឧបករណ៍ប្រាស្រ័យទាក់ទងក៏តែងតែខ្វះខាតជាញឹកញាប់ផងដែរ។[16]
- គួរតែមានការណែនាំ និងការបណ្តុះបណ្តាលបន្ថែមទៀតពីសំណាក់ ក.គ.ជ និងថ្នាក់លើ សម្រាប់ ក.គ.ខ។[17]
- ជានិច្ចកាលបណ្តឹងត្រូវបានដាក់មក ដោយសារប្រជាពលរដ្ឋមិនទាន់យល់អំពីនីតិវិធីដាក់លាក់នៃការគ្រប់គ្រងវិស័យធុរៈកិច្ច និងវិស័យសាធារណៈ ដោយពួកគាត់ត្រូវការការណែនាំបន្ថែមទៀតអំពីបញ្ហានេះ។ ដូច្នេះការអប់រំដល់ប្រជាពលរដ្ឋគឺជាកត្តាចាំបាច់ ដើម្បីឲ្យពួកគាត់យល់អំពីរបៀបប្រើប្រាស់ប្រអប់ពាក្យបណ្តឹងឲ្យមានប្រសិទ្ធភាព។ ការស្ទាប់ស្ទង់មតិក្នុងឆ្នាំ២០០៩ បង្ហាញថាមានប្រជាពលរដ្ឋដែលត្រូវបានសម្ភាសន៍តែ១៤%ប៉ុណ្ណោះ ដែលឆ្លើយថាពួកគាត់យល់ដឹងអំពីរបៀបដាក់ពាក្យបណ្តឹង។[18]
- ដំណើរការប្រមូល និងពិនិត្យពិច័យពាក្យបណ្តឹងប្រើរយៈពេលយូរពេក។ ករណីភាគច្រើនប្រើពេលតិចបំផុតបីសប្តាហ៍ ទម្រាំមានការស៊ើបអង្កេតចាប់ផ្តើម ដោយសារតែត្រូវឆ្លងកាត់នីតិវិធីនានា ប៉ុន្តែក៏ដោយសារ តែខេត្តខ្លះមានទំហំធំ ហើយត្រូវការរយៈពេលធ្វើដំណើរយូរ។ ប្រសិនបើបណ្តឹងត្រូវបានដាក់នៅក្រោយការប្រមូលប្រចាំខែនោះ វាអាចត្រូវរង់ចាំរយៈពេលប្រាំមួយសប្តាហ៍ទម្រាំដល់ពេលស៊ើបអង្កេត ហើយអាចប្រើពេលដល់បីខែទម្រាំដោះស្រាយចប់ ។ កត្តានេះ អាចនឹងធ្វើឲ្យប្រជាពលរដ្ឋបាត់បង់ជំនឿចិត្តចំពោះយន្តការនេះ។ ការបង្កើនការប្រមូលពាក្យបណ្តឹងឲ្យបានញឹកញាប់ ជាងមុនទំនងជាអាចដោះស្រាយបញ្ហាខាងលើបាន ក៏ប៉ុន្តែនៅក្នុងប្រព័ន្ធក.គ.ខ បច្ចុប្បន្នយើងមិនអាចធ្វើបែបនេះបានទេ។[19]
- ក្រុមការងារគណនេយ្យភាពខេត្តចាំបាច់ត្រូវមានសង្គតភាពជាងមុននៅពេលដែលពួកគេជួបប្រជុំគ្នា។ ៤០%នៃអ្នកឆ្លើយសំណួរចំពោះការស្ទាបស្ទង់មតិក្នុងឆ្នាំ២០០៩ បានឆ្លើយថា កិច្ចប្រជុំត្រូវបានធ្វើឡើងដោយពុំជាប់លាប់ឡើយ។ ទោះជាយ៉ាងណា អ្នកឆ្លើយសំណួរភាគច្រើន យល់ថាកិច្ចប្រជុំនេះ ពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់។[20]
- គណនេយ្យភាពបច្ចុប្បន្នគឺស្ថិតក្នុងសភាពមួយមិនទាន់ល្អប្រសើរនៅឡើយទេ នៅតាមទីកន្លែងមួយចំនួន ដែលកត្តានេះអាចបង្អាក់ប្រជាពលរដ្ឋពីការដាក់ពាក្យបណ្តឹងផ្សេងៗ[21]។

---

[14] Graham(២០១០)

[15] Graham(២០១០)

[16] Graham(២០១០)

[17] Graham(២០១០)

[18] Graham(២០១០)

[19] Graham(២០១០)

[20] Graham(២០១០)

[21] Graham(២០១០)

## ៣. ការិយាល័យច្រកចេញចូលតែមួយ(OWSO) និងយន្តការការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក(DO)

ការិយាល័យច្រកចេញចូលតែមួយ(OWSO) គឺជាគំនិតផ្តួចផ្តើមថ្មីមួយក្នុងការផ្តល់សេវានៅកម្ពុជា ដែលនាំឲ្យមានការផ្តល់សេវារដ្ឋបាលផ្សេងៗដល់ប្រជាពលរដ្ឋ និងធុរៈកិច្ចនៅទីកន្លែងតែមួយ ប្រកបដោយសេវាឆាប់រហ័ស និងមានតម្លាភាព។ ការិយាល័យច្រកចេញចូលតែមួយបានបង្កើតឡើងនៅថ្នាក់ស្រុកនៅក្នុងខេត្តចំនួន១៧។ នៅក្នុងការិយាល័យច្រកចេញចូលតែមួយ គឺមានការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក(DO)។ ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកត្រូវបានបង្កើតឡើង ក្រោមគម្រោងជំនួយរបស់សហគមអ៊ឺរ៉ុបនៅក្នុងស្រុកចំនួន២ នៃខេត្តសៀមរាប និងខេត្តបាត់ដំបង នៅក្នុងឆ្នាំ២០០៥-២០០៧។ ក្រោមគម្រោងអភិបាលកិច្ចល្អមូលដ្ឋានដែលផ្តល់ជំនួយដោយធនាគារពិភពលោក ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកថ្មីចំនួន៧ត្រូវបានសម្ពោធឲ្យប្រើប្រាស់ នៅខេត្តកណ្តាល កំពង់ធំ ព្រះសីហនុ បន្ទាយមានជ័យ ក្រចេះ កំពង់ចាម និងព្រៃវែង[22]។

ការិយាល័យប្រជាពលរដ្ឋ គឺជាអ្នកតំណាងប្រជាពលរដ្ឋដ៏អព្យាក្រឹត្យ ដែលបំពេញតួនាទីក្នុងការត្រួតពិនិត្យការអនុវត្តរបស់មន្ត្រីមូលដ្ឋាន និងលើកកម្ពស់គណនេយ្យភាព តម្លាភាព និងការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋាន។ ការិយាល័យប្រជាពលរដ្ឋស្រុក គឺមានអាណត្តិជាអ្នកតំណាងអព្យាក្រឹត្យរបស់ប្រជាពលរដ្ឋដែលស្វែងរកដំណោះស្រាយដែលអាចទទួលយកបានសម្រាប់ប្រជាពលរដ្ឋ និងធុរៈកិច្ច។ ភាពស្មុគស្មាញ ដែលកើនឡើងក្នុងបរិយាកាសសេដ្ឋកិច្ច និងសង្គម និងនៅក្នុងតំបន់ខ្លះដែលនៅតែបន្តមានកង្វះខាតនៃតម្លាភាពឲ្យបានពេញលេញ មានន័យថាប្រព័ន្ធអំប៊ុស្មាន់គឺកាន់តែមានភាពចាំបាច់នៅកម្ពុជា ដើម្បីលើកកម្ពស់ភាពជឿជាក់ និងការផ្សាភ្ជាប់រវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន និងដើម្បីជានានូវការគោរពច្បាប់។ តួនាទីរបស់ការិយាល័យប្រជាពលរដ្ឋស្រុកគឺ៖

- ត្រួតពិនិត្យ និងដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងសេវារបស់ការិយាល័យច្រកចេញចូលតែមួយ
- ផ្តល់ប្រឹក្សា និងខិតខំកំណត់ការប្រព្រឹត្តខុសរបស់មន្ត្រីសាធារណៈ និងដោះស្រាយពាក្យបណ្តឹងផ្សេងទៀតទាក់ទងនឹងរដ្ឋបាលថ្នាក់ស្រុក
- សម្រុះសម្រួលរវាងភាគីជម្លោះ ដើម្បីដោះស្រាយពាក្យបណ្តឹង និង
- កសាងទំនាក់ទំនងល្អរវាងវិស័យធុរៈកិច្ច អង្គការសង្គមស៊ីវិល និងរដ្ឋបាលមូលដ្ឋាន

ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកមានអំណាចក្នុងការស្វែងរកពលឯកសារពាក់ព័ន្ធ ដើម្បីដោះស្រាយពាក្យបណ្តឹង សម្របសម្រួលរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ និងបញ្ជូនអនុសាសន៍នានាជូនទៅអភិបាលស្រុក (ឬអភិបាលខេត្តប្រសិនបើពាក្យបណ្តឹងមានការពាក់ព័ន្ធទៅនឹងមុខងាររបស់អភិបាលស្រុក)។ ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកគឺត្រូវបានជ្រើសរើស និងមានការទទួលខុសត្រូវចំពោះគណៈកម្មាធិការមួយដែលជាតំណាងមកពីក្រុមប្រឹក្សាស្រុក សហគមន៍ធុរៈកិច្ច និងសង្គមស៊ីវិល។ ការិយាល័យប្រជាពលរដ្ឋ គឺជាអង្គភាពឯករាជ្យមួយ ហើយមន្ត្រីក្នុងការិយាល័យនេះគឺត្រូវជ្រើសរើសដោយគណៈកម្មាធិការបោះឆ្នោតមួយ ដែលរួមមានសមាសសភាពមកពីសមាជិកទាំងអស់នៃក្រុមប្រឹក្សាក្រុងឬស្រុក តំណាង៣រូបនៃសហគមន៍ធុរៈកិច្ចមូលដ្ឋាន

[22] ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ ល័ក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត

តំណាង៣រូបមកពីអង្គការសង្គមស៊ីវិលក្នុងស្រុកដែលបានចុះបញ្ជី ដំណើរការការងារនៅក្នុងមូលដ្ឋាននៃក្រុងឬស្រុកនោះ។ សមាជិកទាំងអស់នៃគណៈកម្មាធិការបោះឆ្នោត មានសិទ្ធិក្នុងការដាក់ឈ្មោះបេក្ខជន២រូបយ៉ាងច្រើន ដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតចូលជាមន្ត្រីការិយាល័យប្រជាពលរដ្ឋ[23]។ ក្នុងរយៈកាលកន្លងមកនេះ ការិយាល័យប្រជាពលរដ្ឋត្រូវបានមើលឃើញថាមានប្រសិទ្ធភាពនៅក្នុងការលើកកម្ពស់តម្លាភាព ការទប់ស្កាត់អំពើពុករលួយ និងការធានាពីដំណើរការដែលមានប្រសិទ្ធភាព និងតម្លាភាពរបស់ការិយាល័យច្រកចេញចូលតែមួយ។ អង្គភាពនេះបានជួយកសាងភាពទំនុកចិត្តរវាងរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋ ដែលការណ៍នេះអនុញ្ញាតឲ្យមានទីតាំងអព្យាក្រឹត្យមួយដែលបញ្ហានានារវាងប្រជាពលរដ្ឋ និង រដ្ឋបាលមូលដ្ឋានអាចត្រូវបានដោះស្រាយ[24]។ អព្យាក្រឹត្យភាព គឺជាទិដ្ឋភាពគន្លឹះនៃដំណើរការប្រព្រឹត្តិទៅរបស់ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងតំណាងឲ្យការច្នៃប្រឌិតដ៏សំខាន់នៅក្នុងយន្តការបណ្តឹងនៅប្រទេសកម្ពុជា។ លទ្ធភាពរបស់ពលរដ្ឋក្នុងការបញ្ចេញនូវក្តីកង្វល់ និងពាក្យបណ្តឹងរបស់ពួកគេដោយផ្ទាល់ទៅកាន់អ្នកតំណាងអព្យាក្រឹត និងជាប់ឆ្នោតអាចត្រូវបានគេមើលឃើញថាជាការផ្លាស់ប្តូរឆ្ពោះទៅរកយន្តការ ដែលដោះស្រាយបញ្ហានៃការមិនសូវទទួលបានព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងតម្លាភាពសាធារណៈ ដែលមានករណីជាច្រើនមិនបានផ្តល់ដល់ប្រជាពលរដ្ឋតាមរយៈរដ្ឋបាលមូលដ្ឋានរបស់ពួកគេ។ ការិយាល័យប្រជាពលរដ្ឋឯករាជ្យ ក៏តំណាងឱ្យជំហានមួយឆ្ពោះទៅរកអភិបាលកិច្ចកាន់តែល្អនៅប្រទេសកម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ យន្តការការិយាល័យប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ ប្រឈមនឹងបញ្ហាមួយចំនួនដូចជា ៖

- ពាក្យបណ្តឹងគឺមិនបានដាក់ត្រឹមត្រូវតាមវិស័យសមត្ថកិច្ចនោះទេ ការណ៍នេះបង្ហាញថាប្រជាពលរដ្ឋអាចមានការភ័ន្តច្រឡំអំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋ។ បើទោះបីជា ការិយាល័យប្រជាពលរដ្ឋស្រុកមានអាណត្តិក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងការិយាល័យច្រកចេញចូលតែមួយ យោងតាមការត្រួតពិនិត្យឡើងវិញនៃពាក្យបណ្តឹងរវាងឆ្នាំ២០០៦ និង២០០៩បានបង្ហាញថា មានតែពាក្យបណ្តឹងចំនួន២ប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជី និងបានដោះស្រាយ ខណៈពេលពាក្យបណ្តឹងផ្សេងទៀតដែលបានដាក់មកស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋស្រុក[25]។ ក្នុងឆ្នាំ២០១១ តិចជាង១០%នៃការឆ្លើយតបដែលបានទទួលដោយការិយាល័យប្រជាពលរដ្ឋស្រុក គឺជាពាក្យបណ្តឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋស្រុក[26]។ ពាក្យបណ្តឹងដែលបានទទួល ភាគច្រើនពាក់ព័ន្ធនឹងការមិនពេញចិត្តចំពោះការផ្តល់សេវា និងអ្នកផ្តល់សេវា (ដូចជាសាលាក្រុង និងមន្ទីរជំនាញ) ព្រមទាំងពាក្យបណ្តឹងអំពីសេវារបស់ការិយាល័យច្រកចេញចូលតែមួយនៅមានកម្រិត[27]។

---

[23] ព័ត៌មានទទួលបានពីបទបង្ហាញរបស់លោកចាន់ សុធា នាយកគម្រោង ការិយាល័យប្រជាពលរដ្ឋ

[24] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌(២០០៩)

[25] ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ ល័ក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត

[26] ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ លក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត

[27] ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ លក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យច្រកចេញចូល តែមួយ និងការិយាល័យប្រជាពលរដ្ឋ ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត

- បើទោះបីជាមានយុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមរយៈការផ្សព្វផ្សាយខិត្តប័ណ្ណ និងកម្មវិធី វិទ្យុ ក្តី ប្រជាពលរដ្ឋប្រហែលជាពុំទាន់បានដឹងពីការិយាល័យនេះទេ៖ យោងតាមការស្ទាបស្ទង់មតិ ឆ្នាំ ២០០៧ មានតែប្រជាជន៥%ប៉ុណ្ណោះបានដឹងអំពីការិយាល័យនេះ។
  - ក្នុងក្របខណ្ឌការិយាល័យប្រជាពលរដ្ឋស្រុក នៅមានកង្វះខាតអ្នកជំនាញអាជីព និងធនធានមានកម្រិត រួមមានធនធានមនុស្ស និងហិរញ្ញវត្ថុ
  - កង្វះខាតនៃភាពជឿជាក់រវាងប្រជាពលរដ្ឋ និងយន្តការការិយាល័យប្រជាពលរដ្ឋ បានបង្ហាញថាប្រជាពលរដ្ឋចង់បានការដាក់ពាក្យបណ្តឹងតាមរយៈប្រអប់គណនេយ្យភាព ជាជាងតាមរយៈការិយាល័យប្រជាពលរដ្ឋ[28]
  - ប្រជាពលរដ្ឋប្រហែលជាមិនហ៊ានដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យប្រជាពលរដ្ឋនោះទេ ដោយសារតែប្រជាពលរដ្ឋខ្លាចមានការអង្កេតពីមន្ត្រីនៅទីនោះ។ ពួកគាត់ប្រហែលជាយល់ថាការិយាល័យប្រជាពលរដ្ឋមិនអាចជួយពួកគាត់បានទេក្នុងជម្លោះជាមួយរដ្ឋបាលមូលដ្ឋាននោះ។
  - ពុំមានការបកប្រែដោយផ្ទាល់សម្រាប់ពាក្យ "អំប៊ុស្មាន់" ជាភាសាខ្មែរឡើយ ហើយមនុស្សជាច្រើនយល់ថាកត្តានេះធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ។ ពាក្យផ្សេងទៀតដែលអាចការពន្យល់ពាក្យនេះបានគឺមានដូចជា "ការិយាល័យទទួលពាក្យបណ្តឹង" ឬ "ការិយាល័យបម្រើប្រជាពលរដ្ឋ"។
  - ការិយាល័យប្រជាពលរដ្ឋបច្ចុប្បន្នមានតែនៅថ្នាក់ក្រុង/ស្រុកប៉ុណ្ណោះ។
  - ក្នុងករណីសិក្សាមួយនៅខេត្តបាត់ដំបង បញ្ហាខាងក្រោមត្រូវបានសម្គាល់ឃើញ៖ ការិយាល័យនេះមិនបានបង្ហាញច្បាស់លាស់ដល់ប្រជាពលរដ្ឋ និងមិនបានដាក់ផ្លាកសញ្ញាបង្ហាញឲ្យបានត្រឹមត្រូវនោះទេ[29]។

## ៤. វិធីសាស្ត្រនានាដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងបាន

### *ការដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅក្រុមប្រឹក្សាឃុំ/សង្កាត់*

មធ្យោបាយច្បាស់បំផុតសម្រាប់ប្រជាពលរដ្ឋក្នុងការបង្ហាញពីកង្វល់របស់ពួកគេអំពីបញ្ហាមូលដ្ឋាន គឺតាមរយៈការលើកឡើងពីការិយាល័យអ្នកតំណាងជាប់ឆ្នោតរបស់ពួកគេនៅក្រុមប្រឹក្សាឃុំ/សង្កាត់។ ប៉ុន្តែ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ជាញឹកញាប់ក៏បានខិតខំក្នុងការដោះស្រាយពាក្យបណ្តឹងលើបញ្ហាជាច្រើន ដែលភាគច្រើនគឺជាបណ្តឹងតូចៗរបស់ប្រជាពលរដ្ឋអំពីបញ្ហាដីធ្លី អំពើហឹង្សាក្នុងគ្រួសារ ជម្លោះការទទួលមរតក និងបញ្ហាការសងប្រាក់កម្ចី ជាដើម។

ជាធម្មតា អាជ្ញាធរមូលដ្ឋានដោះស្រាយតែពាក្យបណ្តឹងអំពីករណីរដ្ឋប្បវេណីប៉ុណ្ណោះ។ ពួកគេពុំមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអ្នកឈ្នះ ឬអ្នកចាញ់ក្នុងរឿងក្តីឡើយ ជាងនេះទៀត ពួកគេគ្រាន់តែធ្វើការសម្របសម្រួលដោយផ្តល់ជាមតិយោបល់ និងការណែនាំចំពោះភាគីនៃករណីជម្លោះតែប៉ុណ្ណោះ។ ប្រសិនបើឃុំ/សង្កាត់មិនអាចដោះស្រាយបញ្ហានោះបានដោយខ្លួនឯង ពួកគេអាចបញ្ជូនករណីនោះទៅថ្នាក់ស្រុក ឬទៅតុលាការ។ ក្រុមប្រឹក្សា ឃុំ/សង្កាត់មានអំណាចក្នុងការត្រួតពិនិត្យ គ្រប់គ្រង និងអន្តរាគមន៍ ដោយសហការ

[28] ការស្រាវជ្រាវរបស់អង្គការGTZស្តីពីប្រព័ន្ធអំប៊ុស្មាន់ នៅខេត្តបាត់ដំបង និងសៀមរាប ឆ្នាំ២០០៧

[29] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌(២០០៩)

ជាមួយនិងមន្ត្រីដែនដីថ្នាក់ស្រុក/ខណ្ឌ ឬខេត្ត/ក្រុង[30]។ ពាក្យបណ្តឹងត្រូវដាក់ជូនទៅក្រុមប្រឹក្សាជាលាយលក្ខ័អក្សរពីគ្រប់ភាគីជម្លោះ ហើយត្រូវស្ថិតនៅក្នុងយុត្តាធិការរបស់ក្រុមប្រឹក្សាជាអចិន្ត្រៃយ៍[31]។ ការត្រួតពិនិត្យ ការគ្រប់គ្រង និងការធ្វើអន្តរាគមក្នុងការដោះស្រាយបណ្តឹង រួមមានសកម្មភាពនានា ដូចជា ការស៊ើបអង្កេត និងការវាយតម្លៃ និងបណ្តឹងអាចត្រូវបានដោះស្រាយតាមរយៈការចេញនូវការណែនាំជាលាយលក្ខ័អក្សរទៅក្រុមប្រឹក្សាឃុំ/សង្កាត់ឲ្យអនុវត្តន៍ភារកិច្ចដែលតម្រូវដោយច្បាប់[32]។

ដើម្បីដោះស្រាយជម្លោះឲ្យបានសមស្រប សមាជិកក្រុមប្រឹក្សាត្រូវមានពេលវេលាដើម្បីចុះពិនិត្យតាមភូមិនានាដោយទៀតទាត់ ដែលជានិច្ចកាលតែងតែជួបការលំបាកដោយសារចម្ងាយផ្លូវក្នុងការធ្វើដំណើរមានសភាពឆ្ងាយ រីឯថវិកាអនុវត្តមានចំនួនតិចតួច។ ពេលខ្លះប្រជាពលរដ្ឋអាចរារែកក្នុងការទៅរកសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយសារពួកគេអាចយល់ថា លុះត្រាតែមានបណ្តាញភូមិក្នុងការផ្តល់ព័ត៌មាន ឬបណ្តឹងដែលកើតឡើងក្នុងភូមិ ដែលមានការិយាល័យក្រុមប្រឹក្សាឃុំ/សង្កាត់តាំងនៅ បើមិនដូច្នោះទេវាពិតជាលំបាកណាស់សម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងការដោះស្រាយបញ្ហាដែលកំពុងកើតមានឡើងក្នុងភូមិឲ្យបានសមស្រប[33]។

ការស្ទាបស្ទង់មតិដែលធ្វើឡើងដោយCDRI ក្នុងឆ្នាំ២០១១ បង្ហាញថា ជារួមការដោះស្រាយបណ្តឹងមានលក្ខណៈល្អប្រសើរគួរជាទីកត់សម្គាល់ បើទោះបីជាមានបញ្ហាខ្លះៗដូចរៀបរាប់ខាងលើក៏ដោយ។ នៅពេលដែលប្រជាពលរដ្ឋ ត្រូវបានចោទសួរអំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការដោះស្រាយពាក្យបណ្តឹង ៨១%បានបង្ហាញថាពួកគេបានទទួលជោគជ័យក្នុងការដោះស្រាយបញ្ហាជម្លោះនៅក្នុងកម្រិតថ្នាក់ភូមិ ដែលចំនួននេះកើនឡើងពី៥៥%នៅឆ្នាំ២០០៥ ៩១%បានបង្ហាញថាពាក្យបណ្តឹងត្រូវបានដោះស្រាយយ៉ាងយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ និង៩៩%បង្ហាញថាពួកគេអាចទៅរកក្រុមប្រឹក្សាឃុំ/សង្កាត់បាន ប្រសិនបើពួកគេមានបញ្ហា ដែលទាំងនេះបង្ហាញអំពីទំនុកចិត្តចំពោះសេចក្តីសម្រេចនៃពាក្យបណ្តឹង ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវបានលើកកម្ពស់យ៉ាងខ្លាំង និងក៏បានបង្ហាញថាកំណែទម្រង់វិមជ្ឈការបានទទួលជោគជ័យក្នុងការដោះស្រាយជម្លោះនៅក្នុងកម្រិតមូលដ្ឋាន និងបានកាត់បន្ថយគម្លាតរវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋផងដែរ[34]។

## *ពាក្យបណ្តឹងពាក់ព័ន្ធនឹងបញ្ហាដីធ្លី*

ក្នុងឆ្នាំ២០០៦ អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី(NALCR)ត្រូវបានបង្កើតឡើង ហើយនៅចុងឆ្នាំ២០០៨ ពាក្យបណ្តឹងចំនួន១៥០០ករណីបានចុះបញ្ជីជាមួយអាជ្ញាធរនេះ។ អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លីទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងបញ្ហាដីធ្លីពីប្រជាពលរដ្ឋ និងបញ្ជូនពាក្យបណ្តឹងទាំងនោះបន្តទៅការិយាល័យ និងក្រសួងពាក់ព័ន្ធ។ អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លីមានតួនាទីសម្របសម្រួលរាល់ជម្លោះដីធ្លី ហើយអគ្គ-លេខាធិការនៃអាជ្ញាធរនេះអាចធ្វើការស៊ើបអង្កេត និងធ្វើអធិការកិច្ចតាមដានពាក្យបណ្តឹង និងផ្អាកដំណើរការ

[30] ព្រះរាជក្រមលេខ០៣០១/០៥ ជំពូក៥ មាត្រា៥៣។ លើសពីនេះ មាត្រា៤៩ នៃរាជក្រមលេខ០៣០១/០៥បង្ហាញថា "សេចក្តីសម្រេច[នៃបណ្តឹង] របស់ឃុំ/សង្កាត់ត្រូវចាត់ទុកថាមានប្រសិទ្ធភាពអនុវត្តន៍នៅក្នុងដែនដីរបស់ខ្លួនប៉ុណ្ណោះ។ សេចក្តីសម្រេចរបស់ឃុំ/សង្កាត់មួយ មិនត្រូវផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ រាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីប្រកាស ហើយឧបករណ៍គតិយុត្តិពាក់ព័ន្ធផ្សេងទៀតត្រូវចាត់ទុកជាមោឃៈ។

[31] ព្រះរាជក្រមលេខ០៥០៨/០១៧ ផ្នែក៦ មាត្រា៩១

[32] ព្រះរាជក្រមលេខ០៣០១/០៥ ជំពូក៥ មាត្រា៥៥

[33] Mansfield, C. និង Macleod, K. (២០០៤) ក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិល (អង្គការPact Cambodia ភ្នំពេញ កម្ពុជា)

[34] Ojendal, J. និង Sedara, K. (២០១១) ការធ្វើឲ្យមានប្រជាធិបតេយ្យពិតប្រាកដនៅកម្ពុជា? ការត្រួតពិនិត្យដោយសម្អាងលើបទពិសោធន៍នៃ សក្តានុពលនៃកំណែទម្រង់វិមជ្ឈការ (ICLD- មជ្ឈមណ្ឌលអន្តរជាតិស៊ុីសដើម្បីប្រជាធិបតេយ្យមូលដ្ឋាន)

ណាមួយនៅលើដីដែលមានជម្លោះនោះ។ មានភស្តុតាងតិចតួចណាស់ដែលបានបង្ហាញថា តើពាក្យបណ្តឹងត្រូវបានដោះស្រាយដោយសមស្របឬទេ ឬថាតើពាក្យបណ្តឹងប្រភេទណាខ្លះដែលត្រូវបានដោះស្រាយ ។ល។

### *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) និងក្រសួងផ្សេងៗ*

ការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចគឺជានាគណនេយ្យភាព និងតម្លាភាពនៃក្រសួង និងស្ថាប័នផ្សេងៗ។ អគ្គនាយកដ្ឋានអធិការកិច្ចមានសមត្ថកិច្ចពេញលេញក្នុងការស៊ើបអង្កេត និងការធ្វើអធិការកិច្ច និងការសម្របសម្រួលពាក្យបណ្តឹងចំពោះរដ្ឋបាលមូលដ្ឋាន។ នាយកដ្ឋានទទួលពាក្យបណ្តឹងទទួលខុសត្រូវរាល់ពាក្យបណ្តឹងចំពោះស្ថាប័នសាធារណៈ និងខិតខំស៊ើបអង្កេត និងដោះស្រាយពាក្យបណ្តឹងទាំងនោះ ចងក្រងជាឯកសារដាក់ជូននាយករដ្ឋមន្ត្រីដើម្បីធ្វើការសម្រេចចិត្តចុងក្រោយ។ ករណីភាគច្រើនពាក់ព័ន្ធនឹងបញ្ហាដីធ្លី។ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យមើលការអនុវត្តរបស់ស្ថាប័នរដ្ឋ ជាពិសេសពាក់ព័ន្ធនឹងការចំណាយ។

ជាមួយគ្នានេះ នៅតាមក្រសួងនានាក៏មាននាយកដ្ឋានពាក្យបណ្តឹង/អធិការកិច្ចផ្ទៃក្នុងផងដែរ។ ការដោះស្រាយពាក្យបណ្តឹងផ្ទៃក្នុងជាទូទៅត្រូវអនុវត្តន៍តាមនីតិវិធីដូចគ្នាៈ ពាក្យបណ្តឹងត្រូវពិនិត្យជាដំបូងដោយនាយកដ្ឋានអធិការកិច្ច បន្ទាប់មកសវនាការនឹងត្រូវធ្វើឡើងរវាងភាគីនៃពាក្យបណ្តឹង បន្ទាប់មកទៀតនាយកដ្ឋាននឹងប្រកាសអំពីការបង្គាប់ដែលសម្រេចចុងក្រោយដោយរដ្ឋមន្ត្រី។ ក្នុងករណីដែលករណីបណ្តឹងមានភាពស្មុគស្មាញ និងពិបាកក្នុងការដោះស្រាយ ក្រុមការងារមួយនឹងត្រូវបង្កើតឡើងដើម្បីធ្វើការស៊ើបអង្កេត។ នាយកដ្ឋានទាំងនេះក៏មានបញ្ហាមួយចំនួនផងដែរ រួមមានកង្វះខាតព័ត៌មានសាធារណៈ និងដំណើរការជាលក្ខណៈប្រព័ន្ធក្នុងការផ្ទេរព័ត៌មានអំពីការងារដែលការិយាល័យនោះទទួលបន្ទុក និងកង្វះខាតស្ថិតិគ្រប់គ្រាន់ស្តីពីអំពីប្រភេទនៃពាក្យបណ្តឹងដែលបានទទួល និងដំណោះស្រាយរបស់ពួកគេ។

### *បណ្តឹងពាក់ព័ន្ធនឹងបញ្ហាធុរកិច្ច*

នៅក្រសួងពាណិជ្ជកម្មក៏មានការិយាល័យទទួលពាក្យបណ្តឹងមួយ(ការិយាល័យដោះស្រាយវិវាទ) ដែលអាចប្រើប្រាស់សម្រាប់ធុរជនដែលមិនឯកភាពចំពោះសេចក្តីសម្រេចរបស់ក្រសួង។ ប៉ុន្តែ មានការបង្ហាញថាការិយាល័យនេះមិនត្រូវបានអនុវត្តឲ្យបានទូលំទូលាយនោះទេ ពិបាកក្នុងការកំណត់ទីតាំង ហើយមកទល់ពេលនេះការិយាល័យ ហើយក៏មិនទាន់បានចេញបទបញ្ញត្តិណាមួយច្បាស់លាស់នៅឡើយទេ ពាក់ព័ន្ធនឹងការដោះស្រាយវិវាទ[35]។ ធុរជនក៏អាចដាក់ពាក្យបណ្តឹងទៅកាន់ក្រសួងពាក់ព័ន្ធ ដែលទទួលខុសត្រូវលើការចេញអាជ្ញាប័ណ្ណ ហើយបន្ទាប់មកគឺដោះស្រាយតាមនីតិវិធីស្រដៀងគ្នាដូចពាក្យបណ្តឹងធម្មតា ដែលប្តឹងក្រសួងផ្សេងៗ ឬអាចទូរស័ព្ទទៅកាន់បណ្តាញលេខពិសេសសម្រាប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងធុរកិច្ច។ ការធ្វើបែបនេះអនុញ្ញាតឲ្យពួកគេអាចដាក់ពាក្យបណ្តឹងបានកាន់តែឆាប់រហ័ស និងដោយពុំចាំបាច់រង់ចាំយូរ ឬឆ្លងនីតិវិធីរដ្ឋបាល ហើយបន្ទាប់មកពាក្យបណ្តឹងត្រូវបានបញ្ជូនបន្តទៅកាន់ការិយាល័យពាក់ព័ន្ធ។

[35] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### *អង្គការសង្គមស៊ីវិល*

អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អាចដើរតួនាទីយ៉ាងសំខាន់លើវិស័យមួយចំនួន និងជួយដល់ការដោះស្រាយវិវាទលើបញ្ហាផ្សេងៗដូចជា៖ ការទាមទារដីធ្លី អំពើហឹង្សាក្នុងគ្រួសារ ជម្លោះការទទួលមរតក និងការសងប្រាក់ឥណទាន។ ពួកគេអាចបង្កើតជាបណ្តាញរវាងដៃគូអង្គការក្រៅរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ/សង្កាត់ ព្រមទាំងជួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ឲ្យផ្សាភ្ជាប់បណ្តាញជាមួយគ្នា ដើម្បីស្វែងយល់អំពីបទពិសោធន៍នៃការអនុវត្តការងារកន្លងមកលើវិស័យផ្សេងៗ និងលើកកម្ពស់ដល់លំហូរព័ត៌មានរវាងអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិល ក៏អាចជួយដល់ការជូនដំណឹងដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងប្រជាពលរដ្ឋ ជ្រាបអំពីយន្តការផ្លូវការនានាក្នុងការដាក់ពាក្យបណ្តឹង អំពីច្បាប់ និងវិធីសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាផ្សេងៗ។ ពួកគេអាចផ្តល់ការប្រឹក្សាយោបល់ដល់ប្រជាពលរដ្ឋ និងតាមដានអំពីដំណើរការនៃបណ្តឹង និងករណីផ្សេងៗដែលស្ថិតក្រោមការត្រួតពិនិត្យ[36]។

អង្គការសង្គមស៊ីវិល ដូចជា អង្គការលីកាដូ មានបេសកកម្មការងារផ្តល់ការណែនាំអំពីនីតិវិធីនៃបណ្តឹង សំដៅផ្តល់ប្រឹក្សាយោបល់អំពីនីតិវិធីនៃការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរពាក់ព័ន្ធ។ ប៉ុន្តែ ប្រសិនបើមានករណីមួយចំនួនពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់ពួកគេលើបញ្ហាសិទ្ធិមនុស្ស ពួកគេអាចជួយដល់ប្រជាពលរដ្ឋតាមរយៈការផ្តល់ប្រឹក្សាយោបល់អំពីនីតិវិធីនៃការដាក់ពាក្យបណ្តឹងតាមនីតិវិធីផ្លូវច្បាប់របស់តុលាការ និងអាចជួយផ្តល់ជូនមេធាវីដើម្បីជួយលើដំណើរការនៃការដោះស្រាយបណ្តឹងនោះ។ រីឯអង្គការអាដហុក មានបេសកកម្មការងារលើការជួយដល់ការដោះស្រាយបណ្តឹង តាមរយៈការរៀបចំការស៊ើបអង្កេតដើម្បីប្រមូលភស្តុតាង និងបន្ទាប់មកធ្វើអន្តរាគមន៍ទៅក្រសួង ឬស្ថាប័នពាក់ព័ន្ធ សម្រាប់ករណីណាដែលស្ថិតក្នុងវិស័យការងាររបស់អង្គការអាដហុក។ ក្រៅពីនេះ អង្គការអាដហុកក៏ផ្តល់ជូនប្រជាពលរដ្ឋនូវការប្រឹក្សាយោបល់ និងអនុញ្ញាតឲ្យពួកគេអាចពិគ្រោះយោបល់ជាមួយបុគ្គលិករបស់អង្គការអាដហុកស្តីពីវិធីសាស្ត្រក្នុងការធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យករណីបណ្តឹងរបស់ពួកគេអាចដំណើរការទៅបាន។ ពួកគេក៏អាចជួយផ្តល់ការទំនាក់ទំនងជាមួយមេធាវី និងផ្តល់សេវាដល់ទីកន្លែងដល់ជនរងគ្រោះដោយឥតគិតថ្លៃ។

ការិយាល័យឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ទទួលនូវសំណួរ និងបណ្តឹងជាច្រើន ព្រមទាំងសំណើសុំការប្រឹក្សាច្បាប់ និងជំនួយនានានៅក្នុងវិវាទទាំងឡាយ។ បណ្តឹងភាគច្រើនពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លី អំពើហឹង្សាក្នុងគ្រួសារ ស្ថានភាពនៅក្នុងពន្ធធនាគារ និងការរំលោភសិទ្ធិមនុស្សផ្សេងៗ។ OHCHR បានផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋបានជ្រាប អំពីទីកន្លែងដែលពួកគេអាចស្វែងរកការដោះស្រាយសម្រាប់បណ្តឹងនានា និងការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលដែលដោះស្រាយលើបញ្ហាផ្សេងៗ។ តំណាងរបស់ការិយាល័យឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស យល់ថាប្រជាពលរដ្ឋពុំមានភាពជឿជាក់លើយន្តការបណ្តឹងណាផ្សេងទេ ហេតុដូច្នេះហើយទើបប្រជាពលរដ្ឋងាកមករកអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗនៅពេលដែលពួកគេដាក់ពាក្យបណ្តឹង[37]។

---

[36] Ayres, D. និង Macleod (ឆ្នាំ២០០៤)។ សៀវភៅស្តីពីភាពជាដៃគូ។ (អង្គការ Pact Cambodia ភ្នំពេញ ប្រទេសកម្ពុជា)

[37] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ឆ្នាំ២០០៩)

## ៥. តួនាទីរបស់សភាក្នុងការដោះស្រាយពាក្យបណ្តឹងរបស់ម្ចាស់ឆ្នោត

សភាដើរតួនាទីមួយដ៏សំខាន់ក្នុងការជួយដល់រដ្ឋាភិបាល ដើម្បីធ្វើការត្រួតពិនិត្យមើលលើការអនុវត្ត របស់បណ្តាក្រសួង ឬស្ថាប័នរបស់រដ្ឋាភិបាល សំដៅធានាឲ្យបាននូវគណនេយ្យភាព និងតម្លាភាពដើម្បីជួយ ដល់ប្រជាជន។ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច គឺជាមធ្យោបាយមួយ ដែលសភា អាចធ្វើការទំនាក់ទំនងសម្រាប់ការដោះស្រាយបណ្តឹង ដោយសារតែនេះគឺជាអង្គភាពរបស់រដ្ឋាភិបាលដែលមាន ភារកិច្ចដោះស្រាយបណ្តឹងនានា និងមានសិទ្ធិអំណាចពេញលេញក្រោមការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋាន អធិការកិច្ចដើម្បីអង្កេត និងសម្របសម្រួលបណ្តឹងតវ៉ាទៅនឹងអង្គភាពរដ្ឋបាលដែលប្តឹងដោយប្រជាពលរដ្ឋ[38]។

សភាក៏អាចធានាបាននូវគណនេយ្យភាពរបស់អាជ្ញាធរសាធារណៈ តាមរយៈការបំពេញមុខងារ តំណាងរបស់ខ្លួន។ វិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI) វាយតម្លៃថាសកម្មភាពជាតំណាងដែលអនុវត្តដោយ សមាជិកសភា បានដោះស្រាយនូវបញ្ហាអាទិភាពជាច្រើនរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។ តាមរយៈកិច្ច ពិគ្រោះយោបល់ទាំងនេះ សមាជិកសភាបានបញ្ជូនរបាយការណ៍ដើម្បីត្រៀមខ្លួនក្នុងការស្វែងរកដំណោះស្រាយ លើបញ្ហានានាដែលបានលើកឡើង។ NDI បានសង្កេតឃើញថានេះជាការងារអនុវត្តទៅបានយ៉ាងជោគជ័យ ហើយសមាជិកសភា បានបំពេញការងារតាមដានលើបណ្តឹងដែលបានលើកឡើងដោយប្រជាពលរដ្ឋនៅថ្នាក់ មូលដ្ឋាន តាមរយៈរបាយការណ៍ចុះមូលដ្ឋាន ឬលិខិតជាលាយល័ក្ខអក្សរជូនទៅស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ហើយក៏មានករណីជាក់ស្តែងខ្លះ សមាជិកសភាបានធ្វើអន្តរាគមន៍ដោយផ្ទាល់ និងបានជួបជាមួយអាជ្ញាធរ មូលដ្ឋានដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាវិវាទនោះដោយផ្ទាល់តែម្តង។

## ៦. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

គួរកត់សំគាល់ដែរថាយន្តការទទួលពាក្យបណ្តឹងភាគច្រើន-ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុម ការងារគណនេយ្យភាពខេត្ត- គឺមានសភាពថ្មីនៅឡើយ និងនៅមិនទាន់បានការទទួលស្គាល់ពីសំណាក់ប្រជា ពលរដ្ឋនៅឡើយទេ។ ភាគច្រើនត្រូវបានបង្កើតឡើងនៅចុងទសវត្សឆ្នាំ២០០០ ហើយនៅមិនទាន់បានបំពេញ ការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពពេញលេញនៅឡើយទេ។ ប៉ុន្តែ យន្តការទាំងនេះតំណាងឲ្យការវិវត្តន៍មួយ យ៉ាងសំខាន់ឆ្ពោះទៅរកគណនេយ្យភាពកាន់តែប្រសើរឡើងនៅគ្រប់កម្រិត និងបង្ហាញថារដ្ឋាភិបាលបានកំពុង ខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាឆ្ពោះទៅរកតម្លាភាពកាន់តែទូលំទូលាយ និងដើម្បីផ្តល់ជូនប្រជាពលរដ្ឋនូវលទ្ធភាព ដើម្បីត្រួតពិនិត្យមើលលើការធ្វើសេចក្តីសម្រេចសំខាន់ៗដែលធ្វើឡើងដោយរដ្ឋបាលសាធារណៈ។ បើទោះបីជា មានការបញ្ជាក់ថាការទំនាក់ទំនងក្រុមប្រឹក្សាឃុំសង្កាត់តាមរយៈអ្នកតំណាងប្រចាំភូមិ នៅតែជាវិធីដ៏ពេញនិយម និងទាន់ពេលវេលា ដែលប្រជាជននិយមប្រើពេលដាក់ពាក្យបណ្តឹងក៏ដោយ ក៏យន្តការផ្លូវការនានាអាចកសាង បាននូវបញ្ហាទំនុកចិត្ត ធនធាន សមត្ថភាព និងនីតិវិធីផ្សេងៗ ដើម្បីឱ្យកាន់តែមានប្រសិទ្ធិភាពពេញលេញ។

ប្រហែលជាអាចមានតម្រូវការសម្រាប់អាជ្ញាធរជាតិដើម្បីគណនេយ្យភាពទូទៅមួយ។ ពាក្យបណ្តឹង ជាច្រើនបានបញ្ជូនដោយផ្ទាល់មកក្រុមការងារគណនេយ្យភាពខេត្ត ប្រហាក់ប្រហែលទៅនឹងបណ្តឹងដែលបាន ដាក់ទៅអង្គការនានា ដែលមានការទទួលខុសត្រូវដើម្បីដោះស្រាយបញ្ហានានារវាងសាធារណជន និងអាជ្ញាធរ ដែលនេះគឺជាកិច្ចខិតខំប្រឹងប្រែងមួយដែលទទួលបានការសម្របសម្រួលកាន់តែប្រសើរឡើង។ កត្តានេះនឹងផ្តល់

[38] ការសិក្សាបឋមស្តីពីប្រព័ន្ធអំប៊ូស្មាន់ និងការទទួលពាក្យបណ្តឹងនៅក្នុងប្រទេសកម្ពុជា(ឆ្នាំ២០០៩) ដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធ យុត្តិធម៌

នូវការផ្សារភ្ជាប់ទៅនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីគណនេយ្យភាព និងធានាបានថាអាជ្ញាធរនានាមានធនធានគ្រប់គ្រាន់ដែលពួកគេត្រូវការ[39]។

កត្តានេះក៏ឆ្លើយតបផងដែរទៅនឹងបញ្ហាមួយ ដែលពាក់ព័ន្ធទៅនឹងតួនាទីស្មួនគ្នារវាងការិយាល័យប្រជាពលរដ្ឋស្រុក និង ក.គ.ឧ។ បច្ចុប្បន្ននេះ មានបណ្តឹងជាច្រើនប្រភេទដែលបានប្តឹងមក បង្ហាញថាអាចមានភាពភ័ន្តច្រឡំលើភារកិច្ចរបស់ពួកគេ។ បញ្ហាទាំងអស់នេះអាចត្រូវបានដោះស្រាយ ប្រសិនបើយើងអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោមនេះ ៖

- វិធីសាស្ត្រក្នុងការបង្កើតប្រព័ន្ធរាយការណ៍ ដែលអាចឲ្យតួនាទីទាំងទ្វេររបស់ការិយាល័យប្រជាពលរដ្ឋស្រុកក្នុងនាមជាអាជ្ញាកណ្តាលឯករាជ្យនៃពាក្យបណ្តឹងរដ្ឋបាល និងបុគ្គលដែលបានជាប់ឆ្នោតទទួលខុសត្រូវចំពោះគណៈកម្មាធិការបោះឆ្នោត ដែលបានកំណត់ដោយក្រុមប្រឹក្សាស្រុក/ក្រុង
- តើទិដ្ឋភាពនៃអាណត្តិបែបណាដែអាចត្រូវបានដាក់បញ្ចូលគ្នាបាន ហើយទិដ្ឋភាពបែបណាដែលគួរត្រូវបានរក្សាទុកដាច់ដោយឡែក។ វាគួរតែមានការបែងចែកឲ្យបានច្បាស់លាស់នៃកម្លាំងពលកម្ម ឬយន្តការនីមួយៗគួរតែត្រូវបានបង្កើតឡើងទៅតាមប្រភេទនៃពាក្យបណ្តឹងដោយផ្អែកលើសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ពាក្យបណ្តឹងដែលតម្រូវឱ្យមានឯករាជ្យភាព និងអព្យាក្រឹតភាពត្រូវបានដោះស្រាយដ៏ល្អបំផុត តាមរយៈការស្រមុះស្រម្រួលដោយការិយាល័យប្រជាពលរដ្ឋស្រុក រីឯពាក្យបណ្តឹងដែលមានលក្ខណៈបច្ចេកទេសច្រើន គួរតែដោះស្រាយតាមរយៈ ក.គ.ឧ
- បញ្ហាឯករាជ្យភាព ជាពិសេសធ្វើយ៉ាងដូចម្តេចដើម្បីឲ្យមានតុល្យភាពជាក់ស្តែង ដែលធ្វើឲ្យការិយាល័យប្រជាពលរដ្ឋស្រុកមានឯករាជ្យភាព ប៉ុន្តែមានគណនេយ្យភាពចំពោះអាជ្ញាធរមូលដ្ឋាន បើទោះបីជា ក.គ.ឧ នៅតែមានសមាសភាពដែលជាមន្ត្រីអាជ្ញាធរមូលដ្ឋាន។ វាជាមានសារៈសំខាន់ណាស់ ដែលការផ្សារភ្ជាប់បន្ថែមទៀតនៃ ក.គ.ឧ និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើងដើម្បីពង្រឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៃ ក.គ.ឧ ដល់ថ្នាក់មូលដ្ឋាន និងប្រជាពលរដ្ឋ។ វិធីសាស្ត្របែបនេះ គួរតែត្រូវបានឈានឆ្ពោះដល់ការផ្សារភ្ជាប់ជាមួយគ្នារវាង ក.គ.ឧ និងក្រុមប្រឹក្សាឃុំក្នុងការដោះស្រាយពាក្យបណ្តឹងដែលស្ថិតនៅក្រោមអាណត្តិរបស់ពួកគេ
- ធ្វើយ៉ាងដូចម្តេចដើម្បីដោះស្រាយភាពខុសគ្នានៅទូទាំងប្រទេសរវាងយន្តការទាំងពីរនេះ[40]។

## អនុសាសន៍ផ្សេងៗរួមមាន ៖

- ព័ត៌មានជាច្រើនទៀត ចាំបាច់ត្រូវផ្តល់ជូនប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ ក.គ.ឧ និងការិយាល័យប្រជាពលរដ្ឋស្រុក ដោយសារតែនាពេលបច្ចុប្បន្ននេះ មានពាក្យបណ្តឹងជាច្រើនដែល

[39] Graham (ឆ្នាំ២០១០)

[40]ការិយាល័យប្រជាពលរដ្ឋស្រុកមានសកម្មភាពតែនៅក្នុងក្រុងចំនួន១៧តែប៉ុណ្ណោះ (ក្នុងចំណោមស្រុក/ក្រុង/ខណ្ឌទាំង១៩៥) រីឯក្រុមការងារគណនេយ្យភាពខេត្តមានសកម្មភាពនៅគ្រប់ខេត្តទាំង២៣ និងរាជធានី។ ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ លក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យ ច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត

បានបញ្ជូនមកស្ថាប័នទាំងពីរនេះ ស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ពួកគេទេ។ ប្រជាពលរដ្ឋ គួរដឹងថាមានអាជ្ញាធរផ្សេងៗទៀតដែលអាចដាក់ពាក្យបណ្តឹងលើបញ្ហាផ្សេងៗ ដូចជាភាពមិនប្រក្រតីលើការអនុវត្តការងារ និងបញ្ហាដីធ្លីជាដើម។

- ការអនុវត្តការប្រាស្រ័យទាក់ទងរវាង ក.គ.ខ និងការិយាល័យប្រជាពលរដ្ឋស្រុក ក្នុងខេត្តផ្សេងៗ គួរត្រូវបានពង្រឹង ដើម្បីឲ្យការងារនៅថ្នាក់ក្រោមជាតិទាំងនោះ បានស្វែងយល់កាន់តែច្បាស់អំពីបទពិសោធន៍ប្រៀបធៀបល្អៗ។

- ការផ្តល់មូលនិធិ គួរធានាថាយ៉ាងហោចណាស់អ្នកស៊ើបអង្កេតបណ្តឹង អាចធ្វើដំណើរចុះស៊ើបអង្កេតអំពីបណ្តឹងបានគ្រប់គ្រាន់ ហើយឧបករណ៍ច្បាប់ និងគ្រឿងបរិក្ខារសម្រាប់ការទំនាក់ទំនងក៏គួរតែផ្តល់ជូនឲ្យបានគ្រប់គ្រាន់ផងដែរ ដើម្បីធានាការស៊ើបអង្កេតពាក្យបណ្តឹងបានគ្រប់គ្រាន់។

- ដំណើរការនៃការដោះស្រាយពាក្យបណ្តឹងរបស់ក.គ.ខ គួរតែដោះស្រាយឲ្យបានឆាប់រហ័ស។ កត្តានេះ នឹងតម្រូវឲ្យមានការរៀបចំប្រព័ន្ធបណ្តឹងឡើងវិញសម្រាប់ ក.គ.ខ។ ជម្រើសរួមមានការប្រើប្រាស់អាជ្ញាធរថ្នាក់ក្រោមឲ្យប្រមូល និងដោះស្រាយបណ្តឹងឲ្យបានកាន់តែញឹកញាប់ ដូចជាអនុក្រុមនៅថ្នាក់ស្រុក ឬគណៈកម្មាធិការដោះស្រាយបណ្តឹងនៅថ្នាក់ឃុំ ដែលជានិច្ចកាលត្រូវបានមើលឃើញថាមានភាពឆាប់រហ័ស និងមានប្រសិទ្ធភាពយ៉ាងខ្លាំង។

- មធ្យោបាយនៃដំណើរការការងាររបស់ការិយាល័យប្រជាពលរដ្ឋស្រុក អាចត្រូវបានលើកកម្ពស់តាមរយៈការដាក់ឲ្យមានប្រអប់សម្រាប់ទទួលពាក្យបណ្តឹងនៅតាមទីសាធារណៈ ដែលងាយមើលឃើញ។ ចំណុចនេះ អាចដំណើរការទៅបានជាមួយនិងប្រអប់ក្រុមការងារគណនេយ្យភាពខេត្ត ដោយការិយាល័យប្រជាពលរដ្ឋស្រុក ទទួលខុសត្រូវលើការប្រមូលពាក្យបណ្តឹងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក៏ប៉ុន្តែ ថាតើការងារនេះដំណើរការទៅយ៉ាងដូចម្តេច ពាក់ព័ន្ធនឹងអព្យាក្រឹត្យភាពរបស់ការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យខេត្តដែលមានសមាសភាពតំណាងមកពីរដ្ឋបាលមូលដ្ឋាន ដែលគួរតែធ្វើការពិចារណា។ លើសពីនេះទៀត គួរមានការផ្តល់ព័ត៌មានបន្ថែមស្តីពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងពង្រីកសមត្ថកិច្ចនៃការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកតាមដែលអាចធ្វើទៅបាន[41]។

- អង្គការសង្គមស៊ីវិល គប្បីទំនាក់ទំនងឲ្យបានកាន់តែញឹកញាប់ជាមួយនិងតំណាងការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និង ក.គ.ខ ក៏ដូចជាសមាជិកសភាតាមរយៈវេទិកានៅថ្នាក់មូលដ្ឋាន។ វេទិកាបែបនេះអាចប្រើប្រាស់ដើម្បីពិភាក្សាអំពីបណ្តឹងទូទៅរបស់ប្រជាពលរដ្ឋ ទីកន្លែងនៃការដាក់ពាក្យបណ្តឹង មូលហេតុដែលប្រជាពលរដ្ឋមិនសូវប្រើប្រាស់យន្តការបណ្តឹង បញ្ហាដែលសមាជិកនៃយន្តការទទួលពាក្យបណ្តឹងមានក្នុងការដាក់ពាក្យបណ្តឹង និងវិធីសាស្ត្រដែលសមាជិកសភាអាចចូលរួមបានកាន់តែប្រសើរក្នុងការដោះស្រាយបញ្ហានានានៅមូលដ្ឋាន។

[41] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌(ឆ្នាំ២០០៩)

## ផ្នែកទី២ ៖ ការសិក្សាប្រៀបធៀបទៅលើបទពិសោធន៍តំបន់ស្តីពីការដោះស្រាយបណ្តឹង និងដំណោះ ស្រាយនៃប្រទេសនីមួយៗ

### ១. យន្តការដោះស្រាយបណ្តឹងនៅអាស៊ីអាគ្នេយ៍

ការរីកចម្រើននៃរដ្ឋធម្មនុញ្ញនិយម និងលទ្ធិប្រជាធិបតេយ្យ បានបង្កើតឡើងនូវគោលគំនិតគណនេយ្យភាពរដ្ឋបាល និងការទទួលខុសត្រូវ។ នៅគ្រប់បណ្តាប្រទេសទាំងអស់ គឺចាំបាច់ណាស់ដែលប្រជាជនត្រូវដឹងអំពីវិធីសាស្ត្រឆ្លើយតប នៅពេលដែលការធ្វើសេចក្តីសម្រេច ឬសកម្មភាពណាមួយរបស់មន្ត្រីធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ពួកគេ។ ដើម្បីជានាថារដ្ឋបាលសាធារណៈបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តនីតិរដ្ឋ គណនេយ្យភាព និងតម្លាភាព យន្តការក្នុងការត្រួតពិនិត្យសកម្មភាពរបស់ពួកគេគួរត្រូវបានបង្កើតឡើង។ ជានិច្ចកាល ប្រជាជនដាក់ពាក្យបណ្តឹងដោយផ្អែកលើមូលហេតុចំនួនពីរគឺ ដោយសារមានការរំលោភអំណាច ឬដោយសារពួកគេយល់ថាសេចក្តីសម្រេចនោះមិនឈរលើផលប្រយោជន៍សាធារណៈ។

បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើនមានយន្តការបណ្តឹង ដែលស្ថិតនៅក្នុងដំណាក់កាលនៃភាពពេញលក្ខណៈខុសៗគ្នា។ យន្តការបណ្តឹងផ្លូវការ គឺស្ថិតនៅក្នុងប្រព័ន្ធរដ្ឋបាល ឬតុលាការ រីឯយន្តការក្រៅផ្លូវការជាយន្តការបន្ថែមលើយន្តការផ្លូវការ និងជានិច្ចកាលគឺមានឯករាជ្យភាពពីប្រព័ន្ធរដ្ឋបាល។ ទម្រង់នៃយន្តការដែលពេញនិយមជាងគេគឺការិយាល័យអំប៊ូស្មាន់។ យន្តការទាំងនេះខុសគ្នានៅត្រង់៖ នីតិវិធីដែលសាធារណជនអាចប្រើប្រាស់យន្តការទាំងនោះ វិសាលភាពអំណាចដែលពួកមាន និងប្រភេទនៃពាក្យបណ្តឹងដែលអាចទទួលតើអ្វីទៅដែលជាលទ្ធផលនៃបណ្តឹង និងថាតើយន្តការទាំងនេះអាចបង្កើតសេចក្តីសម្រេចចិត្តដែលចាប់បង្ខំឲ្យអនុវត្តន៍តាម ឬក៏គ្រាន់តែជាអនុសាសន៍។ អត្ថប្រយោជន៍នៃយន្តការបណ្តឹងទាំងនេះ គឺនៅត្រង់យន្តការទាំងនេះជួយសម្រាលបន្ទុករបស់តុលាការថ្នាក់ក្រោមក្នុងការស៊ើបអង្កេតលើមន្ត្រីសាធារណៈ ជាការដោះស្រាយវិវាទមានលក្ខណៈសន្សំសំចៃ ពង្រឹងភាពជឿជាក់របស់ប្រជាជនលើរដ្ឋាភិបាល និងជំរុញឲ្យមានប្រព័ន្ធរដ្ឋបាលសាធារណៈដែលមានគណនេយ្យភាព និងភាពស័ក្តសិទ្ធជាងមុន។ កត្តាជោគជ័យសំខាន់ៗមួយចំនួនគឺ យន្តការនេះមានឯករាជ្យភាពនិងមិនលំអៀង ដោះស្រាយករណីបណ្តឹងឆាប់រហ័ស មានការទទួលស្គាល់ជាសាធារណៈ និង អាចទទួលយកបានសម្រាប់ទាំងអស់គ្នា[42]។

ឯកសារនេះសិក្សា និងប្រៀបធៀបយន្តការបណ្តឹងនៅក្នុងប្រទេសវៀតណាម ថៃ និងហ្វីលីពីន។ ការសិក្សានេះនឹងផ្តោតការពិចារណាទៅលើមូលដ្ឋានគតិយុត្ត រចនាសម្ព័ន្ធ នីតិវិធីនៃយន្តការបណ្តឹង និងការប្រឈមដែលយន្តការបណ្តឹងទាំងនេះជួបប្រទះ។ នៅក្នុងប្រព័ន្ធនៃប្រទេសនីមួយៗ ត្រូវចងចាំថា យន្តការ ដែលអាចជាការិយាល័យអំប៊ូស្មាន់ ឬក្រៅពីនេះ គឺគ្រាន់តែជាឧបករណ៍មួយនៅក្នុងប្រព័ន្ធរដ្ឋបាលពេញលេញតែប៉ុណ្ណោះ។ ដោយសារយន្តការបណ្តឹងនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺនៅមានលក្ខណៈក្មេងខ្ចីនៅឡើយ ឯកសារនេះ នឹងបញ្ចប់ដោយគូសបញ្ជាក់នូវមេរៀនជាពិសោធន៍ពីយុត្តាធិការផ្សេងៗដែលបានអនុវត្តកន្លងមក និងដែលអាចមានសារៈប្រយោជន៍នៅពេលធ្វើការពិចារណាអំពីការអភិវឌ្ឍយន្តការបណ្តឹងរបស់កម្ពុជា។

---

[42] Jorg Menzel. "យន្តការ និងការដោះស្រាយពាក្យបណ្តឹងប្រជាពលរដ្ឋនៅប្រទេសអាល្លឺម៉ង់". (ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.)

## ២. ប្រទេសវៀតណាម

<u>ក្របខ័ណ្ឌគតិយុត្ត នីតិវិធី និងប្រភេទនៃបណ្តឹង</u>

មូលដ្ឋានគតិយុត្តសម្រាប់បណ្តឹងសាធារណៈនៅក្នុងប្រទេសវៀតណាម ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលដែលបានកំណត់នៅក្នុងច្បាប់ឆ្នាំ១៩៩៨ ស្តីពីបណ្តឹង និងការចោទប្រកាន់ (កំណត់ថាជា"ច្បាប់") [43] ។ ដូចបានកំណត់នៅក្នុងមាត្រា៧៥នៃច្បាប់ បណ្តឹងនានាត្រូវតែដាក់នៅ"ទីកន្លែងទទួលពាក្យបណ្តឹងប្រជាពលរដ្ឋ"។ បើទោះបីជាពុំបានកំណត់ច្បាស់លាស់នៅក្នុងច្បាប់ ទីកន្លែងទទួលបណ្តឹងទាំងនេះ គឺជាទីតាំងដែលអង្គភាពរបស់រដ្ឋត្រូវសម្រួលជូនប្រជាពលរដ្ឋដែលចង់មកដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរ ឬធ្វើការរាយការណ៍ពាក់ព័ន្ធនឹងបណ្តឹង ឬការចោទប្រកាន់ផ្សេងៗ។ តារាងពេលវេលា និងវិធានសម្រាប់ការរៀបចំបណ្តឹងគឺត្រូវបានដាក់បង្ហាញនៅទីកន្លែងទទួលពាក្យបណ្តឹង[44]។

ការទទួលខុសត្រូវលើការដោះស្រាយបណ្តឹងត្រូវបានផ្តល់ជូនអង្គភាពរដ្ឋបាលរបស់រដ្ឋ ដែលបានទទួលពាក្យបណ្តឹង។ ជាមួយគ្នានេះ អង្គភាពអធិការកិច្ចដោយឡែកផ្សេងទៀត ក៏ចូលរួមជួយអង្គភាពរដ្ឋបាលរបស់ រដ្ឋក្នុងការដោះស្រាយបណ្តឹងផងដែរ។ ប្រធានអង្គភាពរដ្ឋបាលជាអ្នកចេញសេចក្តីសម្រេចចិត្តក្នុងការដោះស្រាយបណ្តឹង ប៉ុន្តែរាល់កិច្ចការពាក់ព័ន្ធនឹងដំណើរការនៃការសិក្សាឡើងវិញ ការត្រួតពិនិត្យ និងការបញ្ចប់ករណីបណ្តឹងត្រូវប្រគល់ជូនអង្គភាពអធិការកិច្ចជាអ្នកទទួលខុសត្រូវ[45]។

ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងតាមរយៈការមកដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរ ឬតាមរយៈអ្នកតំណាងផ្នែកច្បាប់របស់ខ្លួន [46] ។ មាត្រា៧៤នៃច្បាប់កំណត់យ៉ាងលម្អិតអំពីវិធីសាស្ត្រសមស្របនៃការដាក់ពាក្យបណ្តឹងដោយផ្ទាល់ ដោយកំណត់ថាប្រធានអង្គភាពរដ្ឋបាលរបស់រដ្ឋទទួលខុសត្រូវតែងតាំងមន្ត្រីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងចំណេះដឹងអាជីពក្នុងការដោះស្រាយបណ្តឹង។ នៅពេលទទួលបានបណ្តឹង អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ការណែនាំពាក់ព័ន្ធនានាដល់ប្រជាពលរដ្ឋ ដើម្បីធានាថាពួកគេ អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបានយ៉ាងពេញលេញ និងត្រូវអនុវត្តន៍តាមយ៉ាងតឹងរឹងនូវវិធាននៃការរក្សាការសម្ងាត់ ដែលរួមមានការការពារអត្តសញ្ញាណរបស់ម្ចាស់បណ្តឹង [47] ។ យោងតាមច្បាប់ មេឃុំត្រូវជួបជាមួយប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ រីឯអ្នកតំណាងផ្សេងៗត្រូវមានវត្តមានដើម្បីដោះស្រាយបណ្តឹងយ៉ាងហោចណាស់ពីរថ្ងៃក្នុងមួយខែក្នុងកម្រិតថ្នាក់ស្រុក និងយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយខែនៅថ្នាក់ខេត្ត។ ពាក់ព័ន្ធនឹងកាលកំណត់ពេលវេលាសម្រាប់ឆ្លើយតបចំពោះសំណុំរឿងបណ្តឹងដែលបានទទួល ច្បាប់កំណត់យ៉ាងច្បាស់ថា ចាំបាច់ត្រូវមានសេចក្តីសម្រេចចិត្តមួយ អំពីថាតើគួរដោះស្រាយបណ្តឹងក្នុងរយៈពេលដប់ថ្ងៃបន្ទាប់ពីទទួល

---

[43] សាធារណៈរដ្ឋសង្គមនិយមវៀតណាម. ច្បាប់ស្តីពីបណ្តឹងនិងការចោទប្រកាន់ មាត្រា៧៥. រដ្ឋសភា. ០៩/១៩៩៨/QH១០. ទីក្រុងហាណូយ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៩៨. បានទទួលព័ត៌មាននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.moj.gov.vn/vbpq/en/Lists/Vn%20bn%20php%20lut/View_Detail.aspx?ItemID=1265

[44] សាធារណៈរដ្ឋសង្គមនិយមវៀតណាម. ច្បាប់ស្តីពីបណ្តឹងនិងការចោទប្រកាន់ មាត្រា៧៥. រដ្ឋសភា. ០៩/១៩៩៨/QH១០. ទីក្រុងហាណូយ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៩៨. បានទទួលព័ត៌មាននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.moj.gov.vn/vbpq/en/Lists/Vn%20bn%20php%20lut/View_Detail.aspx?ItemID=1265

[45] Ngoc Giao Hoang. "យន្តការដោះស្រាយបណ្តឹងផ្នែករដ្ឋបាលនៅប្រទេសវៀតណាម៖ ការប្រឈម និងដំណោះស្រាយ". អង្គការមូលនិធិអាស៊ី និងវិទ្យាស្ថានគោលនយោបាយ ច្បាប់ និងការអភិវឌ្ឍ. ខែសីហា ឆ្នាំ២០០៩. ទំព័រ១៣.

[46] វៀតណាម. ច្បាប់ស្តីពីបណ្តឹង. មាត្រា៧៤.

[47] Ibid., មាត្រា៧៧.

បណ្តឹងឬទេ[48]។ មាត្រា៣៥និង៣៦ ពិពណ៌នាកាន់តែលម្អិតអំពីរយៈពេលនៃការដោះស្រាយបណ្តឹង។ ជាទូទៅ ក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីទទួលបានបណ្តឹង ដំណោះស្រាយមួយចំនួនគួរត្រូវធ្វើឡើងចំពោះបណ្តឹងដែលបានទទួលទាំងនោះ[49]។

រហូតមកដល់ពេលថ្មីៗនេះ ចំនួនលិខិតបណ្តឹងរបស់ប្រជាពលរដ្ឋដែលបានទទួលប្រចាំឆ្នាំមានការកើនឡើង ដែលបង្កើតជាតម្រូវការបន្ទាន់មួយក្នុងការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័សនៅគ្រប់វិស័យ[50]។ ផ្ទុយទៅវិញ នៅក្នុងឆ្នាំ២០១១ កំណត់ត្រាបង្ហាញថា ចំនួនលិខិតបណ្តឹងដែលបានទទួលនៅក្នុងប្រទេសវៀតណាមបានថយចុះជាងឆ្នាំមុន ៨,០៧% ជាមួយនឹងលិខិតបណ្តឹងចំនួន ១២៣.៩០៥ច្បាប់ ដែលបានទទួល និងចំនួន ១០៤.១៣៣ ករណីប៉ុណ្ណោះ ត្រូវបានយកមកធ្វើការស៊ើបអង្កេត។ ក្នុងចំណោមតួលេខទាំងនោះ ករណីបណ្តឹងភាគច្រើន(៨០%) ពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី។ បណ្តឹងទាំងនោះផ្តោតលើបញ្ហានានា ដូចជា ការទទួលសំណងតាមតម្លៃទីផ្សារនៅពេលដែលដីត្រូវបានរឹបអូសដោយរដ្ឋាភិបាល និងសំណើផ្លាស់ប្តូរលំនៅដ្ឋាន និងទ្រព្យសម្បត្តិដែលស្ថិតនៅទីតាំងដីដែលមានបញ្ហា។ បណ្តឹងផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហា ដូចជា ការអនុវត្តគោលនយោបាយសង្គម(ការប៉ះប៉ូវសម្រាប់ការបាត់បង់របស់សាច់ញាតិមន្ត្រីយោធា មូលនិធិសម្រាប់ការចូលនិវត្តន៍ ។ល។) បរិស្ថាន និងការប្រតិបត្តិរបស់រដ្ឋាភិបាល[51]។ បណ្តឹងពាក់ព័ន្ធនឹងបញ្ហាតុលាការមាន ១០,១៦%នៃបណ្តឹងសរុប បញ្ហាលំនៅដ្ឋាន៣,៤% បញ្ហាវប្បធម៌និងសង្គម៣,១%[52]។ ជារួម ក្នុងចន្លោះរវាងឆ្នាំ ២០១០ និង២០១១ ចំនួនបណ្តឹងនិងការចោទប្រកាន់នានាថយចុះ ៦,២%។

## ការប្រឈមចំពោះយន្តការនានា

បើទោះបីជាមានច្បាប់ស្តីពីបណ្តឹងនិងការចោទប្រកាន់ តែវិស័យដែលប្រជាពលរដ្ឋមានសិទ្ធិប្តឹង គឺនៅមានកម្រិតនៅឡើយ ជាក់ស្តែងដូចជា បញ្ហាឯកសារចេញដោយអង្គភាពរបស់រដ្ឋដែលប៉ះពាល់ដោយផ្ទាល់ទៅលើការរស់នៅរបស់ប្រជាពលរដ្ឋ។ ផ្ទុយទៅវិញ យោងទៅតាមច្បាប់នេះ ម្ចាស់បណ្តឹងអាចត្រឹមតែប្តឹងទៅលើសេចក្តីសម្រេចចិត្ត ឬសកម្មភាពផ្នែករដ្ឋបាលប៉ុណ្ណោះ[53]។ ការភ័ន្តច្រឡំត្រូវបានកើតមានឡើង នៅពេលដែលការដាក់កំហិតទៅលើប្រភេទនៃបណ្តឹងនេះ វាផ្ទុយទៅនឹងស្មារតីនៃរដ្ឋធម្មនុញ្ញវៀតណាម ដែលចែងថា៖ "ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិក្នុងការប្តឹង ឬចោទប្រកាន់តាមរយៈអាជ្ញាធររដ្ឋមានសមត្ថកិច្ចណាមួយពាក់ព័ន្ធនឹងបទល្មើសនៃច្បាប់របស់អង្គភាពរដ្ឋ ស្ថាប័នសេដ្ឋកិច្ចឬសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធណាមួយ ឬបុគ្គលណាមួយ"[54]។

---

[48] Ibid., មាត្រា៣៤.

[49] Ibid., មាត្រា៣៥-៣៦.

[50] Hoang. "បណ្តឹងផ្នែករដ្ឋបាលនៅវៀតណាម". ទំព័រ២.

[51] Ibid., ទំព័រ៣.

[52] Nguyen Duc Hanh. "ការកំណត់អំពីបញ្ហាកង្វល់របស់ប្រជាជនពីលំហូរពាក្យបណ្តឹងប្រចាំថ្ងៃ និងការចូលរួមក្នុងការលើកកម្ពស់ជាប្រព័ន្ធ". មន្ត្រីអធិការកិច្ចរបស់រដ្ឋាភិបាលវៀតណាម. (បទបង្ហាញនៅក្នុង កិច្ចប្រជុំលើកទី៥ នៃសិក្ខាសាលាលើកទី១២របស់សមាគមអំប៊ូស្មាន់អាស៊ី នៅប្រទេសជប៉ុន. ថ្ងៃទី ៥-៨ ខែធ្នូ ឆ្នាំ២០១១.)

[53] Hoang. "បណ្តឹងផ្នែករដ្ឋបាលនៅវៀតណាម". ទំព័រ៧.

[54] សាធារណៈរដ្ឋសង្គមនិយមវៀតណាម. រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម. រដ្ឋសភា. ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩២. បានទទួលព័ត៌មាននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ពី http://www.na.gov.vn/htx/English/C1479/#H3UT027CqkTm

មិនតែប៉ុណ្ណោះ ការដាក់ពាក្យបណ្តឹងជាក្រុមគឺមិនអាចទទួលយកនោះទេ។ បើទោះបីជាប្រធានបទនៃបណ្តឹងតែមួយ ករណីម្ចាស់ពាក្យបណ្តឹងច្រើនរួមគ្នា ឬលើសពីម្នាក់ គឺមិនត្រូវបានអនុញ្ញាតនោះទេ។ ដូចមានចែងនៅក្នុងច្បាប់ ម្ចាស់បណ្តឹងម្នាក់ៗត្រូវសរសេរលិខិតបណ្តឹងដោយឡែកមួយ[55]។ ជាចុងក្រោយ បញ្ហាមួយទៀតដែលកើតមានឡើងគឺ អង្គភាពអធិការកិច្ចមិនមានឯករាជ្យភាពពីអង្គភាពរដ្ឋបាលរបស់រដ្ឋ ដែលជាអង្គភាពទទួលខុសត្រូវលើសេចក្តីសម្រេចចិត្តស្តីពីនីតិវិធីដោះស្រាយបណ្តឹង។ អង្គភាពរដ្ឋបាលទាំងនេះ ប្រគល់រាល់កិច្ចការពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងជូនអង្គភាពអធិការកិច្ច។ ភាពស្មុគស្មាញពាក់ព័ន្ធនឹងការទទួលខុសត្រូវលើការដោះស្រាយបណ្តឹងធ្វើឲ្យមានការភ័ន្តច្រឡំ អំពីទីកន្លែង និងអ្នកទទួលខុសត្រូវដែលប្រជាពលរដ្ឋគួរដាក់ពាក្យបណ្តឹងរបស់ខ្លួនជូន។

សរុបមក យន្តការដោះស្រាយបណ្តឹងផ្នែករដ្ឋបាលនៅប្រទេសវៀតណាមជួបប្រទះនូវការប្រឈមជាច្រើនដោយសារភាពស្មុគស្មាញ រចនាសម្ព័ន្ធ និងនីតិវិធីមិនច្បាស់លាស់ សិទ្ធិមានដែនកំណត់ក្នុងការដាក់ពាក្យបណ្តឹងលើបញ្ហាជាក់លាក់មួយចំនួន និងការមិនអនុញ្ញាតក្នុងការដាក់បណ្តឹងច្រើនរួមគ្នាតែមួយរបស់ខ្លួន។

## ៣. ប្រទេសថៃ

### <u>ក្របខ័ណ្ឌគតិយុត្ត នីតិវិធី និងប្រភេទនៃបណ្តឹង</u>

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧របស់ប្រទេសថៃ បានបង្កើតអង្គភាពអំប៊ុដ្សម៉ាន់ជាស្ថាប័នរដ្ឋធម្មនុញ្ញឯករាជ្យមួយជាមួយនឹងការតែងតាំងការិយាល័យអំប៊ុដ្សម៉ាន់ដំបូងនៅឆ្នាំ២០០០។ ការិយាល័យនេះ ត្រូវដឹកនាំដោយមន្ត្រីអំប៊ុដ្សម៉ាន់ចំនួនបីរូប ដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមរយៈការផ្តល់ប្រឹក្សារបស់ព្រឹទ្ធសភា។ មន្ត្រីអំប៊ុដ្សម៉ាន់នីមួយៗមានមុខងារជាតួអង្គឯករាជ្យ និងមានការទទួលខុសត្រូវលើតំបន់ផ្សេងៗនៃប្រទេស។ ការិយាល័យនេះត្រូវបានផ្តល់សមត្ថកិច្ចក្នុងការស៊ើបអង្កេតបណ្តឹង ស្តីពីប្រព័ន្ធរដ្ឋបាលមិនត្រឹមត្រូវ ការបំពេញការងារដែលផ្ទុយនឹងច្បាប់ និងការអនុវត្តមិនសមស្រប(ទោះបីផ្ទុយនឹងច្បាប់ ឬមិនផ្ទុយក៏ដោយ) ដោយមន្ត្រីសាធារណៈ[56]។ សកម្មភាពនៃប្រព័ន្ធរដ្ឋបាលមិនត្រឹមត្រូវ អាចសំដៅលើការធ្វេសប្រហេសនៃអំណាច ការប្រើប្រាស់អំណាចហួសកម្រិត សេចក្តីសម្រេចចិត្តមិនសមស្របដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាល និងអំពីថាតើសេចក្តីសម្រេចចិត្តមានធម្មានុរូបភាពឬទេ។

នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ការិយាល័យអំប៊ុដ្សម៉ាន់ត្រូវបានផ្តល់ជូនការទទួលខុសត្រូវបន្ថែមក្នុងការចាត់វិធានការណ៍ផ្នែកច្បាប់ពាក់ព័ន្ធនឹងក្រមសីលធម៌របស់បុគ្គលដែលមានមុខងារនយោបាយ និងមានមុខងារនៅក្នុងជួររដ្ឋាភិបាល និងក្នុងការស៊ើបអង្កេតលើការខកខានណាមួយក្នុងការបំពេញភារកិច្ច ឬការបំពេញភារកិច្ចដោយផ្ទុយពីច្បាប់របស់ភ្នាក់ងារ ឬស្ថាប័នរដ្ឋធម្មនុញ្ញនៅក្នុងរដ្ឋបាលយុត្តិធម៌(ដោយមិនរាប់បញ្ចូលការស៊ើបសួររបស់តុលាការ និងការវិនិច្ឆ័យរបស់តុលាការ)។ ការិយាល័យអំប៊ុដ្សម៉ាន់របស់ប្រទេសថៃ មានការទទួលខុសត្រូវពិសេសដោយឡែកមួយ៖ ការិយាល័យនេះអាចត្រួតពិនិត្យ វាយតម្លៃ និងរៀបចំអនុសាសន៍ស្តីពីបញ្ហាធម្មនុញ្ញភាព ដោយផ្អែកលើបណ្តឹង ឬការផ្តួចផ្តើមដោយផ្ទាល់របស់ខ្លួន និងផ្តល់អនុសាសន៍ជូនតុលាការធម្មនុញ្ញ។

---

[55] Hoang. "បណ្តឹងផ្នែករដ្ឋបាលនៅវៀតណាម". ទំព័រ១២.

[56] Panit Nitithanprapas. "ការដោះស្រាយបណ្តឹងប្រចាំថ្ងៃឆ្ពោះទៅវិធីសាស្ត្រដោះស្រាយជាប្រព័ន្ធមួយ៖បទពិសោធន៍អំពីការងារអំប៊ុដ្សម៉ាន់របស់ប្រទេសថៃ". (ឯកសារដែលបានធ្វើបទបង្ហាញនៅសិក្ខាសាលាលើកទី១២ របស់សមាគមអំប៊ុដ្សម៉ាន់អាស៊ី នៅប្រទេសជប៉ុន. ថ្ងៃទី៥-៨ ខែធ្នូ ឆ្នាំ២០១១). បានទទួលព័ត៌មាននៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.soumu.gov.jp/main_content.

នៅក្នុងការិយាល័យអំប៊ូស្មាន់របស់ថៃ ច្រកផ្សេងៗត្រូវបានណែនាំដើម្បីសម្របសម្រួលដល់ការដាក់ពាក្យបណ្តឹង មានដូចជា៖

- ការដាក់ពាក្យបណ្តឹងតាមរយៈការទៅជួបផ្ទាល់
- បណ្តឹងតាមរយៈប្រព័ន្ធអ៊ីនធើណេត
- ទូរស័ព្ទ និងទូរសារ៖ ប្រព័ន្ធទូរស័ព្ទត្រូវបានរៀបចំឡើងទូទាំងប្រទេសសម្រាប់ប្រជាពលរដ្ឋ ដែលចង់ដាក់ពាក្យបណ្តឹង តែពុំមានលទ្ធភាពចំណាយថ្លៃទូរស័ព្ទ និងការផ្តល់នូវមជ្ឈមណ្ឌលទទួលទូរស័ព្ទដែលឥតគិតថ្លៃ
- ប៉ុស្តិ៍ប្រៃសណីយ៖ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ។ ពួកគេអាចបញ្ជាក់ពីព័ត៌មានទំនាក់ទំនងរបស់ខ្លួន(អាស័យដ្ឋាន និងលេខទូរស័ព្ទ) ឬរក្សាការសម្ងាត់ពីព័ត៌មានរបស់ខ្លួនក៏បាន
- សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា៖ ប្រសិនបើបណ្តឹងត្រូវបានដាក់ជូនតាមរយៈអ្នកតំណាងរាស្ត្រជាប់ឆ្នោត ដូច្នេះសមាជិកសភាត្រូវដាក់ពាក្យបណ្តឹងទៅការិយាល័យអំប៊ូស្មាន់ក្នុងអំឡុងការបើកកិច្ចប្រជុំសភា និង
- បណ្តាញនៃការិយាល័យអំប៊ូស្មាន់របស់ប្រទេសថៃ៖ មានការិយាល័យផ្សេងទៀតជាច្រើនក្រៅពីការិយាល័យអំប៊ូស្មាន់ដែលដើរតួនាទីជាច្រកសម្រាប់ប្រជាពលរដ្ឋក្នុងការស្វែងរកការប្រឹក្សាផ្នែកច្បាប់ ឬដាក់ពាក្យបណ្តឹង។ ការិយាល័យទាំងនេះមានដូចជា ការិយាល័យក្រុមប្រឹក្សាមេធាវី ការិយាល័យអគ្គព្រះរាជអាជ្ញា ការិយាល័យគាំពារសិទ្ធិប្រជាពលរដ្ឋ និងជំនួយផ្នែកច្បាប់ និងការិយាល័យមេធាវីថ្នាក់ខេត្តទូទាំងប្រទេស[57]។

បណ្តឹងនីមួយៗត្រូវដោះស្រាយក្នុងរយៈពេល៦ខែ។ ប៉ុន្តែ បណ្តឹងអាចត្រូវបដិសេធមិនទទួលយកដោយការិយាល័យអំប៊ូស្មាន់ ប្រសិនបើបណ្តឹងនោះមិនមានលក្ខណៈគ្រប់គ្រាន់តាមលក្ខខ័ណ្ឌតម្រូវដែលកំណត់នៅក្នុងផ្នែកទី២៨និង២៩ នៃច្បាប់រៀបចំអង្គការឆ្នាំ២០០៩ស្តីពីការិយាល័យអំប៊ូស្មាន់។ ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ(គ) បន្ទាប់មកការិយាល័យអំប៊ូស្មាន់ត្រូវផ្តល់ព័ត៌មានអំពីការបដិសេធបណ្តឹងដល់ម្ចាស់បណ្តឹង និងក៏អាចបញ្ជូនបណ្តឹងដែលបដិសេធរួចនោះទៅកាន់ស្ថាប័នវេងការចោទប្រកាន់សម្រាប់ការពិចារណា។ ប្រសិនបើបណ្តឹងមានសុពលភាព ភាគីទាំងពីរនៃបណ្តឹងនឹងត្រូវស្នើឲ្យផ្តល់ការបំភ្លឺ និងបង្ហាញភស្តុតាងពាក់ព័ន្ធនឹងការបំភ្លឺនោះ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតលើបណ្តឹងណាមួយ ការិយាល័យអំប៊ូស្មាន់ត្រូវរៀបចំរបាយការណ៍ និងផ្ញើទៅកាន់ភ្នាក់ងារពាក់ព័ន្ធនានា ដើម្បីឲ្យភ្នាក់ងារទាំងនោះទទួលបានព័ត៌មានអំពីដំណើរការរឿងក្តី និងអាចអនុវត្តន៍នូវសេចក្តីសម្រេចនានាដែលស្នើឡើងដោយការិយាល័យអំប៊ូស្មាន់[58]។ រដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ក៏បានផ្តល់សមត្ថកិច្ចដល់ការិយាល័យអំប៊ូស្មាន់របស់ថៃក្នុងការដំណើរការការស៊ើបអង្កេត បើទោះបីជាបណ្តឹងត្រូវបានធ្វើឡើងឬអត់ក៏ដោយ។ ប្រការនេះអនុញ្ញាតឲ្យការិយាល័យអំប៊ូស្មាន់ធ្វើការស៊ើបអង្កេតលើបញ្ហានានាដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ និងផ្តួចផ្តើមការសិក្សា ឬស្រាវជ្រាវលើចំណុចដែលខ្លួនគិតថាចាំបាច់[59]។

[57] ការិយាល័យអំប៊ូស្មាន់របស់ថៃ. "នីតិវិធីដាក់ពាក្យបណ្តឹង". បានទទួលព័ត៌មាននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/howtocomplaint.asp.

[58] ព្រះរាជាណាចក្រថៃ. ច្បាប់រៀបចំអង្គការស្តីពីអំប៊ូស្មាន់. B.E២៥៥២. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/7_2.asp.

[59] ការិយាល័យអំប៊ូស្មាន់របស់ថៃ. "សកម្មភាពនានា៖ វិធីសាស្ត្រដោះស្រាយករណីបណ្តឹង". បានទទួលព័ត៌មាននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/5_1.asp.

បណ្តឹងត្រូវស៊ើបអង្កេតដោយការិយាល័យអំប៊ុដ្សមាន់តាមរយៈវិធីសាស្ត្រដូចខាងក្រោម៖

- ការស្ទង់មតិ និងចុះទៅកាន់ទីតាំងដែលមានបញ្ហា
- ការសម្រុះសម្រួលតាមរយៈកិច្ចប្រជុំ
- ការដោះស្រាយតាមរយៈទូរស័ព្ទ និង
- ឯកសារ និងការឆ្លើយឆ្លងផ្លូវការ

ចាប់តាំងពីខែមេសាឆ្នាំ២០០០ រហូតមកដល់ចុងខែឧសភាឆ្នាំ២០១៣ ការិយាល័យអំប៊ុដ្សមាន់បានទទួលបណ្តឹងចំនួន២៩.៧១៦។ បណ្តឹងចំនួន២៨.០០០ករណី(៩៤%) ត្រូវបានដោះស្រាយ ខណៈដែលបណ្តឹងចំនួន១.៧៩៩ករណី(៦%)ស្ថិតក្រោមការស៊ើបអង្កេត[60]។ បណ្តឹងទាំងនេះ ត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាផ្សេងៗជាច្រើន ដែលភាគច្រើនពាក់ព័ន្ធនឹងបញ្ហាមន្ត្រីនគរបាល ដីធ្លី រដ្ឋបាលមូលដ្ឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

## ការប្រឈមចំពោះយន្តការនានា

បើទោះបីជាការិយាល័យអំប៊ុដ្សមាន់ត្រូវបានចាត់ទុកថា ជាស្ថាប័នឯករាជ្យក្រោមរដ្ឋធម្មនុញ្ញ ប៉ុន្តែស្ថាប័ននេះនៅតែធ្វើការស្នើសុំថវិកាពីរដ្ឋាភិបាល។ ប្រការនេះបានធ្វើឲ្យលេចឡើងនូវបញ្ហា ដោយសារពេលខ្លះគណបក្សកាន់អំណាចនៅក្នុងសភាពុំគាំទ្រដល់ការិយាល័យអំប៊ុដ្សមាន់នៅក្នុងការអនុវត្តសកម្មភាពរបស់ខ្លួនក្នុងនាមជាស្ថាប័នការពារសិទ្ធិមនុស្ស និងផលប្រយោជន៍សាធារណៈ នៅពេលដែលបណ្តឹងត្រូវបានធ្វើឡើងប្រឆាំងទៅនឹងរដ្ឋាភិបាល ហើយពេលខ្លះរដ្ឋាភិបាលក៏បានដាក់កំហិតថវិការបស់ការិយាល័យអំប៊ុដ្សមាន់ដោយសារបញ្ហានេះ[61]។ ប្រការនេះបង្ហាញអំពីឥទ្ធិពលនៃការគិតគូរផ្នែកនយោបាយបង្កជាបញ្ហាដល់យន្តការនេះ។ ធម្មានុរូបភាព និងអព្យាក្រឹត្យភាពប្រហែលជាមិនគ្រប់គ្រាន់សម្រាប់ការដំណើរការការិយាល័យនេះប្រកបដោយប្រសិទ្ធភាពនោះទេ ហើយវាពិតជាលំបាកក្នុងការបង្ហាញថាការិយាល័យនេះគឺផ្តោតយកចិត្តទុកដាក់ទៅលើម្ចាស់បណ្តឹង តែក៏មិនប្រឆាំងនឹងរដ្ឋាភិបាលនោះដែរ។ ការិយាល័យនេះត្រូវព្យាយាមរក្សាលំនឹងរបស់ខ្លួន ដើម្បីទទួលបានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ[62]។

មជ្ឈមណ្ឌលធនធានផ្នែកច្បាប់អាស៊ីបានបង្ហាញថា រដ្ឋាភិបាលថៃអាចនឹងមិនយកចិត្តទុកដាក់លើបណ្តឹងនានាពាក់ព័ន្ធនឹងការរំលោភអំណាច ដែលប្តឹងទៅលើមន្ត្រីរដ្ឋាភិបាល[63]។ ពួកគេពុំបានដឹងថា បណ្តឹងតែមួយអាចនាំទៅដល់ការស៊ើបអង្កេតជាទីពេញចិត្តមួយ និងការចោទប្រកាន់ទៅលើជនសង្ស័យនានាដែលប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនឹងមន្ត្រីនគរបាល មន្ត្រីយោធា ឬមន្ត្រីរដ្ឋាភិបាលផ្សេងៗ។ ពួកគេបានអះអាងថា ប្រការនេះកើតឡើងដោយសារអវត្តមាននៃអង្គភាពឯករាជ្យពិតប្រាកដក្នុងការទទួល និងស៊ើបអង្កេតបណ្តឹងទាំងនេះ[64]។

---

[60] Siracha Chareonpanij. "អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមនៃយន្តការ និងប្រព័ន្ធដោះស្រាយបណ្តឹងនានាប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព". (ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.)

[61] Siracha Chareonpanij. "អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមនៃយន្តការ និងប្រព័ន្ធដោះស្រាយបណ្តឹងនានាប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព". (ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.)

[62] Chareonpanij. "អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម".

[63] "ប្រទេសថៃ/ក្រុមប្រឹក្សាUN HR៖ កង្វះខាតធ្ងន់ធ្ងរនៃយន្តការបណ្តឹងនៅប្រទេសថៃ". សាមគ្គីភាពផ្នែកសិទ្ធិមនុស្ស ១៦៖២. (ឆ្នាំ២០០៦). បានទទួលព័ត៌មាននៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ពី http://www.hrsolidarity.net/mainfile.php/2006vol16no02/2518/.

[64] Ibid.

សរុបមក ឯករាជ្យភាព និងការគាំទ្រផ្នែកហិរញ្ញវត្ថុ អាចជាកត្តាគន្លឹះមួយសម្រាប់ការិយាល័យអំប៊ូស្មាន់នៅក្នុងប្រទេសថៃ។

## ៤. ប្រទេសហ្វីលីពីន

### ក្របខ័ណ្ឌគតិយុត្ត នីតិវិធី និងប្រភេទនៃបណ្តឹង

នៅក្នុងប្រទេសហ្វីលីពីន ការិយាល័យអំប៊ូស្មាន់គឺជាភ្នាក់ងារប្រឆាំងអំពើពុករលួយនាំមុខគេរបស់រដ្ឋាភិបាល។ ការិយាល័យនេះត្រូវបានបង្កើតឡើងតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៧របស់ហ្វីលីពីន មាត្រា១១ផ្នែកទី៥។ ការិយាល័យនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ជាការិយាល័យមួយ "ដែលធ្វើសកម្មភាពបានឆាប់រហ័ស សន្សំសម្ចៃ និងមានប្រសិទ្ធភាពទៅលើបណ្តឹងប្រឆាំងទៅនឹងភាពអសកម្ម ការរំលោភអំណាច និងការប្រព្រឹត្តតាមអំពើចិត្តផ្នែករដ្ឋបាលរបស់មន្ត្រី និងបុគ្គលិករដ្ឋាភិបាល"[65]។ ការិយាល័យអំប៊ូស្មាន់ ផ្តល់អាទិភាពចំពោះបណ្តឹងទាំងឡាយណាដែលធ្វើឡើងប្រឆាំងទៅនឹងមន្ត្រី ឬបុគ្គលិកជាន់ខ្ពស់របស់រដ្ឋាភិបាល[66] ដែលរួមមានបុគ្គលិកសាជីវកម្មរបស់រដ្ឋ ឬដឹកនាំដោយរដ្ឋ។ ប្រធានការិយាល័យអំប៊ូស្មាន់ ត្រូវបានគាំទ្រដោយអនុប្រធានអំប៊ូស្មាន់១រូបនៅថ្នាក់កណ្តាល និងអនុប្រធានអំប៊ូស្មាន់៣រូបទទួលខុសនៅប្រជុំកោះLuzon, ប្រជុំកោះVisayas និងប្រជុំកោះMindanao (ប្រជុំកោះដែលរួមមាន១៧តំបន់)។ លើសពីនេះក៏នៅមានអនុប្រធានអំប៊ូស្មាន់សម្រាប់វិស័យយោធា និងភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ផ្សេងទៀតផងដែរ។ ជារួម បញ្ហាត្រូវបានធ្វើការចម្រោះតាំងពីកម្រិតbarangay(កម្រិតរដ្ឋបាលទាបបំផុតនៅក្នុងប្រទេសហ្វីលីពីន ដែលសមមូលនឹងភូមិ ស្រុក ឬសង្កាត់) រហូតដល់ការិយាល័យអំប៊ូស្មាន់ថ្នាក់កណ្តាល។

### ការិយាល័យអំប៊ូស្មាន់មានសមត្ថកិច្ចមុខងារចំបង៤ គឺ៖

១. ការស៊ើបអង្កេត៖ ស៊ើបអង្កេតលើសកម្មភាព ឬការខកខានមិនបានបំពេញការងារណាមួយរបស់មន្ត្រី ឬភ្នាក់ងារសាធារណៈណាមួយ នៅពេលដែលសកម្មភាព ឬការខកខាននេះហាក់មានលក្ខណៈផ្ទុយពីច្បាប់ អយុត្តិធម៌ មិនត្រឹមត្រូវ ឬគ្មានភាពស័ក្តសិទ្ធិ។ ការិយាល័យនេះ អាចធ្វើការស៊ើបអង្កេតដោយយោងតាមបណ្តឹង ឬតាមការផ្តួចផ្តើមរបស់ខ្លួនផ្ទាល់។

២. ការចោទប្រកាន់៖ ប្តឹងចោទប្រកាន់ករណីបទល្មើសចំពោះមុខតុលាការទូទៅ និងផ្តួចផ្តើមវិធានការណ៍ចំពោះការរកឃើញនូវទ្រព្យសម្បត្តិដែលមិនអាចបកស្រាយបាន។

៣. ជំនួយសាធារណៈ៖ ផ្តល់ជំនួយសាធារណៈតាមរយៈការធ្វើសកម្មភាពប្រឆាំងទៅនឹងភាពអសកម្ម ឬភាពមិនត្រឹមត្រូវរបស់មន្ត្រីនៅក្នុងការបំពេញមុខងាររបស់ខ្លួន។

៤. ការទប់ស្កាត់អំពើពុករលួយ៖ អនុវត្តន៍ការទប់ស្កាត់អំពើពុករលួយ តាមរយៈការកំណត់នូវមូលហេតុនៃការគ្រប់គ្រងមិនត្រឹមត្រូវ ការក្លែងបន្លំ និងអំពើពុករលួយនៅក្នុងជួររដ្ឋាភិបាល និងផ្តល់អនុសាសន៍ចំពោះការដកចេញពីតំណែងនូវមន្ត្រីទាំងនោះ និងការគោរពតាមក្រមសីលធម៌ដែលមានស្តង់ដាខ្ពស់របស់មន្ត្រីសាធារណៈ[67]។

---

[65] សាធារណៈរដ្ឋហ្វីលីពីន. រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋហ្វីលីពីន. R.A.៦៧៧០. ឆ្នាំ១៩៨៧. បានទទួលព័ត៌មាននៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣ ពី http://www.lawphil.net/consti/cons1987.html.

[66] សាធារណៈរដ្ឋហ្វីលីពីន. ច្បាប់ដែលចែងអំពីការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ការិយាល័យអំប៊ូស្មាន់ និងចែងអំពីគោលបំណងផ្សេងទៀត. R.A. ៦៧៧០. ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៨៩. បានទទួលព័ត៌មាននៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ពី *www.doj.gov.ph/files/6770.pdf*. ផ្នែកទី១៥.

[67] ហ្វីលីពីន. ច្បាប់ស្តីពីអំប៊ូស្មាន់.

ការិយាល័យអំប៊ុស្មាន់របស់ហ្វីលីពីន ដើរតួនាទីយ៉ាងសំខាន់នៅក្នុងយុទ្ធនាការប្រឆាំងអំពើពុករលួយរបស់ប្រទេសនេះ។ "ការតាមដានអំពីដំណើរជីវិតរស់នៅ" គឺជាយុទ្ធសាស្ត្រស៊ើបអង្កេតមួយក្នុងការកំណត់ពីទ្រព្យសម្បត្តិដែលបានមកដោយមិនស្មោះត្រង់ និងមិនអាចបកស្រាយបានរបស់មន្ត្រី និងបុគ្គលិករដ្ឋាភិបាល ដើម្បីពិនិត្យឲ្យឃើញថា តើពួកគេកំពុងប្រមូលទ្រព្យសម្បត្តិដោយខុសច្បាប់ ឬយ៉ាងណា។ ដើម្បីសម្រេចឲ្យបានតួនាទីនេះ ការិយាល័យអំប៊ុស្មាន់ចាំបាច់ត្រូវរក្សាឲ្យបាននូវឯករាជ្យភាព និងសេរីភាពពីឥទ្ធិពលណាមួយ[68]។ ការិយាល័យនេះទទួលបានថវិកាពីរដ្ឋាភិបាល ដែលអាចធានាអំពីស្វ័យភាពថវិការបស់ខ្លួនបាន។ ការិយាល័យនេះក៏ទទួលបានអំណាចក្នុងការរៀបចំបុគ្គលិក និងរចនាសម្ព័ន្ធរបស់ខ្លួន ហើយមន្ត្រីអំប៊ុស្មាន់អាចត្រូវបណ្តេញចេញតែក្នុងករណីមានការចោទប្រកាន់ជាសាធារណៈប៉ុណ្ណោះ [69] ។ ការិយាល័យអនុវត្តតាមការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាលរបស់ខ្លួន ក្នុងករណីដែលភស្តុតាងបញ្ជាក់អះអាង ដើម្បីធានាអំពីគណនេយ្យភាពរបស់រដ្ឋបាលសាធារណៈចំពោះប្រជាជន។

បុគ្គលភាពជាដៃគូសាជីវកម្ម ឬអង្គភាពណាមួយ អាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ឬមកដោយផ្ទាល់ ប៉ុន្តែលិខិតបណ្តឹងនោះចំបាច់ត្រូវបង្ហាញពីលក្ខណៈនៃបណ្តឹង។ ម្ចាស់បណ្តឹងអាចដាក់ពាក្យបណ្តឹងរបស់ខ្លួនដោយផ្ទាល់នៅការិយាល័យកណ្តាលរបស់អំប៊ុស្មាន់ ឬតាមរយៈគេហទំព័ររបស់ការិយាល័យអំប៊ុស្មាន់ក៏បាន។ នៅពេលដែលបណ្តឹងបានដាក់រួចរាល់ ការិយាល័យមានរយៈពេល១០ថ្ងៃក្នុងសម្រេចថាតើគួរបំពេញឯកសារបង្ហាញពីការយល់ឃើញរបស់ខ្លួន និងធ្វើការស៊ើបអង្កេត ឬទេ។ បណ្តឹងដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងលក្ខខណ្ឌទម្រង់ និងខ្លឹមសារ ត្រូវដាក់ឲ្យធ្វើការស៊ើបអង្កេតលើកដំបូង និង/ឬការវិនិច្ឆ័យផ្នែករដ្ឋបាល។ បើមិនដូច្នោះទេ បណ្តឹងនេះនឹងត្រូវដាក់ឲ្យធ្វើការសិក្សាស្វែងរកព័ត៌មានបន្ថែមទៀត។ ប្រសិនបើបណ្តឹងមានលក្ខណៈបង្ហាញពីការគាបសង្កត់ ឬស្នើឲ្យមានជំនួយឧបត្ថម្ភផ្សេងៗ បណ្តឹងនេះត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ការិយាល័យអំប៊ុស្មាន់ស្តីពីជំនួយសាធារណៈ ដែលទទួលបន្ទុកទទួលបណ្តឹងសាធារណៈ[70]។ ដំណើរការស្វែងរកព័ត៌មានតម្រូវឲ្យធ្វើការប្រមូលឯកសារពាក់ព័ន្ធនានាដែលអាចប្រើប្រាស់ជាភស្តុតាង ធ្វើការត្រួតពិនិត្យដោយផ្ទាល់ និង/ឬប្រតិបត្តិការនៃការឃ្លាំមើល និងធ្វើបទសម្ភាសន៍ជាមួយបុគ្គលដែលអាចដឹងអំពីព្រឹត្តការណ៍នានា ជុំវិញការចោទប្រកាន់ដោយគ្មានភស្តុតាង។ ការិយាល័យនេះ មានអំណាចក្នុងការដាក់ទណ្ឌកម្មផ្នែករដ្ឋបាលដល់មន្ត្រីសាធារណៈ ដែលប្រព្រឹត្តខុសនៅក្នុងលក្ខខណ្ឌកាដោយការបណ្តេញចេញ ការព្យួរការងារ ការស្តីបន្ទោស និងការពិន័យ។ ចំពោះអ្នកសមគំនិតត្រូវដាក់ទណ្ឌកម្ម ដូចជា ការដកហូតសិទ្ធិជាអចិន្ត្រៃយ៍ពីការគ្រប់គ្រងការិយាល័យសាធារណៈ ហើយក៏ប្រហែលជាអាចដកហូតសិទ្ធិទទួលបានផលប្រយោជន៍ពីការចូលនិវត្តន៍ផងដែរ[71]។

នៅក្នុងឆ្នាំ២០១១ ការិយាល័យបានទទួលបណ្តឹងថ្មីសរុបចំនួន ១៦.៩៨៧ ដែលចំនួននេះកើនឡើង ៣០%លើសនៅឆ្នាំមុន។ បណ្តឹងភាគច្រើនគឺធ្វើឡើងចំពោះមន្ត្រី និងបុគ្គលិកនៃអង្គភាពរដ្ឋាភិបាលមូលដ្ឋាន

---

68 Harry Roque. "តើការិយាល័យអំប៊ុស្មាន់បានដំណើរការអាណត្តិការងាររបស់ខ្លួន ក្នុងនាមជា"អ្នកគាំ ពារប្រជាជនឬទេ? បទពិសោធន៍ប្រទេសហ្វីលីពីន". (ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣).

69 Conchita Carpio Morales. "ប្រព័ន្ធអំប៊ុស្មាន់៖ ករណីរបស់ប្រទេសហ្វីលីពីន". (ឯកសារដែលបានធ្វើ បទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣).

70 Ibid.

71 ការិយាល័យអំប៊ុស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០០៩៖ ការទទួលបានប្រជាប្រិយភាព. ប្រទេសហ្វីលីពីន. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.gov.ph/index.php?home=1&navId=Ng==&subNavId=NDg=.

និងនគរបាលជាតិហ្វីលីពីន។ ប្រការនេះនាំឲ្យមានការស៊ើបអង្កេតតាមវិធីសាស្ត្រការតាមដាន លើដំណើរជីវិតរបស់មន្ត្រី និងបុគ្គលិករដ្ឋាភិបាលចំនួន៤៣៥រូប ដោយរកឃើញនូវករណីព្រហ្មទណ្ឌចំនួន៣៩ករណី និងករណីរដ្ឋបាលចំនួន៣២ករណី [72]។ ចំនួនករណីរដ្ឋបាលសរុបដែលបានវិនិច្ឆ័យនៅក្នុងឆ្នាំ២០១១ គឺមាន ៤.៦៨០ករណី។ ប្រហែលជា២៥%នៃករណីទាំងនេះបានបញ្ចប់ដោយការដាក់ទណ្ឌកម្ម។ នៅក្នុងករណីចំនួន២៩៧ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរបំផុតត្រូវបានធ្វើឡើង គឺការបណ្តេញចេញពីអង្គភាពសេវាកម្មសាធារណៈ។ ក្នុងចំណោមអ្នកដែលត្រូវបានបណ្តេញចេញ រួមមាន ប្រធាននាយកប្រធានរដ្ឋបាល ប្រធានរដ្ឋបាលស្តីទី អនុប្រធានរដ្ឋបាលស្តីទីនៃរដ្ឋបាលរដ្ឋករទឹកមូលដ្ឋាន អតីតប្រធានក្រុមប្រឹក្សាសាជីវកម្មរបស់រដ្ឋាភិបាល និងប្រធានតំបន់នៃក្រសួងសាធារណការ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ[73]។

ក្នុងនាមជាភ្នាក់ងារគន្លឹះក្នុងការប្រឆាំងអំពើពុករលួយ ការលើកកម្ពស់ការយល់ដឹងអំពីការិយាល័យ អំប៊ុស្មាន់គឺពិតជាមានសារៈសំខាន់ណាស់។ គេហទំព័រថ្មីរបស់ការិយាល័យត្រូវបានដាក់ឲ្យដំណើរការ នៅក្នុងឆ្នាំ២០០៩ ដែលបានរៀបចំឡើងមានលក្ខណៈរៀបរយ ព័ត៌មានសម្បូរបែប និងឆ្លើយតបល្អ ជាងមុនចំពោះតម្រូវការរបស់សាធារណៈ។ ក្រៅពីគេហទំព័រ ការិយាល័យក៏មានបណ្តាញទូរស័ព្ទទូទាំងប្រទេសដើម្បីធ្វើឲ្យការិយា ល័យនេះកាន់តែខិតទៅជិតសាធារណជន និងដើម្បីជួយសម្រួលដល់ការរាយការណ៍របស់ប្រជាជនឲ្យកាន់តែមានលក្ខណៈងាយស្រួល [74]។ ការិយាល័យអំប៊ុស្មាន់ក៏ផលិត និងចែកចាយព័ត៌មាន និងសម្ភារៈសិក្សាដល់សិស្ស-និស្សិត តំណាងភ្នាក់ងាររដ្ឋាភិបាលនានា និងសាធារណជន ជារៀងរាល់ឆ្នាំស្តីពីសកម្មភាពរបស់ការិយាល័យផងដែរ។ ការិយាល័យអំប៊ុស្មាន់មានថវិកាក្នុងការផ្សព្វផ្សាយតាមទូរទស្សន៍ ការធ្វើបាឋកថាជាបន្តបន្ទាប់ទូទាំងប្រទេសស្តីពីការប្រឆាំងអំពើពុករលួយ និងការរៀបចំអនុកម្មវិធីស្តីពីអំពើពុករលួយ ដែលបង្ហាញកាន់តែច្បាស់ពីសកម្មភាពរបស់ការិយាល័យអំប៊ុស្មាន់។ នៅក្នុងខែធ្នូ ឆ្នាំ២០០៩ ការិយាល័យអំប៊ុស្មាន់ក៏បានចាប់ផ្តើមបង្កើតខិតប័ណ្ណ/ព្រឹត្តិប័ត្រផ្សព្វផ្សាយមួយទំព័រ ដើម្បីផ្តល់ព័ត៌មានកាន់តែប្រសើរជូនបុគ្គលិក និងសាធារណៈនូវវឌ្ឍនភាពថ្មីៗស្តីពីការទប់ស្កាត់អំពើពុករលួយ បទពិសោធន៍ដ៏ល្អ/ប្រវត្តិជោគជ័យ និងសេចក្តីជូនដំណឹងសំខាន់ផ្សេងៗ។ ជាចុងក្រោយ នៅក្នុងឆ្នាំ២០០៩ ការិយាល័យអំប៊ុស្មាន់បានបង្កើតឡើងនូវធម្មនុញ្ញប្រជាពលរដ្ឋ ដើម្បីសំដែងឆន្ទៈរបស់ការិយាល័យក្នុងការលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាព ខណៈដែលខ្លួនកំពុងផ្តល់នូវសេវាកម្មដ៏មានគុណភាពជូនប្រជាពលរដ្ឋ។ ធម្មនុញ្ញនេះផ្តល់នូវការណែនាំងាយស្រួលជាជំហានៗ និងសាមញ្ញ ស្តីពីនីតិវិធីក្នុងការប្រើប្រាស់សេវាកម្មអំប៊ុស្មាន់។

## ការប្រឈមចំពោះយន្តការនានា

បញ្ហាដ៏ចំបងរបស់ការិយាល័យអំប៊ុស្មាន់នៅក្នុងប្រទេសហ្វីលីពីនគឺត្រង់ថា ការិយាល័យនេះមិនមានឯករាជ្យភាពចេញពីអាជ្ញាធរអាណាព្យាបាលរបស់ខ្លួននោះទេ។ ក្នុងចំណោមការិយាល័យអំប៊ុស្មាន់ដំបូងចំនួន៥ ការិយាល័យចំនួន៣មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយអាជ្ញាធរអាណាព្យាបាលរបស់ខ្លួន[75]។ ប្រការនេះបានធ្វើឲ្យរាំងស្ទះដល់មុខងារប្រឆាំងអំពើពុករលួយរបស់ការិយាល័យ ដោយសារប្រសិនបើការិយាល័យចង់ប្រែក្លាយខ្លួនជាស្ថាប័នប្រឆាំងអំពើពុករលួយពិតប្រាកដ វាចាំបាច់ណាស់សម្រាប់ការិយាល័យអំប៊ុស្មាន់ក្នុងការ

72 ការិយាល័យអំប៊ុស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០១១៖ ការកំណត់ទិសដៅថ្មី. ប្រទេសហ្វីលីពីន. ឆ្នាំ២០១១. បានទទួលព័ត៌មាននៅខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.gov.ph/index.php?home=1&navId=Ng==&subNavId=NDg=.

73 ការិយាល័យអំប៊ុស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០១១.

74 ការិយាល័យអំប៊ុស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០០៩.

75 Roque. "អាណត្តិការងាររបស់ការិយាល័យអំប៊ុស្មាន់?"

ទទួលបានជោគជ័យជាសាធារណៈលើករណីបណ្តឹងចំពោះបុគ្គលសំខាន់នានា។ បច្ចុប្បន្ន បើទោះបីជាបណ្តឹងជាច្រើនត្រូវបានធ្វើឡើង តែមន្ត្រីជាន់ខ្ពស់តិចតួចបំផុតត្រូវបានផ្តន្ទាទោស។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៨ របស់Phillip Alston អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានសន្និដ្ឋានថា ការិយាល័យអំប៊ុដ្ស្មាន់ "បានបោះបង់ចោលឯករាជ្យភាពពីអង្គនីតិប្រតិបត្តិរបស់ខ្លួនដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ"[76]។

ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព យន្តការបណ្តឹងត្រូវជានាអំពីការដោះស្រាយករណីបណ្តឹងដែលមានលក្ខណៈឆាប់រហ័ស។ នៅក្នុងប្រទេសហ្វីលីពីន ជានិច្ចកាលករណីនេះមិនទាន់អនុវត្តបាននៅឡើយទេ។ ឧទាហរណ៍៖ ករណីឃាតកម្មដ៏ល្បីល្បាញលើអនុនាវាត្រីកងទ័ពជើងទឹក Phillip Pestano នៅលើនាវា BRP Bacolod នៅក្នុងឆ្នាំ១៩៩៥ គឺទើបតែបានដាក់ពាក្យប្តឹងនៅក្នុងអាណត្តិរបស់ប្រធានការិយាល័យអំប៊ុដ្ស្មាន់ លោកស្រីMorales នៅក្នុងឆ្នាំ២០១២ប៉ុណ្ណោះ[77]។

កន្លងមកអត្រានៃការផ្តន្ទាទោសមានកម្រិតទាបជាប្រវត្តិសាស្ត្រ ជាពិសេសការផ្តន្ទាទោសចំពោះឥស្សរជនជាន់ខ្ពស់។ មុនអាណត្តិរបស់លោកស្រី Morales ប្រធានការិយាល័យអំប៊ុដ្ស្មាន់បច្ចុប្បន្ន អត្រានៃការផ្តន្ទាទោសក្នុងអំឡុងអាណត្តិប្រធានការិយាល័យអំប៊ុដ្ស្មាន់ លោក Desertio(១៩៩៥-២០០២)និងអាណត្តិប្រធានការិយាល័យអំប៊ុដ្ស្មាន់ លោកស្រីQutierrez(២០០៥-២០១១) មានកម្រិតពី ៣,១៩% ដល់៥,៤៨% [78]។ អត្រានៃការផ្តន្ទាទោសកម្រិតទាបនេះ អាចបកស្រាយតាមរយៈប្រព័ន្ធប្រមូលផ្តុំអំណាចនៅថ្នាក់កណ្តាលកម្រិតខ្ពស់ ការិយាល័យអំប៊ុដ្ស្មាន់ទន់ខ្សោយ និងបុគ្គលិកដែលបាក់ទឹកចិត្ត[79]។ ប្រការនេះបង្កជារូបភាពអវិជ្ជមានដល់ការិយាល័យអំប៊ុដ្ស្មាន់ និងធ្វើឲ្យការិយាល័យបាត់បង់ប្រជាប្រិយភាព។ ប៉ុន្តែ បើទោះបីជាជួបប្រទះនូវការប្រឈមទាំងនេះក្តី ការិយាល័យអំប៊ុដ្ស្មាន់នៅប្រទេសហ្វីលីពីនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់ភាពជឿជាក់របស់សាធារណជន ទទួលបានអំណាចឯករាជ្យចាំបាច់មួយចំនួន និងក្រោមការដឹកនាំបច្ចុប្បន្នរបស់ប្រធានការិយាល័យអំប៊ុដ្ស្មាន់ លោកស្រី Morales ដោយអត្រានៃការផ្តន្ទាទោសមានការកើនឡើងគួរជាទីកត់សម្គាល់។

## ៥. ការប្រៀបធៀបយន្តការបណ្តឹងនានា

ផ្អែកលើការសិក្សាស្រាវជ្រាវទៅលើបណ្តាប្រទេសទាំងបីនេះ គឺបាននាំមកនូវការស្វែងយល់អំពីកត្តាជោគជ័យសំខាន់ៗ បទពិសោធន៍ និងមេរៀនជាពិសោធន៍ល្អៗជាច្រើន។

---

[76] មហាសន្និបាតសហប្រជាជាតិ. របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីតុលាការបន្ថែម សេចក្តី សង្ខេប ឬការប្រព្រឹត្តិតាមទំនើងចិត្ត. ការលើកឡើងបន្ថែមរបស់Philip Alston ការតាមដានចំពោះអនុសាសន៍របស់ប្រទេស - ហ្វីលីពីន. ក្រុមប្រឹក្សាសិទ្ធិមនុស្ស. A/HRC/១១/២/Add.៨. បានទទួលព័ត៌មាននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.ihumanrights.ph/hr-mechanism/human-rights-bodies/charter-based-bodies/special procedures/reportsrecommendations/report-of-the-special-rapporteur-on-extrajudicial-summary-or-arbitrary-executions-philip-alston/.

[77] Roque. "អាណត្តិការងាររបស់ការិយាល័យអំប៊ុដ្ស្មាន់?"

[78] Ibid.

[79] តម្លាភាព និងបណ្តាញគណនេយ្យភាព. "ការិយាល័យអំប៊ុដ្ស្មាន់៖ តើស្ថាប័នមានចំណុចខ្សោយបែបណាខ្លះ?" បណ្តាញអភិវឌ្ឍន៍ធនធានមនុស្ស. PHDR Technical/Issue Note ២០០៨/២០០៩ លេខ២. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ ពី *hdn.org.ph/wp-content/uploads/2009/05/tin02_tan.pdf.*

## ច្បាប់

គ្រប់ប្រទេសទាំងអស់ ដែលបានយកមកធ្វើការសិក្សាប្រៀបធៀប មានកំណត់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្តឹងនៅក្នុងច្បាប់របស់ខ្លួន។ នៅគ្រប់ករណីទាំងអស់ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្តឹងត្រូវបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងរដ្ឋធម្មនុញ្ញ។ ប្រទេសថៃ និងហ្វីលីពីនកំណត់យ៉ាងច្បាស់ពីតួនាទីរបស់អង្គភាពអំប៊ុដ្សមាន់នៅក្នុងដំណើរការរបស់ខ្លួន ខណៈដែលរដ្ឋធម្មនុញ្ញរបស់វៀតណាម(ឆ្នាំ២០០១) ចែងបន្ថែមអំពីការទទួលខុសត្រូវរបស់រដ្ឋក្នុងការឆ្លើយតបចំពោះបណ្តឹង និងការចោទប្រកាន់នានាប្រកបដោយប្រសិទ្ធភាព និងភាពឆាប់រហ័ស។ ប្រទេសហ្វីលីពីន វៀតណាម និងថៃក៏បានបង្កើតច្បាប់ដ៏លម្អិត ដែលគូសបញ្ជាក់ពីយន្តការនានាសម្រាប់ប្រទេសរបស់ខ្លួន(ហ្វីលីពីន៖ ច្បាប់ចែងអំពីការរៀបចំមុខងារ និងរចនាសម្ព័ន្ធនៃការិយាល័យអំប៊ុដ្សមាន់ និងចែងអំពីគោលបំណងផ្សេងទៀត(ឆ្នាំ១៩៨៩), ថៃ៖ ច្បាប់រៀបចំអង្គការស្តីពីប្រព័ន្ធអំប៊ុដ្សមាន់(ឆ្នាំ១៩៩៩), រីឯ វៀតណាម៖ ច្បាប់ស្តីពីបណ្តឹង និងការចោទប្រកាន់(ឆ្នាំ១៩៩៨))។ ប្រការនេះបញ្ជាក់ថា យន្តការដែលកំពុងពិភាក្សាទាំងនេះ នឹងមិនងាយផ្លាស់ប្តូរនៅក្នុងប្រព័ន្ធរដ្ឋាភិបាល ឬនៅក្នុងគោលនយោបាយនានា ដែលអាចជះឥទ្ធិពលដល់ប្រព័ន្ធដែលមានស្រាប់ ឬអាចផ្លាស់ប្តូរទាំងស្រុងនៃវិសាលភាពយន្តការទាំងនេះឡើយ។

## មុខងារ

ប្រទេសថៃ និងហ្វីលីពីនផ្តល់នូវឧទាហរណ៍ល្អៗចំពោះប្រភេទនៃមុខងារដែលយន្តការបណ្តឹងគួរទទួលបាន ប៉ុន្តែបញ្ហាទាំងនេះតែងតែមិនទទួលបានការគាំទ្រនោះទេនៅក្នុងការអនុវត្តជាក់ស្តែង។ នៅក្នុងប្រទេសវៀតណាម បណ្តឹងជាក្រុម និងបណ្តឹងដែលមិនមានលក្ខណៈស្របតាមបទដ្ឋាន ឬក្រៅផ្នែករដ្ឋបាលត្រូវបានហាមឃាត់។ នៅក្នុងប្រទេសថៃ ខណៈដែលប្រជាពលរដ្ឋមិនត្រូវបានហាមឃាត់ចំពោះប្រភេទនៃបណ្តឹង បណ្តឹងពាក់ព័ន្ធនឹងការរំលោភអំណាចរបស់មន្ត្រីសាធារណៈ គឺមិនត្រូវបានយកចិត្តទុកដាក់ជាប្រព័ន្ធតែម្តង។ នៅក្នុងប្រទេសហ្វីលីពីន បើទោះបីជាមានយន្តការបណ្តឹងចាប់តាំងពីកម្រិតថ្នាក់ក្រោមជាតិ តែការិយាល័យអំប៊ុដ្សមាន់យកចិត្តទុកដាក់ជាចំបងតែទៅលើបណ្តឹងពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់ប៉ុណ្ណោះ។ ប៉ុន្តែការិយាល័យនេះមានអំណាចធំទូលាយក្នុងការស៊ើបអង្កេត ចោទប្រកាន់ ផ្តល់ជំនួយជាសាធារណៈ និងទប់ស្កាត់អំពើពុករលួយ។ ការិយាល័យអាចប្រែក្លាយបណ្តឹងទៅជាករណីបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែការធ្វើបែបនេះទាមទារពេលវេលាយូរ ហេតុដូចនេះហើយចំណុចនេះមិនត្រូវបានយកមកអនុវត្តញឹកញាប់ក្នុងការឆ្លើយតបបណ្តឹងនោះទេ។

## ការពង្រឹងកាអនុវត្ត

លទ្ធភាពក្នុងការពង្រឹងការអនុវត្តវិធានការណ៍ក្រោយការស៊ើបអង្កេត មានលក្ខណៈខុសប្លែកគ្នាច្រើនទៅតាមប្រទេសនីមួយៗ ហើយចំណុចនេះប្រទេសថៃ និងហ្វីលីពីនជាប្រទេសនាំមុខគេ។ នៅប្រទេសវៀតណាម អាជ្ញាធរទទួលបណ្តឹងអាចមានលទ្ធភាពត្រឹមតែផ្តល់អនុសាសន៍ចំពោះការដាក់ទណ្ឌកម្មដែលអាចមាន ជូនដល់ការិយាល័យ ឬប្រធានរបស់មន្ត្រីរងការចោទប្រកាន់តែប៉ុណ្ណោះ។ នៅប្រទេសវៀតណាម អង្គភាព/បុគ្គលដែលរងការចោទប្រកាន់ ត្រូវបញ្ជូនរបាយការណ៍ស្តីពីវិធានការណ៍នានាដែលពួកគេបានយកមកប្រើប្រាស់ក្នុងការដោះស្រាយបណ្តឹង ប៉ុន្តែការិយាល័យផ្ទាល់ពុំមានអំណាចក្នុងការចាប់បង្ខំឲ្យអនុវត្តតាមនោះទេ។ នៅក្នុងប្រទេសថៃ ការិយាល័យអំប៊ុដ្សមាន់អាចចាត់វិធានការណ៍លើករណីជាច្រើន មានដូចជា ការរំលោភអំណាច ភាពអសកម្មរបស់ប្រព័ន្ធរដ្ឋបាល និងធម្មានុរូបភាពតាមរដ្ឋធម្មនុញ្ញនៃសេចក្តីសម្រេចចិត្ត។ លើសពីនេះ ក៏នៅមាន

មធ្យោបាយមានលក្ខណៈគ្រប់គ្រាន់ផ្សេងទៀត ដើម្បីអនុញ្ញាតឲ្យប្រើប្រាស់នូវ វិធីសាស្ត្រស៊ើបអង្កេតមួយចំនួនក្នុងការដោះស្រាយករណីបណ្ដឹងផងដែរ។ ផ្ទុយទៅវិញ ការិយាល័យអំប៊ុដ្សមាន់មានអំណាចក្នុងការដាក់ទណ្ឌកម្មដែលរួមមាន ការដកហូតប្រាក់ត្រូវទូទាត់ ការបណ្ដេញចេញ ការបាត់បង់សិទ្ធិទទួលផលប្រយោជន៍ និងការដាក់ពិន័យលើភាគីប្រព្រឹត្តិល្មើស[80]។ នៅប្រទេសហ្វីលីពីន ការិយាល័យអំប៊ុដ្សមាន់មានអំណាចប្រហាក់ប្រហែលនឹងតុលាការ និងអាចចាប់បង្ខំឲ្យអនុវត្តនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បើទោះបីជាប្រការនេះជាញឹកញាប់ត្រូវអាស្រ័យលើឋានៈផ្នែកនយោបាយរបស់អ្នកដែលត្រូវបានចោទប្រកាន់ក្ដី។ កន្លងមក ជនជាប់ចោទដែលមានទំនាក់ទំនងផ្នែកនយោបាយល្អតែងតែរួចផុតពីការដាក់ពិន័យ[81]។

## ឯករាជ្យភាព

ច្បាប់ ដែលបានបង្កើតឡើងដើម្បីគាំទ្រដល់យន្តការបណ្ដឹង ក៏ត្រូវតែជានាអំពីកត្តាគន្លឹះសម្រាប់ភាពជោគជ័យរបស់ខ្លួន៖ ឯករាជ្យភាពពីប្រព័ន្ធរដ្ឋបាល។ លើសពីនេះ វាក៏ចាំបាច់សម្រាប់ការបង្ហាញពី ឯករាជ្យភាពរបស់ខ្លួនចំពោះសាធារណជនផងដែរ។ នៅគ្រប់ប្រទេសទាំងអស់ ឯករាជ្យភាពគឺជាបញ្ហាកង្វល់ដែលមានលក្ខណៈខុសប្លែកពីគ្នាទៅតាមប្រទេសនីមួយៗ ដែលចំណុចនេះប្រទេសថៃប្រហែលអាចជាឧទាហរណ៍ដ៏បំផុតចំពោះបញ្ហាឯករាជ្យភាពនៃយន្តការដោះស្រាយបណ្ដឹង។ នៅក្នុងប្រទេសវៀតណាម យន្តការបណ្ដឹងមិនមានឯករាជ្យភាពពេញលេញនោះទេ ដែលជាទូទៅ ប្រព័ន្ធរដ្ឋបាលទទួលខុសត្រូវដោះស្រាយបណ្ដឹង ហើយអង្គភាពអធិការកិច្ចក៏មិនមានឯករាជ្យភាពពីប្រព័ន្ធរដ្ឋបាលនោះដែរ។ នៅក្នុងប្រទេសថៃ ការិយាល័យអំប៊ុដ្សមាន់ជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដោយសាររដ្ឋាភិបាលពេលខ្លះមិនគាំទ្រដល់ការិយាល័យអំប៊ុដ្សមាន់និងសកម្មភាពរបស់ការិយាល័យនេះទេ ហើយការិយាល័យនេះក៏ត្រូវស្នើសុំថវិកាពីសភា ដែលទាំងនេះបានជះឥទ្ធិពលដល់ឯករាជ្យភាពផ្នែកថវិការបស់ការិយាល័យផងដែរ។ លើសពីនេះ ការបញ្ជាក់មួយចំនួនបង្ហាញថា បណ្ដឹងនានាពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ត្រូវបានរាំងស្ទះ[82]។ នៅក្នុងប្រទេសហ្វីលីពីន ការិយាល័យអំប៊ុដ្សមាន់ជាយូរយារមកហើយត្រូវបានមើលឃើញថាមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយអំណាចគ្រប់គ្រងរដ្ឋ និងមិនអាចធ្វើការចោទប្រកាន់ប្រកបដោយប្រសិទ្ធិភាពទៅលើករណីបណ្ដឹងសំខាន់ៗនោះទេ តែស្ថានភាពនេះប្រហែលជាអាចផ្លាស់ប្ដូរក្រោមការដឹកនាំរបស់ប្រធានការិយាល័យអំប៊ុដ្សមាន់បច្ចុប្បន្ន លោកស្រី Morales[83]។

## ដំណើរការនៃពាក្យបណ្ដឹង

មធ្យោបាយនានាដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្ដឹង និងរយៈពេលក្នុងការដោះស្រាយបណ្ដឹងគឺជាបញ្ហាគន្លឹះ។ យន្តការនៅក្នុងប្រទេសវៀតណាមផ្ដល់លទ្ធភាពជូនប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្ដឹង តាមរយៈការមកដោយផ្ទាល់ បើទោះបីជានីតិវិធីនេះពុំបានកំណត់ច្បាស់លាស់ក្ដី។ បណ្ដឹងក៏អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬបញ្ជូនតាមរយៈអ្នកតំណាងរបស់រដ្ឋនៅថ្នាក់មូលដ្ឋានផងដែរ។ ប៉ុន្តែ មន្ត្រីនានាត្រូវបានដាក់កំហិតឲ្យជួបពិភាក្សាជាមួយសាធាណៈឲ្យបានទៀងទាត់នៅគ្រប់កម្រិតថ្នាក់ក្រោមជាតិ ដើម្បីទទួលបានព័ត៌មានស្ដីពីបណ្ដឹងរបស់ពួកគេ ហើយការកំណត់នេះពិតជាមានអត្ថប្រយោជន៍ណាស់។ ប្រទេសថៃបង្ហាញពីពិសោធន៍ដ៏រឹងមាំអំពីមធ្យោបាយផ្សេងៗដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្ដឹងបាន។ មានវិធីសាស្ត្រចំនួន៦

[80] ហ្វីលីពីន. ច្បាប់ស្ដីពីអំប៊ុដ្សមាន់.

[81] Roque. "អាណត្តិរបស់ការិយាល័យអំប៊ុដ្សមាន់?

[82] Chareonpanij. "អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម".

[83] Roque. "អាណត្តិរបស់ការិយាល័យអំប៊ុដ្សមាន់?

ផ្សេងគ្នាសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ក្នុងការដាក់ពាក្យបណ្តឹងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយបណ្តឹងដែលទទួលបានត្រូវធ្វើការដោះស្រាយក្នុងអំឡុងរយៈពេល៦ខែ។ នៅក្នុងប្រទេសហ្វីលីពីន បុគ្គល ក្រុម និងសាជីវកម្មនានាអាចដាក់ពាក្យបណ្តឹង ហើយការដាក់ពាក្យបណ្តឹងនេះអាចធ្វើឡើងតាមរយៈការមកដោយផ្ទាល់ ឬតាមប្រព័ន្ធអ៊ិនធើណេត។ បើទោះបីជា ការិយាល័យអំប៊ូស្មាន់ត្រូវសម្រេចចិត្តឲ្យបានឆាប់រហ័ស អំពីការស៊ើបអង្កេតលើបណ្តឹងក្តី តែជាក់ស្តែង បណ្តឹងអាចត្រូវការរយៈពេលយូរក្នុងការបញ្ចប់ ជាពិសេសករណីបណ្តឹងសំខាន់ៗ។

## ការយល់ដឹងជាសាធាណៈ

ការយល់ដឹងជាសាធារណៈអំពីដំណើរការបណ្តឹងគឺជាបញ្ហានៅក្នុងប្រទេសវៀតណាម ដោយសារដំណើរការនេះមាននីតិវិធីស្មុគស្មាញ និងស្រដៀងគ្នាច្រើន ដែលធ្វើឲ្យសាធារណជនមានការភ័ន្តច្រឡំ។ កង្វះខាតមូលនិធិគាំទ្រ និងសមត្ថភាពក៏អាចកាត់បន្ថយការទទួលបានព័ត៌មាន និងការយល់ដឹងរបស់សាធារណៈអំពីដំណើរការនៃបណ្តឹង ជាពិសេសប្រការនេះគឺជាបញ្ហាដែលកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជា វៀតណាម និងក្នុងកម្រិតតិចជាងនៅក្នុងប្រទេសថៃ។ ប្រទេសហ្វីលីពីនសម្រេចបានជោគជ័យ ថ្មីៗគួរឲ្យកត់សម្គាល់តាមរយៈយុទ្ធនាការអប់រំជាសាធារណៈ និងការបង្កើនការផ្សព្វផ្សាយព័ត៌មាន ស្តីពីការិយាល័យអំប៊ូស្មាន់។ ជារួម កង្វះខាតការយល់ដឹងរបស់សាធារណៈ ក៏ដូចជា ពេលវេលាឆ្លើយតបយឺតយ៉ាវ អាចកាត់បន្ថយការទទួលបានព័ត៌មាន និងធម្មានុរូបភាពនៃយន្តការបណ្តឹង។

## ការចូលរួមរបស់សភាក្នុងការដោះស្រាយបណ្តឹង

ពាក់ព័ន្ធនឹងការចូលរួមរបស់សភាក្នុងការដោះស្រាយបណ្តឹង នៅក្នុងប្រទេសថៃ ការដាក់ពាក្យបណ្តឹងអាចធ្វើឡើងតាមរយៈអ្នកតំណាងជាប់ឆ្នោតនៅក្នុងសភា។ ប៉ុន្តែ ប្រការនេះអាចបង្កជាទំនាស់ផលប្រយោជន៍ ដោយសារតែការិយាល័យអំប៊ូស្មាន់ ក៏អាចស៊ើបអង្កេតបណ្តឹងដែលចោទប្រកាន់ចំពោះសមាជិកសភាផងដែរ ហើយជាងនេះទៅទៀត ព្រឹទ្ធសភាថៃជាអ្នកស្នើឡើងនូវសមាសភាពមន្ត្រីអំប៊ូស្មាន់ទាំងនេះ ហើយសភាជាអ្នកឯកភាពលើថវិការបស់ការិយាល័យទៀតផង។ ការដាក់ពាក្យបណ្តឹងតាមរយៈសភាទៅកាន់ការិយាល័យអំប៊ូស្មាន់នៅក្នុងប្រទេសថៃ ក៏ត្រូវបានយកមកអនុវត្តន៍នៅក្នុងប្រទេសកម្ពុជាផងដែរ។ គណៈកម្មការទី១ របស់សភា[84]នៅកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលបណ្តឹងពីប្រជាជននៅមូលដ្ឋានរបស់ខ្លួន ក្នុងអំឡុងពេលនៃការអនុវត្តមុខងាររបស់ខ្លួន និងក្នុងការផ្តល់ជាអនុសាសន៍ទៅលើសេចក្តីព្រាងពាក់ព័ន្ធនឹងវិស័យក្រោមយុត្តាធិការរបស់ខ្លួន។ យោងតាមសេចក្តីសម្រេចដែលធ្វើឡើងដោយគណៈកម្មការ គណៈកម្មការមានសិទ្ធិក្នុងការស្នើឲ្យមានការបំភ្លឺ និងវិធានការណ៍តាមដានពីសំណាក់អង្គភាពពាក់ព័ន្ធចំពោះពាក្យបណ្តឹងដែលបានទទួល[85]។

---

[84] អង្គការCOMFREL. (ឆ្នាំ២០១៣). បញ្ជីរាយនាមនៃរដ្ឋសភាកម្ពុជាអាណត្តិទី៤ (២០០៨-២០១៣). ភ្នំពេញ. ឆ្នាំ២០០៩. ទំព័រ១៥.

[85] គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា. "អង្គភាពសិទ្ធិមនុស្សថ្នាក់ជាតិនៅកម្ពុជា". CCHR Institutions Series. ភាគ ៣. ខែមីនា ឆ្នាំ២០១២. បានទទួលព័ត៌មាននៅខែមិថុនា ឆ្នាំ២០១៣ ពី http://www.cchrcambodia.org/admin/media/factsheet/factsheet/english/2012_03_30_CCHR_Institutions_Series_Factsheet_National_Human_Rights_Bodies_ENG.pdf.

# សេចក្តីសន្និដ្ឋាន

ការអនុវត្តនូវគោលនយោបាយវិមជ្ឈការនៅកម្ពុជា មួយផ្នែកត្រូវពឹងផ្អែកលើយន្តការគណនេយ្យភាពដ៏សមស្រប។ ដើម្បីធានាថា រដ្ឋបាលសាធារណៈបំពេញការងាររបស់ខ្លួនបានល្អនៅក្នុងការអនុវត្តន៍នីតិរដ្ឋ គណនេយ្យភាព និងតម្លាភាព រដ្ឋបាលសាធារណៈត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយត្រឹមត្រូវ និងរួមមានការផ្តល់លទ្ធភាពជូនសាធារណៈក្នុងការដោះស្រាយទុក្ខលំបាករបស់ខ្លួនផងដែរ។ ហេតុដូចនេះ វាពិតជាចាំបាច់ណាស់ដែលយន្តការបណ្តឹងត្រូវមានអំណាចគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ អំណាចទាំងនេះត្រូវកំណត់នៅក្នុងច្បាប់ ឬបទបញ្ញាផ្នែករដ្ឋបាលពាក់ព័ន្ធ ដូចជា អនុក្រឹត្យជាដើម[86]។

មានមេរៀនជាច្រើនដែលអាចទទួលបានពីករណីផ្សេងៗ ដែលបានធ្វើការសិក្សានៅក្នុងឯកសារនេះ។ យន្តការបណ្តឹងត្រូវមានភាពរឹងមាំ ឯករាជ្យភាព និងកំណត់ឲ្យបានច្បាស់លាស់។ ប្រការនេះតម្រូវឲ្យមានច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលកំណត់អំពីវិសាលភាពនៃការអនុវត្ត និងសមត្ថកិច្ចរបស់ស្ថាប័នទទួលបន្ទុកដោះស្រាយបណ្តឹង។ លើសពីនេះ ការដាក់ដែនកំណត់ចំពោះប្រភេទនៃបណ្តឹងកាន់តែតិច ស្ថាប័ននឹងកាន់តែមានប្រសិទ្ធភាព និងធម្មានុរូបភាព។ ដំណើរការនៃបណ្តឹងដែលមានលក្ខណៈប្រសើរ និងងាយយល់ជាងមុនអាចផ្តល់អត្ថប្រយោជន៍ដល់ទាំងសាធារណៈ និងប្រព័ន្ធរដ្ឋបាល។ ការធ្វើឲ្យប្រសើរឡើងនូវដំណើរការនៃការដាក់ពាក្យបណ្តឹង និងដំណើរការនៃការស៊ើបអង្កេត នឹងជួយដល់ការយល់ដឹងជាសាធារណៈ និងការកាត់បន្ថយចំណាយ។ ប្រការនេះគួរគាំទ្រដោយយុទ្ធនាការលើកកម្ពស់ការយល់ដឹងរបស់សាធារណៈនៅក្នុងទម្រង់ផ្សេងៗ។ សរុបមក ដើម្បីធានាបាននូវភាពជោគជ័យ ស្ថាប័នដែលគាំទ្រដល់យន្តការបណ្តឹងត្រូវទទួលបានមូលនិធិគាំទ្រសមស្រប មានបុគ្គលិក និងធនធានគ្រប់គ្រាន់ និងមានបុគ្គលិកដែលយល់អំពីស្ថាប័ន និងតួនាទីរបស់ខ្លួន ដើម្បីឆ្លើយតបចំពោះចម្ងល់របស់សាធារណៈ និងដោះស្រាយបណ្តឹងដែលទទួលបាន។

ជំហានជាក់លាក់ដែលកម្ពុជាអាចយកមកពិចារណាដើម្បីលើកកម្ពស់យន្តការបណ្តឹងរបស់ខ្លួន រួមមាន៖ ការអនុម័តច្បាប់ដែលបង្កើតនូវអង្គភាព/ស្ថាប័នយន្តការបណ្តឹងឯករាជ្យតែមួយគត់ យុទ្ធនាការអប់រំជាសាធារណៈ ដែលរួមបញ្ចូលទាំងប្រភពព័ត៌មានលើប្រព័ន្ធអ៊ីនធើណេតពាក់ព័ន្ធនឹងដំណើរការនៃយន្តការបណ្តឹង និងការធានាអំពីការគាំទ្រផ្នែកមូលនិធិ និងធនធានគ្រប់គ្រាន់ចំពោះស្ថាប័នគាំទ្រដំណើរការបណ្តឹង ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានពេញលេញលើបណ្តឹងនានា និងដើម្បីសម្រេចឲ្យបាននូវការឆ្លើយតបដែលចំណាយពេលវេលាខ្លីសមស្របចំពោះបណ្តឹងដែលទទួលបាន។ នៅកម្ពុជា កិច្ចប្រជុំជាប្រចាំរវាងមន្ត្រីនៃយន្តការបណ្តឹងនានាក្នុងការដោះស្រាយបណ្តឹង គួរយកមកពិចារណា ដូចជាករណីនៅប្រទេសវៀតណាម។ ជាពិសេស វាចាំបាច់ចំពោះករណីបណ្តឹងដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់អង្គភាពទទួលពាក្យបណ្តឹងច្រើន។

[86] សមាគមអំប៊ុដ្សម៉ាន់របស់សហរដ្ឋអាមេរិច. "ស្តង់ដាអំប៊ុដ្សម៉ាន់របស់រដ្ឋាភិបាល". Ron Adcock, William Angrick II និង Becky Chia. ទីក្រុងDayton រដ្ឋOhio. ឆ្នាំ២០០៣. បានទទួលព័ត៌មាននៅថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៣ ពី *www.usombudsman.org/documents/PDF/.../USOA_STANDARDS.pdf.*

# បញ្ជីនៃប្រភពឯកសារ


ANSA. (ឆ្នាំ២០១១). សារៈសំខាន់នៃការវិវត្តន៍របស់គណនេយ្យភាពសង្គមក្នុងប្រទេសកម្ពុជា. អាស៊ីប៉ាស៊ីហ្វិកខាងកើត.

Ayres D និង Macleod K. (ឆ្នាំ២០០៤). សៀវភៅស្តីពីភាពជាដៃគូ. Pact Cambodia.

Burke A និងNil V. (ឆ្នាំ២០០៤). ជម្រើសសម្រាប់ការបង្កើនគណនេយ្យភាពសង្គមនៅកម្ពុជា. DFID និងធនាគារពិភពលោក.

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា. "អង្គភាពសិទ្ធិមនុស្សថ្នាក់ជាតិនៅកម្ពុជា". CCHR Institutions Series. ភាគ ៣. ខែមីនា ឆ្នាំ២០១២. បានទទួលព័ត៌មាននៅខែមិថុនា ឆ្នាំ២០១៣ ពី http://www.cchrcambodia.org/admin/media/factsheet/factsheet/english/2012_03_30_CCHR_Institutions_Series_Factsheet_National_Human_Rights_Bodies_ENG.pdf.

អង្គការCare. (ឆ្នាំ២០០៦). អង្គការ Care International ករណីសិក្សាអំពីយន្តការបណ្តឹងនៅកម្ពុជា.

Chareonpanij Siracha. "អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមនៃយន្តការ និងប្រព័ន្ធដោះស្រាយបណ្តឹងនានាប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព". ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃ ទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.

អង្គការCOMFREL. (ឆ្នាំ២០១៣). បញ្ជីរាយនាមនៃរដ្ឋសភាកម្ពុជាអាណត្តិទី៤ (២០០៨-២០១៣). ភ្នំពេញ ឆ្នាំ២០០៩.

អង្គការCOMFREL. (ឆ្នាំ២០០៧). ការវាយតម្លៃ និងរបាយការណ៍ចុងក្រោយស្តីពី ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០០៧.

អំប៊ុដ្សម៉ាន់នៃប្រព័ន្ធCommonwealth. (ឆ្នាំ២០០៩). វិធីសាស្រ្តណែនាំអំពីការអនុវត្តល្អៗដើម្បីដោះស្រាយពាក្យបណ្តឹង.

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌. (ឆ្នាំ២០០៩). ការវាយតម្លៃបឋមស្តីពីអំប៊ុដ្សម៉ាន់ និងប្រព័ន្ធទទួលពាក្យបណ្តឹងផ្សេងទៀតនៅកម្ពុជា.

លោកដោក ណារ៉េត លោកហួត លាភពិសិដ្ឋ និង លោកជា វ៉ាន់ដា. បទសម្ភាសន៍ដោយលោកស្រីតុប ដារី. ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២. កំណត់ហេតុបទសម្ភាសន៍.

Evans H, Ngin Ch, Lang H និងMin M. (ឆ្នាំ២០១០). ការវាយតម្លៃចុងក្រោយនៃគម្រោង PSDD របស់ UNDP.

គម្រោងកសាងសមត្ថភាពបន្ទាន់. (ឆ្នាំ២០០៧). ការប៉ាន់ស្មានអំពីផលប៉ះពាល់ និងគណនេយ្យភាពក្នុងស្ថានភាពបន្ទាន់. The Good Enough Guide.

EIC. (ឆ្នាំ២០១០). របាយការណ៍ស្តីពីការសិក្សាលើកទីពីរលើការពេញចិត្តរបស់ប្រជាពលរដ្ឋតាមឃុំ/សង្កាត់គោលដៅនៃគម្រោង LAAR.

Eng N និងCraig D. (ឆ្នាំ២០០៩). គណនេយ្យភាព និងការគ្រប់គ្រងធនធានមនុស្សតាមការធ្វើវិមជ្ឈការនៅកម្ពុជា. ឯកសារការងាររបស់ CDRI លេខ ៤០.

Graham P. (ឆ្នាំ២០១០). របាយការណ៍ចុងក្រោយស្តីពីការបន្តកិច្ចសន្យា សម្រាប់បង្កើតសៀវភៅស៊ើបអង្កេតបណ្តឹង និងវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមការងារគណនេយ្យភាពក្នុងការដាក់បញ្ចូលនូវការវាយតម្លៃរបស់ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តនិងជាតិ និងយន្តការបណ្តឹងរបស់ខ្លួន. NCDD.

Grimsditch M និងHenderson N. (ឆ្នាំ២០០៩). ពុំមានចំណងជើង៖ ភាពអសន្តិសុខ និងវិសមភាពនៃសិទ្ធិកាន់កាប់ក្នុងវិស័យដីធ្លីនៅកម្ពុជា. ស្ថានឆ្លងកាត់ព្រំដែនអាស៊ីអាគ្នេយ៍ - ដោយមជ្ឈមណ្ឌលស្តីពីសិទ្ធិមានលំនៅដ្ឋាន និងការបណ្តេញចេញ. សេវាជនភៀសខ្លួនយេស៊ូស.

Gruber R និងKhlok D. (ឆ្នាំ២០០៩). អំប៊ុដស្មាន់ និងប្រព័ន្ធទទួលពាក្យបណ្តឹងផ្សេងទៀត. GTZ.

Hammer M និងCumming L. (ឆ្នាំ២០១១). លទ្ធផលនៃការសិក្សាអំពីគណនេយ្យភាពឆ្នាំ២០១១/២០១២. ធនាគារពិភពលោក.

Heng S, Kim S និងSo S. (ឆ្នាំ២០១១). អភិបាលកិច្ចតាមបែបវិមជ្ឈការក្នុងគោលនយោបាយចម្រុះ៖ កំណែទម្រង់វិមជ្ឈការដល់ថ្នាក់មូលដ្ឋាននៅកម្ពុជា. ឯកសារការងាររបស់ CDRI លេខ ៦៣.

Hoang Ngoc Giao. "យន្តការដោះស្រាយបណ្តឹងផ្នែករដ្ឋបាលនៅប្រទេសវៀតណាម៖ ការប្រឈម និងដំណោះស្រាយ". អង្គការមូលនិធិអាស៊ី និងវិទ្យាស្ថានគោលនយោបាយ ច្បាប់ និងការអភិវឌ្ឍ. ខែសីហា ឆ្នាំ២០០៩.

Horng Vuthy និង Craig David. "គណនេយ្យភាព និងការធ្វើផែនការតាមបែបវិមជ្ឈការនៅកម្ពុជា". វិទ្យាស្ថានអភិវឌ្ឍធនធានកម្ពុជា. លំដាប់ឯកសារការងារ លេខ៩. ខែកក្កដា ឆ្នាំ២០០៨. បានទទួលព័ត៌មាននៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ ពី *www.cdri.org.kh/webdata/download/wp/wp39e.pdf*.

Hughes S និងKim S ព្រមទាំងជំនួយការAnn S. (ឆ្នាំ២០០៤). ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងជម្លោះនៅកម្ពុជា៖ ការសិក្សាប្រៀបធៀបអំពីការបោះឆ្នោតទាំងបីលើកនៅកម្ពុជា. ឯកសារការងាររបស់ CDRI លេខ ៣០.

"ការកំណត់អំពីបញ្ហាកង្វល់របស់ប្រជាជនពីលំហូរពាក្យបណ្តឹងប្រចាំថ្ងៃ និងការចូលរួមក្នុងការលើកកម្ពស់ជាប្រព័ន្ធ". ឯកសារដែលបានធ្វើបទបង្ហាញនៅសិក្ខាសាលាលើកទី១២ របស់សមាគមអំប៊ុដស្មាន់ អាស៊ី នៅប្រទេស

ជប៉ុន. ថ្ងៃទី៥-៨ ខែធ្នូ ឆ្នាំ២០១១. បានទទួលព័ត៌មាននៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ ពី www.soumu.go.jp/main_content/000144334.pdf.

Knowles J N. (ឆ្នាំ២០០៧). របាយការណ៍ចុងក្រោយ-ការវាយតម្លៃរបស់ក្រុមការងារគណនេយ្យភាព. NCDD.

Kim S និងOjendal J. (ឆ្នាំ២០០៧). តើកន្លែងណាជាចំណុចប្រសព្វរវាងវិមជ្ឈការនិងប្រជាធិបតេយ្យ៖ សង្គមស៊ីវិល រដ្ឋបាលមូលដ្ឋាន និងគណនេយ្យភាពនៅកម្ពុជា. ឯកសារការងាររបស់ CDRI លេខ ៣៥.

Mansfield C និង Macleod K. (ឆ្នាំ២០០៤). ក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិល. Pact Cambodia.

Meerkerk D, Hean S និង Lanjouw S. (ឆ្នាំ២០០៨). ការសិក្សាអំពីទស្សនៈរបស់ប្រជាពលរដ្ឋ និង ក្រុមប្រឹក្សា ស្តីពីក្រុមប្រឹក្សាឃុំ/សង្កាត់. មជ្ឈមណ្ឌលដើម្បីការសិក្សាជាន់ខ្ពស់.

Morales Conchita Carpio. "ប្រព័ន្ធអំប៊ុដ្សមាន់៖ ករណីរបស់ប្រទេសហ្វីលីពីន". ឯកសារដែលបានធ្វើ បទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.

MONASRI. (ឆ្នាំ២០០៨). តម្រូវការគម្រោងសំណើសម្រាប់អភិបាលកិច្ចល្អ (ការផ្សព្វផ្សាយច្បាប់ និងការដោះស្រាយពាក្យបណ្តឹង).

NCDD. (ឆ្នាំ២០១០). កម្ពុជា៖ ការវិនិយោគនៅទីជនបទ និងគម្រោងអភិបាលកិច្ចមូលដ្ឋាន (RILGP).

NCDD. (ឆ្នាំ២០០៩). នីតិវិធីនៃការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់ក្រុមការងារគណនេយ្យភាព (ជាភាសាខ្មែរ).

Nitithanprapas Panit. "ការដោះស្រាយបណ្តឹងប្រចាំថ្ងៃឆ្ពោះទៅវិធីសាស្ត្រដោះស្រាយជាប្រព័ន្ធមួយ៖បទពិសោធន៍អំពីការងារអំប៊ុដ្សមាន់របស់ប្រទេសថៃ". ឯកសារដែលបានធ្វើបទបង្ហាញនៅសិក្ខាសាលាលើកទី១២ របស់សមាគមអំប៊ុដ្សមាន់អាស៊ី នៅប្រទេសជប៉ុន. ថ្ងៃទី៥-៨ ខែធ្នូ ឆ្នាំ២០១១. បានទទួលព័ត៌មាននៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.soumu.gov.jp/main_content.

Nguyen Duc Hanh. "ការកំណត់អំពីបញ្ហាកង្វល់របស់ប្រជាជនពីលំហូរពាក្យបណ្តឹងប្រចាំថ្ងៃ និងការចូលរួមក្នុងការលើកកម្ពស់ជាប្រព័ន្ធ". មន្ត្រីអធិការកិច្ចរបស់រដ្ឋាភិបាលវៀតណាម. បទបង្ហាញនៅក្នុង កិច្ចប្រជុំលើកទី៥ នៃសិក្ខាសាលាលើកទី១២របស់សមាគមអំប៊ុដ្សមាន់អាស៊ី នៅប្រទេសជប៉ុន. ថ្ងៃទី ៥-៨ ខែធ្នូ ឆ្នាំ២០១១.

ព្រះរាជាណាចក្រថៃ. ច្បាប់រៀបចំអង្គការស្តីពីអំប៊ុដ្សមាន់. B.E២៥៥២. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/7_2.asp.

Menzel Jorg. "យន្តការ និងការដោះស្រាយពាក្យបណ្តឹងប្រជាពលរដ្ឋនៅប្រទេសអាល្លឺម៉ង់". ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.

វចនានុក្រម Merriam-Webster. នៅលើប្រព័ន្ធអ៊ីនធើណេត. បានទទួលព័ត៌មាននៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០១៣ ពី http://www.merriam-webster.com/dictionary/ombudsman.

ការិយាល័យអំប៊ូស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០០៩៖ ការទទួលបានប្រជាប្រិយភាព. ប្រទេសហ្វីលីពីន. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.gov.ph/index.php?home=1&navId=Ng==&subNavId=NDg=.

ការិយាល័យអំប៊ូស្មាន់របស់ប្រទេសហ្វីលីពីន. របាយការណ៍ប្រចាំឆ្នាំ២០១១៖ ការកំណត់ទិសដៅថ្មី. ប្រទេសហ្វីលីពីន. ឆ្នាំ២០១១. បានទទួលព័ត៌មាននៅខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.gov.ph/index.php?home=1&navId=Ng==&subNavId=NDg=.

ការិយាល័យអំប៊ូស្មាន់របស់ថៃ. "សកម្មភាពនានា៖ វិធីសាស្ត្រដោះស្រាយករណីបណ្តឹង". បានទទួលព័ត៌មាននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/5_1.asp.

ការិយាល័យអំប៊ូស្មាន់របស់ថៃ. "បណ្តឹងនានា៖ ឧទាហរណ៍នៃករណីបណ្តឹង". បានទទួលព័ត៌មាននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ពីhttp://www.ombudsman.go.th/10/eng/sample_complaints.asp.

ការិយាល័យអំប៊ូស្មាន់របស់ថៃ. "នីតិវិធីដាក់ពាក្យបណ្តឹង". បានទទួលព័ត៌មាននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ពី http://www.ombudsman.go.th/10/eng/howtocomplaint.asp.

Ojendal J និង Kim S. (២០១១). ប្រជាធិបតេយ្យនីយកម្មពិតនៅកម្ពុជា? ការពិនិត្យដាក់ស្តែងអំពីសក្តានុពលនៃកំណែទម្រង់វិមជ្ឈការ. ICLD(មជ្ឈមណ្ឌលអន្តរជាតិដើម្បីប្រជាធិបតេយ្យនៅមូលដ្ឋានរបស់ស៊ុយអែដ).

ប្រព័ន្ធអំប៊ូស្មាន់នៅអូស្ត្រាលីភាគខាងលិច. (ឆ្នាំ២០១០). គោលការណ៍ណែនាំស្តីពីការដោះស្រាយពាក្យបណ្តឹង.

Pak K និង Craig D. (ឆ្នាំ២០០៨). គណនេយ្យភាព និងការគ្រប់គ្រងចំណាយសាធារណៈតាមបែបវិមជ្ឈការនៅកម្ពុជា. ឯកសារការងាររបស់ CDRI លេខ៣៨.

Pak K, Hong V, Eng N, Ann S, Kim S, Knowles Noelle J, និង Craig D. (ឆ្នាំ២០០៧). គណនេយ្យភាព និងកំណែទម្រង់លំនៅលបែបទំនើបនៅកម្ពុជា៖ រំលឹកទ្រឹស្តីសំខាន់ៗ. ឯកសារការងាររបស់ CDRI លេខ៣៤.

Pak K, Hong V, Ann S និង Ngo Ngoun Th. (ឆ្នាំ២០០៥). ការពង្រឹងអភិបាលកិច្ចថ្នាក់ខេត្តនៅក្នុងការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា៖ គណនេយ្យភាពក្នុងប្រព័ន្ធកំណែទម្រង់គ្រប់គ្រងបែបថ្មី. CDRI.

សាធារណៈរដ្ឋហ្វីលីពីន. ច្បាប់ដែលចែងអំពីការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ការិយាល័យអំប៊ូស្មាន់ និងចែងអំពីគោលបំណងផ្សេងទៀត. R.A.៦៧៧០. ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៨៩. បានទទួលព័ត៌មាននៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ពី *www.doj.gov.ph/files/6770.pdf.*

សាធារណរដ្ឋហ្វីលីពីន. រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋហ្វីលីពីន. R.A.៦៧៧០. ឆ្នាំ១៩៨៧. បានទទួលព័ត៌មាន នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣ ពី http://www.lawphil.net/consti/cons1987.html.

Roque Harry. "តើការិយាល័យអំប៊ុដ្សមាន់បានដំណើរការអាណត្តិការងាររបស់ខ្លួន ក្នុងនាមជា"អ្នកគាំ ពារប្រជាជនឬទេ? បទពិសោធន៍ប្រទេសហ្វីលីពីន". ឯកសារដែលបានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ស្តីពីយន្តការបណ្តឹងផ្នែករដ្ឋបាលនៅអាស៊ាន នៅខេត្តសៀមរាប ប្រទេសកម្ពុជា. ថ្ងៃទី៣-៤ ខែមិថុនា ឆ្នាំ២០១៣.

Sieng D, Hor Ch និង You S. (ឆ្នាំ២០០៦). ការអនុវត្តសេវាសាធារណៈនៅមូលដ្ឋាន និងតម្លៃក្រៅផ្លូវការ. EIC.

Smith P, Red Tape និង អំប៊ុដ្សមាន់. សភាអូស្ត្រាលី.

សាធារណៈរដ្ឋសង្គមនិយមវៀតណាម. រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម. រដ្ឋសភា. ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩២. បានទទួលព័ត៌មាននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ពី http://www.na.gov.vn/htx/English/C1479/#H3UT027CqkTm

សាធារណៈរដ្ឋសង្គមនិយមវៀតណាម. ច្បាប់ស្តីពីបណ្តឹងនិងការចោទប្រកាន់. រដ្ឋសភា. ០៩/១៩៩៨/QH១០. ទីក្រុងហាណូយ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៩៨. បានទទួលព័ត៌មាននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.moj.gov.vn/vbpq/en/Lists/Vn%20bn%20php%20lut/View_Detail.aspx?ItemID=1265

តម្លាភាព និងបណ្តាញគណនេយ្យភាព. "ការិយាល័យអំប៊ុដ្សមាន់៖ តើស្ថាប័នមានចំណុចខ្សោយបែបណាខ្លះ?" បណ្តាញអភិវឌ្ឍន៍ធនធានមនុស្ស. PHDR Technical/Issue Note ២០០៨/២០០៩ លេខ២. ឆ្នាំ២០០៩. បានទទួលព័ត៌មាននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ ពី *hdn.org.ph/wp-content/uploads/2009/05/tin02_tan.pdf.*

"ប្រទេសថៃ/ក្រុមប្រឹក្សាUN HR៖ កង្វះខាតធ្ងន់ធ្ងរនៃយន្តការបណ្តឹងនៅប្រទេសថៃ". សាមគ្គីភាពផ្នែកសិទ្ធិមនុស្ស ១៦៖២. (ឆ្នាំ២០០៦). បានទទួលព័ត៌មាននៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ពី http://www.hrsolidarity.net/mainfile.php/2006vol16no02/2518/.

មហាសន្និបាតសហប្រជាជាតិ. របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីតុលាការបន្ថែម សេចក្តី សង្ខេប ឬការប្រព្រឹត្តិតាមទំនើងចិត្ត. **ការលើកឡើងបន្ថែមរបស់Philip Alston ការតាមដានចំពោះ អនុសាសន៍របស់ប្រទេស - ហ្វីលីពីន. ក្រុមប្រឹក្សាសិទ្ធិមនុស្ស.** A/HRC/១១/២/Add.៨. បានទទួលព័ត៌មាន នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ពី http://www.ihumanrights.ph/hr-mechanism/human-rights-bodies/charter-based-bodies/special procedures/reportsrecommendations/report-of-the-special-rapporteur-on-extrajudicial-summary-or-arbitrary-executions-philip-alston/.

UNDP. (ឆ្នាំ២០១០). ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដំណើរការបោះឆ្នោតនៅកម្ពុជា.

សមាគមអំប៊ូស្មាន់របស់សហរដ្ឋអាមេរិច. "ស្តង់ដាអំប៊ូស្មាន់របស់រដ្ឋាភិបាល". Ron Adcock, William Angrick II និង Becky Chia. ទីក្រុងDayton រដ្ឋOhio. ឆ្នាំ២០០៣. បានទទួលព័ត៌មាននៅថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០១៣ ពី *www.usombudsman.org/documents/PDF/.../USOA_STANDARDS.pdf*.

ធនាគារពិភពលោក. (ឆ្នាំ២០០៩). ការផ្សារភ្ជាប់រវាងប្រជាពលរដ្ឋ និងរដ្ឋនៅកម្ពុជា.

## ប្រភពឯកសារតាមអ៊ិនធើណេត៖

របាយការណ៍សង្ខេបក្នុងកិច្ចប្រជុំ PSO. (ឆ្នាំ២០១០). បានទទួលព័ត៌មានពី http://www.google.com.kh/url?sa=t&rct=j&q=&esrc=s&source=web&cd=1&ved=0CBoQFjAA&url=http%3A%2F%2Fwww.ncdd.gov.kh%2Fimages%2Fstories%2Fncdd%2F2010%2Fawg%2F1st_PSO_Meeting_Report.pdf&ei=P-50UOC5C6qfiAf_qIGIAQ&usg=AFQjCNGZ-soYT0E6xjgimhr2iGQzWOv1Yw

NCDD. គណនេយ្យភាព. បានទទួលព័ត៌មានពី http://www.ncdd.gov.kh/en/accountability-working-group

អង្គការ CCSP. (ឆ្នាំ២០១១) ព្រឹត្តិប័ត្រ D&D, អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា. បានទទួលព័ត៌មានពីhttp://www.ccspcambodia.org/index.php/resourcecenter/bullitenapublication

អង្គការCCSP. (ឆ្នាំ២០១០). ព្រឹត្តប័ត្រ D&D , ការវិភាគ D&D៖ ទស្សនវិស័យស្តីពីការផ្សារភ្ជាប់រវាងសង្គមស៊ីវិល ជាមួយនិងក្រុមប្រឹក្សាខេត្ត និងស្រុក. បានទទួលព័ត៌មានពី *http://www.ccspcambodia.org/index.php/resourcecenter/bullitenapublication*

Martin,V. (ឆ្នាំ២០១០). រំលឹកទ្រឹស្តី៖ យន្តការទទួលពាក្យបណ្តឹង និងការគ្រប់គ្រងការកេងប្រវ័ញ្ច និងការរំលោភបំពាន. បានទទួលព័ត៌មានពី http://www.un.org/en/pseataskforce/documents/hap_**literature_review**.pdf

## បទសម្ភាសន៍៖

ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១២ ជួបសម្ភាសន៍ជាមួយ លោកស្រី សៅ ចាន់ហម និង លោក អំ សំអាត អ្នកសម្របសម្រួលការិយាល័យឃ្លាំមើល និងអ្នកគ្រប់គ្រងបច្ចេកទេសឃ្លាំមើល. អង្គការលីកាដូ.

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ ជួបសម្ភាសន៍ជាមួយលោក ដោក ណារ៉េត ទីប្រឹក្សាគណនេយ្យភាព លោក ហួត លាភពិសិដ្ឋ និង លោក ជា វ៉ាន់ដា   មន្ត្រីគាំទ្រថ្នាក់ជាតិ. NCDD.

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ជួបសម្ភាសន៍ជាមួយលោក នី ចរិយា   ប្រធានកម្មវិធីស៊ើបអង្កេត. អង្គការ ADHOC.

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ជួបសម្ភាសន៍ជាមួយលោក លី សុជាវ៉ាយុទ្ធ   អ្នកគ្រប់គ្រងកម្មវិធី. NDI.

**ឧបសម្ព័ន្ធក៖ ពាក្យបណ្តឹងដែលបានដាក់តាមរយៈក្រុមការងារគណនេយ្យភាពខេត្ត(PAWG) ការិយាល័យប្រជាពលរដ្ឋស្រុក(DO) និងអង្គការសង្គមស៊ីវិល**

ចំនួនពាក្យបណ្តឹងសរុបដែលបានទទួលក្នុងឆ្នាំ២០១០ និងពីរត្រីមាសដំបូងនៃឆ្នាំ២០១១ មានដូចខាងក្រោម[87]៖

| | ចំនួនពាក្យបណ្តឹងដែលបានទទួល | ចំនួនពាក្យបណ្តឹងដែលស្ថិតក្នុងសមត្ថកិច្ចរបស់ PAWG | ចំនួនពាក្យបណ្តឹងដែលបានដោះស្រាយ |
|---|---|---|---|
| ឆ្នាំ២០១០ | ១២១៦ | ៦៣៩ | ២២៤ |
| ត្រីមាសទី១ និងទី២នៃឆ្នាំ២០១១ | ៣៤៦ | ៩៨ | ២១ |

ក្នុងចន្លោះពីខែមេសា និងខែមិថុនា នៃឆ្នាំ២០១២ បណ្តឹងចំនួន២២០ ត្រូវបានប្តឹងដោយប្រើប្រាស់វិធីសាស្រ្តខុសៗគ្នា ក្នុងនោះការដាក់ពាក្យបណ្តឹងតាមរយៈប្រអប់គណនេយ្យភាពមានប្រជាប្រិយភាពខ្លាំងជាងគេ។

| | **ត្រីមាសទីមួយ ឆ្នាំ២០១២** | | **ត្រីមាសទីពីរ ឆ្នាំ២០១២** | |
|---|---|---|---|---|
| | **ចំនួន** | **%** | **ចំនួន** | **%** |
| **ប្រអប់គណនេយ្យភាព** | ២៥៨ | ៩៩% | ២១៨ | ៩៩% |
| **ទូរស័ព្ទ** | 0 | 0% | 0 | 0% |
| **វិធីសាស្រ្តផ្សេងទៀត** | ២ | ១% | ២ | ១% |
| **សរុប** | ២៦០ | ១00% | ២២០ | ១00% |

*ប្រភព: របាយការណ៍ត្រីមាសទីពីរក្នុងឆ្នាំ២០១២ របស់ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ*

នីតិវិធីស៊ើបអង្កេត និងដំណោះស្រាយពាក្យបណ្តឹងត្រូវធ្វើឡើង បន្ទាប់ពីការជ្រើសរើសពាក្យបណ្តឹងត្រូវបានបញ្ចប់។ លទ្ធផលនៃការជ្រើសរើសពាក្យបណ្តឹងមានដូចខាងក្រោម៖

| | **ត្រីមាសទីមួយ ឆ្នាំ២០១២** | | **ត្រីមាសទីពីរ ឆ្នាំ២០១២** | |
|---|---|---|---|---|
| | **ចំនួន** | **%** | **ចំនួន** | **%** |
| **ពាក្យបណ្តឹងដែលបានដោះស្រាយ** | ១៧៧ | ៦៨% | ១១៧ | ៥៣% |
| **ពាក្យបណ្តឹងដែលមិនទាន់បានដោះស្រាយ** | ៨៣ | ៣២% | ១០៣ | ៤៧% |
| **សរុប** | ២៦០ | ១00% | ២២០ | ១00% |

*ប្រភព: របាយការណ៍ត្រីមាសទីពីរក្នុងឆ្នាំ២០១២ របស់ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ*

[87] ព័ត៌មានទទួលបានពីឯកសារផែនការសម្រាប់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន៖ លក្ខខ័ណ្ឌការងារសម្រាប់ទីប្រឹក្សា ស្តីពីការសិក្សាគម្រោងការិយាល័យច្រកចេញចូលតែមួយ(OWSO) និងការិយាល័យប្រជាពលរដ្ឋស្រុក(DO) ស្តីពីការបញ្ចូលការិយាល័យប្រជាពលរដ្ឋស្រុក និងក្រុមការងារគណនេយ្យភាពខេត្ត(PAWG).

ជារួម ពាក្យបណ្តឹងដែលបានដាក់មកមានចំនួនប្រាំបួនប្រភេទ[88]៖

1. ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកាតាមរាជធានី និងបណ្តាខេត្តនានា
2. ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកាតាមទីក្រុង និងស្រុក
3. ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកានៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់
4. ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិករដ្ឋបាលរាជធានី និងខេត្ត
5. ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិករដ្ឋបាលក្រុង ស្រុក និងខណ្ឌ (សមាជិកក្រុមប្រឹក្សា ក្រុមមន្ត្រីរដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ/សង្កាត់)
6. ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិកឃុំ/សង្កាត់ (សមាជិកក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ/ សង្កាត់)
7. ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់ជំនួយការ/បុគ្គលិករបស់ឃុំ/សង្កាត់
8. ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរនានាដែលបំពេញការងារក្រោមរដ្ឋបាលមូលដ្ឋាន
9. ពាក្យបណ្តឹងអំពីតួនាទីរបស់ដៃគូអង្គការសង្គមស៊ីវិលនៅកម្រិតរាជធានី និងខេត្ត

ក្រាហ្វិក និងតារាងលំអិតអំពីប្រភេទពាក្យបណ្តឹងដែលពេញនិយមជាងគេក្នុងឆមាសដំបូងនៃឆ្នាំ២០១២៖




*ប្រភព: របាយការណ៍ត្រីមាសទីពីរក្នុងឆ្នាំ២០១២ របស់ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ*

| ល.រ | ចំណាត់ថ្នាក់ | មករា - កក្កដា | |
|---|---|---|---|
| | | ចំនួន | % |
| ១ | ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកាតាមរាជធានី និងបណ្តាខេត្តនានា | 0 | 0% |
| ២ | ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកាតាមទីក្រុង និងស្រុក | ១ | 0% |
| ៣ | ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកានៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ | ១៣ | ៤% |
| ៤ | ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិករដ្ឋបាលរាជធានី និងខេត្ត | ៦ | ២% |
| ៥ | ពាក្យបណ្តឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិករដ្ឋបាលក្រុង ស្រុក និងខណ្ឌ (សមាជិកក្រុមប្រឹក្សា ក្រុមមន្ត្រីរដ្ឋបាល និងបុគ្គលិករបស់ក្រុម | ១២ | ៤% |

[88] បទសម្ភាសន៍ជាមួយក្រុមការងារគណនេយ្យភាព

| | | | |
|---|---|---|---|
| | ប្រឹក្សាឃុំ/សង្កាត់) | | |
| ៦ | ពាក្យបណ្ដឹងអំពីតួនាទី និងភារកិច្ចរបស់សមាជិកឃុំ/សង្កាត់ (សមាជិកក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ/ សង្កាត់) | ៤២ | ១៤% |
| ៧ | ពាក្យបណ្ដឹងអំពីតួនាទី និងភារកិច្ចរបស់ជំនួយការ/បុគ្គលិករបស់ឃុំ/សង្កាត់ | ១៤ | ៥% |
| ៨ | ពាក្យបណ្ដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរនានាដែលបំពេញការងារក្រោមរដ្ឋបាលមូលដ្ឋាន | ២១៦ | ៧០% |
| ៩ | ពាក្យបណ្ដឹងអំពីតួនាទីរបស់ដៃគូអង្គការសង្គមស៊ីវិលនៅកម្រិតរាជធានី និងខេត្ត | ៤ | ១% |
| សរុប | | ៣០៨ | ១០០% |

*ប្រភព: របាយការណ៍ត្រីមាសទីពីរក្នុងឆ្នាំ២០១២ របស់ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ*

**ពាក្យបណ្ដឹងតាមរយៈការិយាល័យប្រជាពលរដ្ឋស្រុក(DO)**

| | **ពាក្យបណ្ដឹងដែលបានទទួល** | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ភាពមិនពេញចិត្តចំពោះការផ្ដល់សេវាកម្ម | ៣១ | ៨ |
| ២ | ពាក្យបណ្ដឹងអំពីការផ្ដល់សេវាកម្មមានកម្រិតពេករបស់ OWSO | ៦៩ | ១៧ |
| ៣ | ពាក្យបណ្ដឹងអំពីអ្នកផ្ដល់សេវាកម្មផ្សេងៗ (ឧទាះ សាលាក្រុង និងមន្ទីរជំនាញ) | ៧ | ២ |
| | សរុប | ១០៧ | ២៧ |
| | **ការប្រាស្រ័យទាក់ទងផ្សេងទៀត** | | |
| ៤ | ការបញ្ចេញមតិកោតសរសើរ | ៧៥ | ១៩ |
| ៥ | សំណើសុំព័ត៌មានស្ដីពីសេវាកម្មរបស់ OWSO និងសេវាកម្មផ្សេងៗ | ២១៦ | ៥៤ |
| | សរុប | ២៩១ | ៧៣ |
| | សរុបរួម | ៣៩៨ | ១០០ |

**ពាក្យបណ្ដឹងមកពីអង្គការសង្គមស៊ីវិល**

**អង្គការលីកាដូ៖ ពាក្យបណ្ដឹងក្នុងរយៈពេល៦ខែដំបូងនៃឆ្នាំ២០១២[89]៖**

*ករណីដែលបានដោះស្រាយរួចរាល់៖*

- សិទ្ធិមនុស្ស៖១៨០ករណី៖ ៣ករណីបានដោះស្រាយរួចរាល់តាមរយៈតុលាការ ៤០ករណី បានដោះស្រាយតាមរយៈអាជ្ញាធរមូលដ្ឋាន (ប៉ូលីស ឃុំ/សង្កាត់)។
- គណៈកម្មាធិការសុរិយោដី ពាក់ព័ន្ធនឹងបញ្ហាដីធ្លី៖ ៣ករណី

*ករណីដែលកំពុងស្ថិតក្នុងដំណើរការដោះស្រាយ៖ ១៣១ករណី៖*

- ៧៨ករណីបានដោះស្រាយនៅកម្រិតអាជ្ញាធរមូលដ្ឋាន ៤៩ករណីបានដោះស្រាយនៅតុលាការ

[89] បទសម្ភាសន៍ជាមួយអង្គការលីកាដូនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២

- គណៈកម្មាធិការសុរិយោដី ពាក់ព័ន្ធនឹងបញ្ហាដីធ្លី៖ ៤ករណី
- ករណីពាក់ព័ន្ធនឹងយេនឌ័រ៖ ១០៨ករណី៖ អំពើហឹង្សាក្នុងគ្រួសារ៦៧ករណី រំលោភសេពសន្ថវៈ ៣៨ករណី ការបៀតបៀនរាងកាយ១ករណី និងការវាយប្រហារដោយអាស៊ីដ១ករណី។
- ករណីពាក់ព័ន្ធនឹងកុមារ៖ ១២០ករណី៖ រំលោភសេពសន្ថវៈ៩៩ករណី និង២១ករណីផ្សេងទៀត។

## អង្គការអាដហុក៖ ពាក្យបណ្តឹងក្នុងឆ្នាំ២០១១[90]

យោងតាមរបាយការណ៍ស្តីពីករណីសិក្សាចំនួន ៥៣២ករណី ដែលធ្វើឡើងដោយអង្គការអាដហុកក្នុងឆ្នាំ ២០១១ បង្ហាញថា អំពើហឹង្សាក្នុងគ្រួសារនៅតែជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ។ ជនរងគ្រោះភាគច្រើនដោយសារអំពើហឹង្សាក្នុងគ្រួសារគឺជាស្ត្រី និងកុមារទន់ខ្សោយ។ ក្នុងឆ្នាំដដែលនេះដែរ មានករណីរំលោភសេពសន្ថវៈចំនួន ៤៧៦ករណី។ តួលេខនេះមានការថយចុះប្រហែល ៥០១ករណីគិតចាប់ពីឆ្នាំ២០១០។

ក្នុងឆ្នាំ២០១១ ករណីរំលោភបំពានលើសិទ្ធិរបស់ពលករទេសន្តប្រវេសន៍ទាំងបុរស និងស្ត្រីបានកើនឡើងទ្វេរដងធៀបនឹងឆ្នាំ២០១០។ កាលពីឆ្នាំ២០១០ មានតែ៥១ករណីតែប៉ុណ្ណោះ ខណៈពេលដែលតួលេខនេះកើនដល់ ១០២ករណីក្នុងឆ្នាំ២០១១។ ករណីទាំងនេះគឺយោងតាមពាក្យបណ្តឹងដែលអង្គការអាដហុកទទួលបាន និង ការស៊ើបអង្កេតនិងអន្តរាគមន៍ ដែលអង្គការនេះបានធ្វើឡើងតាមរយៈការិយាល័យទាំង២៤របស់ខ្លួននៅទូទាំងខេត្ត/រាជធានីនៃប្រទេសកម្ពុជា។

## វិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI)

NDI មានកម្មវិធីកិច្ចពិភាក្សានៅតាមមណ្ឌលបោះឆ្នោតដើម្បីលើកកម្ពស់គណនេយ្យភាពរបស់សភា និងផ្តល់នូវលទ្ធភាពនៃដំណើរវិវត្តន៍ទៅមុខដ៏មានអត្ថន័យក្នុងការផ្សាភ្ជាប់រវាងប្រជាពលរដ្ឋ និងអ្នកតំណាងដែលខ្លួនបានបោះឆ្នោតជូន។ បច្ចុប្បន្ន NDI រៀបចំកិច្ចពិភាក្សាតាមបណ្តាខេត្តមួយចំនួន ដូចខាងក្រោម៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ក្រចេះ ព្រៃវែង សៀមរាប និង តាកែវ។ នៅទូទាំងខេត្តទាំង១២ អ្នកចូលរួមក្នុងកិច្ចពិភាក្សាបានលើកឡើងនូវបញ្ហាបីដូចគ្នា ដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ៖ ជម្លោះដីធ្លី តម្រូវការហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធស្រោចស្រព និងអំពើពុករលួយនិងការដាក់ឲ្យអនុវត្តដោយមិនស្មើភាពរបស់អាជ្ញាធរមូលដ្ឋាន។

[90] របាយការណ៍អង្គការអាដហុក ឆ្នាំ២០១២. សិទ្ធិរបស់ស្ត្រី និងកុមារនៅកម្ពុជា៖ របាយការណ៍ស្ថានភាពឆ្នាំ២០១១.

## ឧបសម្ព័ន្ធ ៦៖ តារាងរចនាសម្ព័ន្ធនៃយន្តការបណ្តឹងរបស់ប្រទេសថៃ

**អគ្គលេខាធិការ** — **ទីប្រឹក្សា**

### អគ្គលេខាធិការរង

**សេវាកម្មផ្នែកសាជីវកម្ម**

- ការិយាល័យរដ្ឋបាលទូទៅ
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យរដ្ឋបាលធនធានមនុស្ស
- ការិយាល័យICT
- ការិយាល័យគោលនយោបាយ និងផែនការ

**អង្គភាពសវនកម្មផ្ទៃក្នុង**

### អគ្គលេខាធិការរង

**ការស៊ើបអង្កេត**

- ការិយាល័យទទួលពាក្យបណ្តឹង និងដំណោះស្រាយមុនកាលកំណត់
- ការិយាល័យស៊ើបអង្កេតទី១
- ការិយាល័យស៊ើបអង្កេតទី២
- ការិយាល័យស៊ើបអង្កេតទី៣
- ការិយាល័យស៊ើបអង្កេតក្រមសីលធម៌និងស៊ើបអង្កេតពិសេស
- ការិយាល័យច្បាប់

### អគ្គលេខាធិការរង

**ការអប់រំ និងPR**

- ការិយាល័យលើកកម្ពស់ស្តង់ដាក្រមសីលធម៌
- ការិយាល័យត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តស្របតាមរដ្ឋធម្មនុញ្ញ
- ការិយាល័យទំនាក់ទំនងរវាងPR និងអាជីវកម្ម
- វិទ្យាស្ថានសិក្សាអំពីអំប៊ុដ្សមាន់